ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រ ដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា
លេខ២៤៦ ខែមិថុនា ឆ្នាំ២០២០

## ស្វែងរកការពិត

### ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*លេខ ២៨៦ ខែមិថុនា ឆ្នាំ២០២០*

## មាតិកា

**សំបុត្រ**

◆ ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រ ......១

**ផ្នែកឯកសារ**

◆ ជូ ជុនហ៊ិន ប្រជាជនថ្មីជម្លៀសទៅតំបន់៥ .... ៩

**ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ**

◆ ខ្ញុំមានជីវិតរស់ដោយសារលួចដំឡូងមីហូប . ១៣
◆ ខ្ញុំរលូតកូនដោយសាររែកដី.................១៦
◆ ថ្វាង កាន អតីតប្រធានពេទ្យ.............. ១៨
◆ យុទ្ធនារីបដិវត្តន៍.......................... ២២
◆ បូជាភ្លើង...................................២៥
◆ រែកប្រាក់ដែលបន្សល់ទុកពីសម័យ ........... ៣៣

**ផ្នែកច្បាប់**

◆ សាលក្រមសំណុំរឿង០០២/០២ ........... ៣៦

**ផ្នែកវេទិកាសាធារណៈ**

◆ ការឈឺចាប់ដែលមិនអាចបំភ្លេចបាន .......៤២
◆ ពេលវេលាដ៏លំបាកសម្រាប់ខ្ញុំនៅក្នុងរបប.. ៤៤
◆ របបខ្មែរក្រហមមិនដែលរសាត់ចេញពី..... ៤៧

**ផ្នែកស្រាវជ្រាវរកគ្រួសារ**

«ផេះផង់ធូលី» រឿងរ៉ាវចេញពីប្រជាជនថ្មី ក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
◆ សេក មឿន ៖ ពលទាហាន.................៥០
◆ ស៊ុំ ស្រស់ ៖ ពេទ្យទាហាន.................៥២
◆ ឈួន សុភ័ក្រ ៖ តម្រួតយោធា ........... ៥៣
◆ ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា .................. ៥៥
◆ បញ្ជីឈ្មោះអ្នកដែលបានស្លាប់.............. ៥៨



កុមារកំពុងរែកដីនៅការដ្ឋានការងារនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ឆ្នាំ១៩៧៥-១៩៧៩)។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**រក្សាសិទ្ធិ**
មជ្ឈមណ្ឌលឯកសារកម្ពុជា
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ៣៧៥៣.មប្រក
ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨
រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

**ស្នេរលេខនេះ៖** ផេង ពង្សរ៉ាស៊ី, សុង ថាណៃ, ហេឌី ប្រហ្វាយ, ប៉ាង ពីរ៉ុន្ត, វេនី ខកហ្កៀល, កៅ សិរិទ្ធ, វ៉ាន់ថាន់ ពៅដារ៉ា និងឡុង ដានី
**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ហូ ថុនា,ដារ៉ារដ្ឋ មេត្តា, អ៊ុន សុដាវី **អ្នកបកប្រែ៖** អ៊ុន សុដាវី
**និពន្ធនាយកទូទៅ៖** សោម ប៊ុនថន **ជំនួយការនិពន្ធនាយក៖** ហូ ថុនា
**ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនីឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង
Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org



# ពិព័រណ៍បង្ហាញពេលវេលាប្រវត្តិសាស្ត្រ

## ដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៧៧

*ផេង ពង្សរ៉ាស៊ី*



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្ម នៅវេលាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។ (ស៊ាង ចន្ទា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅក្នុងពិធីរំឭកខួបលើកទី៤៣ នៃទិវាចងចាំពីដំណើរឆ្ពោះទៅការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់សម្តេចតេជោ ហ៊ុន សែន ប្រារព្ធធ្វើឡើងនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០នេះ មានការរៀបចំដាក់តាំងពិព័រណ៍បង្ហាញពេលវេលាជាប្រវត្តិសាស្ត្រមួយដែលមានរូបភាពចំនួន១០៧សន្លឹក, រូបគំនូរចំនួន៣៦ផ្ទាំង និងផែនទីចំនួន៦ផ្ទាំង នៅក្នុង «មជ្ឈមណ្ឌលឯកសារកោះថ្ម»។ មជ្ឈមណ្ឌលឯកសារកោះថ្មនេះ គឺផ្តើមចេញពីគំនិតរបស់ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ ទីប្រឹក្សាពិសេសសម្តេចពិជ័យសេនា ទៀ បាញ់ និងជាអគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេសនៃក្រសួងការពារជាតិ ជាមួយនឹងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ក្នុងដំណើរកម្មសិក្សានៅតំបន់កោះថ្មនាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០។

នៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២០ នាយឧត្តមសេនីយ៍ សៅ សុខា អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានផ្ញើលិខិតស្នើសុំបន្ទប់រៀនចំនួន ២បន្ទប់ នៅក្នុងសាលា



សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិទស្សនកិច្ច មជ្ឈមណ្ឌលឯកសារកោះថ្ម នៅវេលាព្រឹកថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២០។
(ស៊ាង ចិន្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បឋមសិក្សា ប៊ុនរ៉ានី ហ៊ុន សែន កោះថ្ម ស្ថិតនៅក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ សម្រាប់រៀបចំជាសារមន្ទីររក្សាទុកឯកសារស្រាវជ្រាវ ដោយសហការរៀបចំនិងប្រតិបត្តិជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០២០ លិខិតពីឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានឯកភាពលើសំណើរសុំបន្ទប់សិក្សាចំនួន២នេះ។

ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជារួមមាន ឡុង ដានី, ផេង ពង្សរ៉ាស៊ី, លី កុកឆាយ, សូ ហ្វារីណា, លឹម យ៉ុងហួត និងសុខ វណ្ណៈ បានរៀបចំតម្លើងផ្ទាំងពិព័រណ៍រូបថត និងរចនាមជ្ឈមណ្ឌលឯកសារកោះថ្មនេះឡើង។ ឯកសារពិព័រណ៍បង្ហាញពេលវេលាជាប្រវត្តិ-សាស្ត្រនេះយកចេញពី ១) ឯកសារខ្មែរក្រហម ២) ឯកសារអាមេរិក និង៣) ឯកសារវៀតណាម និងរូបភាពទាំងឡាយផ្តើមចេញពីអ្នកថតរូបចំនួន៥រូប គឺ ១) ម៉ៃ ឡាំ អ្នកថតរូបវៀតណាម, ២) ស៊ីលវ៉ាណា ហ្វ័រ អ្នកថតរូបអាមេរិក ៣), ដេវីត ហ៊ិក អ្នកថតរូបអាមេរិក, ៤) ឆាំង យុ អ្នកថតរូបកម្ពុជា និង៥) ហ៊ុនណោ បឹតស្រ្តម អ្នកថតរូបស៊ុយអែត និង រូបគំនូរទាំង៣៦ផ្ទាំង គូរដោយវិចិត្រករ អ៊ុត រឿន។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអ្នករៀបចំពិព័រណ៍នេះ ដើម្បីជាការចាប់ផ្តើមបង្កើតឲ្យមានមជ្ឈមណ្ឌលឯកសារកោះថ្ម សហការជាមួយក្រុមការងារវិមានឈ្នះឈ្នះ តំបន់ប្រវត្តិសាស្ត្រយោធានៃក្រសួងការពារជាតិ។ មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រុមការងារប្រវត្តិសាស្ត្រយោធានីងខិតខំពង្រឹងកិច្ចសហការឲ្យមានការសិក្សាស្វែងយល់ និងស្រាវជ្រាវអំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជាឲ្យកាន់តែប្រសើរជាងសព្វថ្ងៃ សម្រាប់ជាចំណេះចេះដឹងដល់យុវជនយុវនារីជំនាន់ក្រោយ។ មជ្ឈមណ្ឌលឯកសារកោះថ្មនេះ ក៏មានតួនាទីជាទីតាំងបណ្តោះអាសន្នសម្រាប់រៀបចំធ្វើ សារមន្ទីរក្រោមលំហមេឃ មួយនៅលើផ្ទៃដីនៅចំពីមុខសាលាបឋមសិក្សាកោះថ្ម។

រូបថតដែលបានដាក់តាំងបង្ហាញទាំងអស់ គឺជាបណ្តុំរូបថតបន្សល់ទុកពីទសវត្សរ៍ឆ្នាំ១៩៦០ រហូតដល់ទសវត្សរ៍ឆ្នាំ១៩៩០។ រូបថតទាំងនេះ បង្ហាញដល់អ្នកទស្សនាអំពីព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ របស់ប្រទេសកម្ពុជា ដែលចាប់ផ្តើមពីការធ្វើសង្គ្រាមនៅតាមព្រំប្រទល់កម្ពុជា-វៀតណាម ជាពិសេសនៅតំបន់កោះថ្ម ឃុំទន្លូង និងភូមិមួយចំនួនក្នុងឃុំជាំក្រវៀន ស្រុកមេមត់ ខេត្តកំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ), ការកកើតនិងគ្រប់គ្រងប្រទេសទាំងស្រុងរបស់ខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលបង្កឲ្យមានមហន្តរាយយ៉ាងធ្ងន់ធ្ងរដល់ជីវិតប្រជាជនកម្ពុជាជាង២លាននាក់ និងហេដ្ឋារចនាសម្ព័ន្ធប្រទេសទាំងមូល, ដំណើរឆ្ពោះទៅរកការដួលរំលំរបបខ្មែរក្រហមនិងជីវិតរស់នៅប្រចាំថ្ងៃបន្ទាប់ពីរបបខ្មែរក្រហម ព្រមទាំងភ័ស្តុតាងឧក្រិដ្ឋដែលបន្សល់ទុកពីរបបនេះ រហូតឈានដល់ការផ្តួចផ្តើមគំនិតបង្កើតគោលនយោបាយឈ្នះ ឈ្នះ របស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ដើម្បីបង្រួបបង្រួមប្រទេសទាំងមូលដោយសន្តិភាពនិងសន្តិវិធី។





# ពិព័រណ៍រូបថតបង្ហាញពីសំណល់សង្គ្រាមទសវត្សរ៍ ៦០ ដល់ ៧០ នៅតំបន់កោះថ្ម ក្នុងឃុំជាំក្រវៀន





ឧទ្ធម្ភាគចក្រយោធារបស់អាមេរិក។
(ដេវីដ ហ៊ិក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ពិព័រណ៍ផ្នែកនេះ បង្ហាញពីការធ្លាក់ឧទ្ធម្ភាគចក្រយោធារបស់អាមេរិក និងមូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ឬវៀតកុង នៅក្នុងទឹកដីឃុំជាំក្រវៀន ស្រុកមេមត់។ រូបឧទ្ធម្ភាគចក្រដែលកំពុងបន្ទាបខ្លួនចុះ មានឈ្មោះសម្គាល់ថា អេអេច-វិនហ្គី កូប្រា បានធ្លាក់នៅចម្ងាយប្រមាណ១០០ម៉ែត្រ ភាគខាងលិចភូមិដងទង់ ឃុំជាំក្រវៀន នៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧០។ រូបថតមួយសន្លឹកទៀត ដែលអាចមើលឃើញថាជាប្រភេទឧទ្ធម្ភាគចក្រមានកង្ហារពីរមុខនិងក្រោយ មានឈ្មោះសម្គាល់ថា ជីនុក បានធ្លាក់នៅចំណុចខាងជើងភូមិដងទង់ ឃុំជាំក្រវៀន។ អ្នកភូមិបានប្រាប់ពីការធ្លាក់ឧទ្ធម្ភាគចក្រ ជីនុក ថា បានធ្លាក់នៅក្នុងឆ្នាំ១៩៧០។ រូបថតមួយសន្លឹកទៀត ជាប្រភេទឧទ្ធម្ភាគចក្រ អូ អេច-៦ បានធ្លាក់នៅក្បែរស្រះទឹកមួយក្នុងភូមិរបងច្រេះ ឃុំជាំក្រវៀន ដែលមានចម្ងាយប្រមាណ៥០០ម៉ែត្រពីព្រំប្រទល់វៀតណាមក្នុងឆ្នាំ១៩៧០។ ចំណែករូបថតពីរសន្លឹកទៀតនៃផ្នែកនេះ បង្ហាញពីមូលដ្ឋានទ័ពរបស់វៀតណាមខាងជើង ដែលមានទីតាំងស្ថិតនៅចម្ងាយប្រមាណ១ពាន់៥រយម៉ែត្រប៉ែកខាងជើងភូមិតាសោម និង៧គីឡូម៉ែត្រប៉ែកត្បូងសានភូមិតាសោម ឃុំជាំក្រវៀន ក្នុងទឹកដីប្រទេសកម្ពុជា។ មូលដ្ឋានទាំងពីរនេះ ត្រូវបានសាងសង់ឡើងក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៦០។ រូបថតបង្ហាញពីទាហានរបបសាធារណរដ្ឋខ្មែរវាយដំទង់ពីររូបឈរស្តាយគ្រាប់ និងកាំភ្លើងនៅសងខាងស្ត្រីអ្នកកាសែតដែលជាជនជាតិអាមេរិក គឺជាមូលដ្ឋានទ័ពមួយត្រូវបានប្រើប្រាស់ជាមន្ទីរ១០០របស់ខ្មែរក្រហម ក្នុងឆ្នាំ១៩៦៣ដល់ឆ្នាំ១៩៦៥។ អ្នកថតរូប និងជាអ្នកកាសែតរូបនេះមានឈ្មោះថា ស៊ីលវ៉ាណា ហ្វ័រ គឺជាអតីតអ្នកឆ្លើយឆ្លងព័ត៌មានបរទេស និងអ្នកជំនាញកិច្ចការសាធារណៈ។ គាត់គឺជាស្ត្រីដំបូងដែលបម្រើការជានិពន្ធនាយករបស់ទីភ្នាក់ងារសារព័ត៌មានអន្តរជាតិដ៏ធំមួយនៃបណ្តាញទូរទស្សន៍អាមេរិក និងជាស្ត្រីដំបូងបង្អស់ដែលបម្រើការជាអ្នកនាំពាក្យរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ។ នៅខែមេសា ឆ្នាំ១៩៧៣ លោកស្រីត្រូវបានបណ្តេញចេញពីប្រទេសកម្ពុជាដោយសារតែលោកស្រីបានធ្វើសេចក្តីរាយការណ៍អំពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ចំពោះសកម្មភាពទម្លាក់គ្រាប់បែកនៅក្នុងប្រទេសកម្ពុជា។ របាយការណ៍របស់លោកស្រីបានធ្វើឲ្យព្រឹទ្ធសភាអាមេរិក ចេញបញ្ជាឲ្យបញ្ឈប់ជាបន្ទាន់នូវការទម្លាក់គ្រាប់បែកនៅកម្ពុជា។ បច្ចុប្បន្នលោកស្រីរស់នៅក្នុងប្រទេសអ៊ីស្រាអែល។

# ពិព័រណ៍រូបថតបង្ហាញពីជីវិតក្នុងរបប ប៉ុល ពត



រូបថតក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតជាច្រើនសន្លឹកក្នុងផ្នែកនេះ បង្ហាញពីប្រជាជនកម្ពុជាទាំងចាស់ទាំងក្មេង ធ្វើការងារពលកម្មលើកទំនប់ ជីកប្រឡាយ ធ្វើស្រែ កសាងប្រព័ន្ធធារាសាស្ត្រ និងកំណែនកុមារា និងកុមារី ឲ្យធ្វើជាកងទ័ពចូលប្រយុទ្ធក្នុងសមរភូមិប្រឆាំងនឹងកងទ័ពវៀតណាម។ ពុំមានរូបថតមួយសន្លឹកណាទេ ដែលបង្ហាញពីការយកចិត្តទុកដាក់របស់ខ្មែរក្រហមក្នុងវិស័យអប់រំ។ ក្មេងៗនិងយុវជនយុវនារីត្រូវបង្ខំឲ្យធ្វើការងារពលកម្មស្រែចម្ការ និងបង្ខំឲ្យចូលរួមប្រយុទ្ធនៅក្នុងសមរភូមិ។ សម្លៀកបំពាក់ខ្មៅ គឺជាឯកសណ្ឋានដែលសម្គាល់ពីភាពស្មើភាពគ្នា គ្មានវណ្ណៈសង្គម និងសមូហភាព។ ការងារពលកម្ម និងធ្វើស្រែចម្ការ គឺជាទិសដៅកំណត់ពីអង្គការថ្នាក់លើ ដើម្បីឈានដល់ការអភិវឌ្ឍន៍ប្រទេសឲ្យក្លាយទៅជាប្រទេសដែលមានវិស័យកសិកម្មជឿនលឿនលើសាកលលោក។ ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ របបខ្មែរក្រហមបាននាំប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងសោកនាដកម្មយ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណជាងពីរលាននាក់។ មេដឹកនាំកំពូលៗនៃរបបនេះ ត្រូវបាននាំខ្លួនមកកាត់ទោសពីបទឧក្រិដ្ឋដែលខ្លួនបានប្រព្រឹត្ត គឺបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ។ រូបថតទាំងអស់នេះ ថតក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ដោយអ្នកថតរូបខ្មែរក្រហមមិនស្គាល់ឈ្មោះម្នាក់ និងអ្នកសារព័ត៌មានជនជាតិស៊ុយអែតឈ្មោះ ហ្គូណា បឺតស្ត្រម និងមានតម្កល់នៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា។

ហ្គូណា បឺតស្ត្រម បានមកធ្វើទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ ក្នុងខែសីហា ឆ្នាំ១៩៧៨។ គាត់ គឺជាអ្នកគាំទ្រខ្មែរក្រហមម្នាក់លើវិស័យនយោបាយ សង្គម និងសេដ្ឋកិច្ច។ ហ្គូណា ធ្លាប់ជួបដោយផ្ទាល់ជាមួយ ប៉ុល ពត ហើយគាត់ត្រូវបានបំផុសគំនិតថា ការកសាងសង្គមមួយ គឺត្រូវពឹងផ្អែកលើភាពឯករាជ្យម្ចាស់ការ និងសមភាព។ នៅឆ្នាំ ២០០៨ និងឆ្នាំ២០១៦ ហ្គូណា បានមកទស្សនកិច្ចប្រទេសកម្ពុជា ដើម្បីធ្វើការសុំទោសជាសាធារណៈដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងបានបង្រៀនដល់ក្មេងៗជំនាន់ក្រោយឲ្យខិតខំថែរក្សា និងចងចាំពីប្រវត្តិសាស្ត្រខ្លួនឯងក្នុងន័យទប់ស្កាត់អំពើប្រល័យពូជសាសន៍កើតឡើងម្តងទៀត។ ហ្គូណាបឺតស្ត្រម សព្វថ្ងៃនេះគាត់រស់នៅទីក្រុងស្តុកឃម ប្រទេសស៊ុយអែត។



រូបថតក្នុងអំឡុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





# ពិព័រណ៍រូបថត និងរូបភាពបង្ហាញពីដំណើរឆ្ពោះទៅរកការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត របស់ សម្តេចតេជោ ហ៊ុន សែន ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧

រូបថត និងរូបគំនូរដែលមាននៅក្នុងផ្នែកនេះ គឺជាដំណើរដ៏គ្រោះថ្នាក់របស់សម្តេចតេជោ នាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីពាក់កណ្តាលឆ្នាំ១៩៧៧ ឆ្ពោះទៅកានប្រទេសវៀតណាម ក្នុងគោលបំណងប្រមូលកម្លាំងអ្នកតស៊ូស្នេហាជាតិ ដើម្បីវាយរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត។ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧ គឺជាថ្ងៃដែលសម្តេចតេជោ និងយុទ្ធមិត្តដ៏ស្មោះស្ម័គ្រ៤រូបទៀត សម្រេចចិត្តរត់ចេញទាំងក្តីបារម្ភបំផុត ពីបន្ទាយកោះថ្ម ស្ថិតក្នុងភូមិកោះថ្ម ឃុំទន្លូង ស្រុកមេមត់ ខេត្តកំពង់ចាម ដែលជាទីតាំងបន្ទាយឈរជើងរបស់សម្តេចតេជោក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សម្តេចនិងយុទ្ធមិត្ត បានធ្វើដំណើរឆ្លងកាត់អូរតូចមួយ ប៉ុន្តែនៅក្នុងមហិច្ឆតាដ៏ធំបំផុត ក្នុងតំបន់អាងកាច់ ដែលខណ្ឌចែកព្រំដែននៃប្រទេសទាំងពីរ ឆ្ពោះទៅកាន់ទឹកដីវៀតណាម។ នៅក្នុងទឹកដីវៀតណាម សម្តេចនិងយុទ្ធមិត្ត បានលាក់អាវុធនិងសម្ភារផ្សេងៗរួចធ្វើដំណើរដោយថ្មើរជើងចូលទៅកាន់ភូមិមួយ ជាទីកន្លែងដែលសម្តេចនិងយុទ្ធមិត្តទទួលបានការស្វាគមន៍រាក់ទាក់ពីប្រជាជនវៀតណាម មុនពេលដែលប្រជាជនវៀតណាមទាំងនោះ នាំសម្តេចនិងយុទ្ធមិត្តទាំងអស់ទៅកាន់ទីស្នាក់ការឃុំរបស់វៀតណាម។ សម្តេចតេជោត្រូវបានភាគីវៀតណាមសួរចម្លើយជាលើកទីមួយនៅទីនោះ។ បន្ទាប់មក សម្តេច ហ៊ុន សែន ត្រូវបានបញ្ជូនទៅកាន់ស្រុកមិញភៀកជាទីកន្លែងដែលសម្តេចត្រូវសួរចម្លើយម្តងទៀតពីកម្មាភិបាលថ្នាក់ស្រុក។ នៅឆ្នាំ ១៩៧៨ សម្តេច ហ៊ុន សែន បានក្លាយជាសមាជិកស្ថាបនិកនៃរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ ដោយមានការសហការជាមួយចលនាស្នេហាជាតិនានា និងការគាំទ្រពីកងកម្លាំងស្ម័គ្រចិត្តវៀតណាម រណៈសិរ្សបានសង្គ្រោះប្រទេស និងប្រជាជនកម្ពុជាទាំងស្រុងនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។

រូបគំនូរពីដំណើរឆ្ពោះទៅផ្តួលរំលំរបបប្រល័យពូជសាសន៍ប៉ុល ពត របស់សម្តេចតេជោ គូរដោយវិចិត្រករ អ៊ុត រឿន។ លោក អ៊ុត រឿន បានចាប់ផ្តើមគូរគំនូរដំបូងនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ លោកបានបោះពុម្ពសៀវភៅគំនូររឿង ព្រះថោងនាងនាគ, ធនញ្ជ័យ និងទុំទាវ។ ក្នុងរបបខ្មែរក្រហម លោកត្រូវខ្មែរក្រហមតម្រូវឲ្យគូរគំនូរស្តីអំពី «ផែនការសាងសង់សម្រាប់អង្គការបដិវត្តន៍»។ លោក អ៊ុត រឿន បានចូលនិវត្តន៍នៅឆ្នាំ២០០១។ បច្ចុប្បន្ន លោកគឺជាវិចិត្រករនៅវិមាន ឈ្នះ ឈ្នះ។





រូបគំនូរអំពីដំណើររបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ឆ្ពោះទៅប្រទេសវៀតណាម កាលពីពាក់កណ្តាលឆ្នាំ ១៩៧៧។ (អ៊ុត រឿន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពិព័រណ៍រូបថតបង្ហាញពីការវិលត្រឡប់មកស្រុកភូមិវិញក្នុងឆ្នាំ ១៩៧៩ បន្ទាប់ពីការដួលរលំរបប ប៉ុល ពត

រូបថតទាំងអស់នៅក្នុងផ្នែកនេះ ដែលត្រូវបានថតឡើងក្នុងឆ្នាំ១៩៧៩និង១៩៨០ ដោយអ្នកថតរូបជនជាតិវៀតណាមពីររូបគឺ ឌិញ ហ៊ុង និងហូ វ៉ាន់តាយ បង្ហាញពីជ័យជំនះលើរបបខ្មែរក្រហម តាមរយៈការចូលដល់ទីក្រុងភ្នំពេញរបស់កងកម្លាំងរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងកម្លាំងស្ម័គ្រចិត្តវៀតណាម នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ និងការរស់ឡើងវិញរបស់ប្រជាជនកម្ពុជា។ បន្ទាប់ពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាជនកម្ពុជាប្រមាណ៥លាននាក់ ដែលភាគច្រើនជាកុមារ និងស្ត្រីមេម៉ាយ បានរួចរស់ជីវិតពីរបបខ្មែរក្រហម និងបានវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ខ្លួនវិញ។ រូបថតបានបង្ហាញពីការធ្វើដំណើរដោយឥតគោលដៅ ប៉ុន្តែប្រកបដោយក្តីសង្ឃឹមថ្មី និងជីវិតវេទនារបស់ក្មេងកំព្រា, ការវិលត្រឡប់មកកាន់ស្រុកកំណើតរបស់ប្រជាជនដោយគ្មានស្បែកជើង និងការបង្ហាញពីស្លាកស្នាមធ្វើទារុណកម្មរបស់ខ្មែរក្រហម ព្រមទាំងពិការភាពដែលបន្សល់ទុកដោយខ្មែរក្រហម។



ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើតបន្ទាប់ពីរបបខ្មែរក្រហមដួលរលំឆ្នាំ១៩៧៩។ (ឌិញ ហ៊ុង និងហូ វ៉ាន់តាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ឌិញ ហ៊ុង និងហូ វ៉ាន់តាយ គឺជាអតីតអ្នកថតភាពយន្តឯកសារ «គុកទួលស្លែង» ដំបូងបង្អស់ នៅថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩។ អ្នកទាំងពីរ បានចូលទៅកាន់គុកទួលស្លែងតាមរយៈក្លិនស្អុយរបស់សាកសព និងបានថតរូបជាច្រើនសន្លឹកពីទិដ្ឋភាពក្នុងគុក ព្រមទាំងបានជួយសង្គ្រោះក្មេងកំព្រា៥នាក់ ដែលឪពុកម្តាយត្រូវបានសម្លាប់ដោយខ្មែរក្រហម។ សព្វថ្ងៃ ហូ វ៉ាន់តាយ រស់នៅខណ្ឌ បិញថាញ់។

# ពិព័រណ៍រូបថតបង្ហាញពីរូបភាពបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍



អដ្ឋិធាតុរបស់ជនរងគ្រោះពីរបបខ្មែរក្រហម។
(ដេវីដ ហ៊ក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតច្រើនសន្លឹកនៅក្នុងផ្នែកនេះ បង្ហាញពីការសម្លាប់រង្គាលរបស់ខ្មែរក្រហមមកលើប្រជាជនកម្ពុជាក្នុងរយៈពេលនៃការកាន់កាប់ប្រទេសពីឆ្នាំ១៩៧៥ដល់១៩៧៩។ ថ្វីត្បិតតែមានប្រជាជនកម្ពុជាជាច្រើននាក់បានស្លាប់ដោយសារជំងឺ ហូបមិនគ្រប់គ្រាន់ ធ្វើការហួសកម្លាំង និងធ្វើទារុណកម្មក៏ដោយ ក៏នៅមានប្រជាជនកម្ពុជាជាច្រើននាក់ផ្សេងទៀត ត្រូវបានសម្លាប់ក្រោមរូបភាពធ្វើបន្សុទ្ធកម្មដើម្បីស្វែងរកសមាសភាពក្បត់នឹងអង្គការបដិវត្តន៍ ដូចជាគិញសម្ងាត់សេអ៊ីអារបស់អាមេរិក គិញសម្ងាត់កាហ្សេបេរបស់រុស្ស៊ី និងទាហាននិងមន្ត្រីរដ្ឋការរបស់របបសាធារណរដ្ឋខ្មែរជាដើម។ ខ្មែរក្រហមបានបង្កើតឲ្យមានមន្ទីរសន្តិសុខ ឬគុក ចំនួន១៩៧កន្លែង ដើម្បីឃុំឃាំង ធ្វើទារុណកម្ម សួរចម្លើយអ្នកទោស និងសម្លាប់។ មន្ទីរសន្តិសុខទាំងនោះ បានប្រព្រឹត្តឡើងជាលក្ខណៈប្រព័ន្ធ ចាប់តាំងពីថ្នាក់មូលដ្ឋានរហូតដល់ថ្នាក់មជ្ឈិម (មន្ទីរ ស-២១)។ នៅដើមឆ្នាំ១៩៨០ ឆ្អឹងលលាដ៏ក្បាល ឆ្អឹងដងខ្លួន និងឆ្អឹង អវៈយវៈរបសជនរងគ្រោះ ត្រូវបានប្រមូលទុកដាក់នៅក្នុងស្តូប ឬចេតិយ៍ក្នុងបរិវេណវត្តអារាមនៅតាមទីកន្លែងដែលស្ថិតនៅជិតៗកន្លែងសម្លាប់ ដើម្បីធ្វើជាភស្តុតាង និងសម្រាប់ធ្វើបុណ្យតាមប្រពៃណីសាសនា។ នៅថ្ងៃ២០ ខែឧសភា រៀងរាល់ឆ្នាំ ប្រជាជនកម្ពុជាទូទាំងប្រទេស តែងតែធ្វើពិធីបង្សុកូលគោរពដល់វិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ទៅក្នុងរបបខ្មែរក្រហម។

រូបថតទាំងអស់នេះ ថតដោយ ម៉ៃ ឡាំ នៅក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩។ ម៉ៃ ឡាំ បានមកដល់ប្រទេសកម្ពុជា ប្រហែលនៅក្នុងខែកុម្ភៈ ឬ មីនា ឆ្នាំ១៩៧៩ ក្នុងតួនាទីជាវរសេនីយ៍ឯករបស់កងទ័ពវៀតណាម។ គាត់មានចំណេះដឹងផ្នែកច្បាប់ជ្រៅជ្រះ និងមានជំនាញខាងរៀបចំនិងប្រតិបត្តិសារមន្ទីរបែបវិទ្យាសាស្ត្រ។ ម៉ៃ ឡាំ បានទទួលភារកិច្ចដ៏សំខាន់មួយ ក្នុងការរៀបចំឯកសារទាំងអស់ដែលត្រូវបានរកឃើញនៅក្នុងមន្ទីរ ស-២១ ឲ្យទៅជាសារមន្ទីរមួយ ដែលមានឈ្មោះហៅថា «សារមន្ទីរនៃសុបិនអាក្រក់របស់កម្ពុជា»។ កិច្ចការរបស់គាត់ គឺជាកិច្ចការដ៏មានតម្លៃ និងជាភស្តុតាងក្នុងការបង្កើតតុលាការប្រជាជនបដិវត្តន៍កម្ពុជាក្នុងខែសីហា ឆ្នាំ១៩៧៩ ដើម្បីកាត់ទោស ប៉ុល ពត និងអៀង សារី ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។

# ពិព័រណ៍រូបថតបង្ហាញពីរូបភាពជីវិតប្រចាំថ្ងៃនៅទសវត្សរ៍៨០



ប្រជាជនកម្ពុជាក្នុងកំឡុងទសវត្សរ៍ ៨០ ។
(ដេវីដ ហ៊ក, ឆាំង យុ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបថតប៉ុន្មានសន្លឹកនៅក្នុងផ្នែកនេះ ដែលថតដោយលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងប្រវត្តិវិទូសញ្ជាតិអាមេរិក ដេវីត ហ៊ក បង្ហាញពីផ្នែកសំខាន់ៗចំនួនបួនគឺ ការចរាចរណ៍ទីផ្សារនិងវិស័យគមនាគមន៍, ការស្តារឡើងវិញនូវវិស័យព្រះពុទ្ធសាសនា និងការមិនរើសអើងពូជសាសន៍, សេរីភាពក្នុងការប្រកបការងារនិងរស់រាន, និងការចាប់ផ្តើមឡើងវិញនៃវិស័យអប់រំ។ រយៈពេលជាង៤០ឆ្នាំក្រោយរបបខ្មែរក្រហម កម្រងរូបថតទាំងនេះ ក្លាយជាកម្រងរូបថតអនុស្សាវរីយ៍ ដែលមិនអាចបំភ្លេចបាន និងជាផ្នែកមួយនៃដំណើរការស្វែងរកយុត្តិធម៌សម្រាប់សង្គមកម្ពុជានាពេលបច្ចុប្បន្ន។ លោក ឆាំង យុ បានមានប្រសាសន៍ថា «ការចងចាំពីអំពើប្រល័យពូជសាសន៍ នៅតែជាផ្នែកមួយនៃអត្តសញ្ញាណរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន និងជាច្រើនជំនាន់ទៀតទៅថ្ងៃអនាគត។ សង្គមមួយមិនអាចស្គាល់ខ្លួនឯងបានទេ ប្រសិនបើសង្គមនោះពុំមានការចងចាំច្បាស់លាស់អំពីប្រវត្តិសាស្ត្ររបស់ខ្លួន។» ប្រវត្តិវិទូ ដេវីត ហ៊ក បានអធិប្បាយថា «អ្នករស់រានមានជីវិត

ក្រោយរបបខ្មែរក្រហមជាច្រើនបានព្យាយាមកប់ចោលនូវអតីតកាលរបស់ខ្លួន ប៉ុន្តែវានៅតែជាអតីតកាលនិងជាអត្តសញ្ញាណរបស់ខ្លួនជានិច្ច។ ប្រជាជនខ្មែរដែលកើតក្រោយរបបខ្មែរក្រហម បានព្យាយាមស្វែងយល់អំពីមូលហេតុដែលបណ្តាលឲ្យសោកនាដកម្មក្នុងអតីតកាលកើតមានឡើង ប្អូនក្មួយទាំងនោះប្រហែលជានៅមានមន្ទិលសង្ស័យថា តើសោកនាដកម្មទាំងនោះបានកើតឡើងពិតមែន ឬយ៉ាងណា។»

ប្រវត្តិវិទូ ដេវីត ហ៊ិក គឺជាអ្នកប្រមែប្រមូលឯកសារខ្មែរក្រហមដំបូងបង្អស់ និងបានបង្កើតគណកម្មការមួយដើម្បីប្រមូល រៀបចំ ថែរក្សា និងចងក្រងឯកសារខ្មែរក្រហមនៅកម្ពុជាក្នុងអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០។ កិច្ចការស្រាវជ្រាវរបស់លោកទៅលើប្រវត្តិសាស្ត្រខ្មែរក្រហម បានបង្ហាញថា ប្រជាជនកម្ពុជាប្រមាណពីមួយលានទៅបីលាននាក់ ក្នុងចំណោមប្រជាជនសរុបប្រាំពីរលាននាក់ត្រូវបានសម្លាប់ ហើយវប្បធម៌ទាំងមូលត្រូវបានបំផ្លិចបំផ្លាញជាប្រព័ន្ធ។ លោក ដេវីដ ហ៊ិក ក៏ដូចជាលោក ឆាំង យុ សព្វថ្ងៃអ្នកទាំងពីរផ្តោតការស្រាវជ្រាវមួយផ្នែកធំនៅក្នុងប្រទេសកូរ៉េខាងជើង និងប្រទេសភូមា។

## ពិព័រណ៍រូបថតបង្ហាញពីរូបសម្តេចហ៊ុនសែន ដែលចាប់ផ្តើមគិតពីគោលនយោបាយឈ្នះ ឈ្នះ

រូបថតសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថ្លែងនៅក្នុងរដ្ឋសភាជាតិ ក្នុងទសវត្សរ៍ឆ្នាំ១៩៩០។ ការជជែកពិភាក្សារបស់សម្តេច គឺបានផ្តោតសំខាន់ទៅលើការផ្តួចផ្តើមគំនិតក្នុងការបង្កើតគោលនយោបាយ ឈ្នះ ឈ្នះ ដែលនាំទៅដល់ការបង្រួបបង្រួមជាតិទាំងមូល រវាងក្រុមខុទ្ទាមផ្តាច់ខ្លួនខ្មែរក្រហម និងរដ្ឋាភិបាលកម្ពុជា ដោយសន្តិភាព និងសន្តិវិធី កាលពីឆ្នាំ១៩៩៨។

ពិព័រណ៍នេះ គឺជាផ្នែកមួយនៃការផ្សារអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជារបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅតាមបណ្តាខេត្តដទៃទៀតនៅក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា។ ឯកឧត្តម នាយឧត្តមសេនីយ៍ ណឹម សុវត្ថិ រំពឹងថា ក្រុមប្រវត្តិសាស្ត្រយោធា នឹងខិតខំពង្រឹងកិច្ចសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា បន្តការសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រខ្មែរក្រហមនេះឲ្យកាន់តែច្បាស់លាស់ជាងមុន ដើម្បីជាចំណេះចេះដឹងរបស់កូនខ្មែរជំនាន់ក្រោយៗទៀត មិនឲ្យភ្លេចពីវិនាសកម្មដ៏ជូរចត់ក្នុងប្រវត្តិសាស្ត្រកម្ពុជា។



សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅប្រទេសស៊ុយអែត ឆ្នាំ១៩៧៩។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




លេខ២៤៦ ខែមិថុនា ឆ្នាំ២០២០

# ជូ ជុនហ៊ិន ប្រជាជនថ្មីជម្លៀសទៅតំបន់៥

## ដកស្រង់ចេញពីចម្លើយសារភាពឯកសារ J00២៥៥

**សុខ ថាវណៃ**



កងចល័តនៅសហករណ៍ ក្នុងស្រុកភ្នំស្រុក តំបន់៥ ភូមិភាគពាយ័ព្យកំពុងជញ្ជូនថ្មយកទៅលាយជាមួយបាយអសម្រាប់សង់ទ្វារទឹក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ជូ ជុនហ៊ិន អាយុ៣៣ឆ្នាំ ភេទប្រុស មានស្រុកកំណើត នៅភូមិចំណោម ឃុំកំពែង ស្រុកព្រែកប្បាស តំបន់៣៣ (ភូមិភាគនិរតី)។ ខ្ញុំគឺជាអតីតគ្រូបង្រៀននៅសាលាបឋមសិក្សាចំណោម។

នៅឆ្នាំ១៩៦០ ខ្ញុំបានចូលរៀននៅសាលាបឋមសិក្សាចំណោម បន្ទាប់មករៀននៅសាលាអនុវិទ្យាល័យព្រៃល្វា។ នៅឆ្នាំ១៩៦៦ ខ្ញុំរៀនដល់ថ្នាក់ទី២ នៅវិទ្យាល័យតាកែវ។

នៅឆ្នាំ១៩៦៧ ខ្ញុំប្រឡងជាប់ធ្វើជាគ្រូបង្រៀន និងរៀនច្បាប់គ្រូនៅមហាវិទ្យាល័យកំពង់កន្ទួត។ រយៈពេលនោះខ្ញុំបានស្នាក់នៅ និងជិតស្និទ្ធជាមួយឈ្មោះ អ៊ុំ សន ដែលជាគ្រូបង្រៀនទីនោះដែរ។ នៅឆ្នាំ១៩៦៨ ខ្ញុំបានទទួលការអប់រំពីឈ្មោះ សន អំពីរបបលោកសេរី គឺប្រជាជនរស់នៅសប្បាយដូចប្រទេសអាមេរិក រីឯរបបកុម្មុយនីសជារបបរឹតត្បិតលើសេរីភាពប្រជាជន ដែលលំបាកដូចប្រទេសចិន។ ក្រោយពីទទួលការអប់រំហើយ ខ្ញុំបានចូលជា សេ.អ៊ី.អា ដោយមានអ្នកខុទេសនាមបញ្ចូលឈ្មោះ ញាន ធូរ៉ាន និងទទួលស្គាល់ដោយឈ្មោះ វង់ សារ៉េត។ ទាំងពីរនាក់នេះគឺជាសាស្ត្រាចារ្យនៅមហាវិទ្យាល័យកំពង់កន្ទួត។ សន ក៏ណែនាំឲ្យខ្ញុំទាក់ទងជាមួយឈ្មោះ ចិល ខេង (អតីតគ្រូបង្រៀន), ស សឿង (អតីតគ្រូបង្រៀន), សុក ហន (អតីតគ្រូបង្រៀន) ដើម្បីរួមធ្វើសកម្មភាពតាមដានចលនាខ្មែរក្រហម នៅសាលាផ្សេងៗទៀត និងកសាងកម្លាំង សេ.អ៊ី.អា។

នៅឆ្នាំ១៩៦៩ ពេលខ្ញុំរៀនច្បាប់គ្រូចប់ហើយ ក៏មកបង្រៀននៅសាលាបឋមសិក្សាចំណោម។ ពេលនោះ សនបានឲ្យខ្ញុំធ្វើការទាក់ទងធ្វើសកម្មភាពតាមដានខ្មែរក្រហមជាមួយឈ្មោះ មិញ ឈើវ (អតីតគ្រូបង្រៀន), សួង ស្រេង (ប្រជាជនថ្មីនៅសហករណ៍ដកពោ), យិន

*លាងឆាយ (អតីតគ្រូបង្រៀន)។ ក្រោយថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ខ្ញុំ, សួង ស្រេង, យិន លាងឆាយ និងឈីវ បានរត់មកនៅភ្នំពេញ។ ខ្ញុំបានជាប់ខ្សែ សេ.អ៊ី.អា ចាស់ជាមួយ អ៊ូ សន ជាមេរបស់ខ្ញុំដដែល។ សន និង មិញ ឈីវ បាននាំខ្ញុំទៅទាក់ទងខ្សែ សេ.អ៊ី.អា ដែលរត់ពីជនបទមកនៅភ្នំពេញដែរ ដែលអ្នកទាំងនោះមានឈ្មោះ អឹម សាយ, កែវ សេថា, ហង់ អឿង ដើម្បីរួមធ្វើសកម្មភាពតាមដានខ្មែរក្រហមនៅក្នុងចំណោមសិស្សនៅសាលាបឋមសិក្សាទួលស្វាយព្រៃ។ ជាមួយគ្នានេះ ខ្ញុំបានធ្វើសកម្មភាពចាប់ខ្មែរក្រហមបានម្នាក់ឈ្មោះ ជា។ នៅក្នុងឆ្នាំ១៩៧០ដដែល អ៊ូ សន និង មិញ ឈីវ នាំខ្ញុំទៅទាក់ទងខ្សែ សេ.អ៊ី.អា ម្នាក់ឈ្មោះ ប៉ែន សូត្រ អតីតពាក់ស័ក្តិ២ (ទាហានចាស់) ដើម្បីឲ្យស្គាល់ទាក់ទងភ្ជាប់ខ្សែ សេ.អ៊ី.អា ក្នុងក្រុងភ្នំពេញ។ បន្ទាប់មក សាវិន បាននាំខ្ញុំឲ្យស្គាល់ ឌុច សំ (អតីតគ្រូបង្រៀន) និង ជី វ៉ិត (អតីតគ្រូបង្រៀន) ដែលជាខ្សែ សេ.អ៊ី.អា ដែរ។ ក្រោយពីទាក់ទងហើយ ខ្ញុំបានចូលរួមធ្វើសកម្មភាពជាមួយ សំ និង វ៉ិត ឃោសនាំប្រជាជនឲ្យស្អប់ខ្មែរក្រហម និងចាប់ខ្មែរក្រហម។*

*នៅឆ្នាំ១៩៧២ ខ្ញុំបានទទួលការចាត់តាំងពី ប៉ែន សូត្រ ឲ្យទាក់ទងខ្សែ សេ.អ៊ី.អា នៅសាលាបឋមសិក្សាបឹងត្របែកឈ្មោះ ឡាច សារុន។ បន្ទាប់មក ខ្ញុំបានទៅទាក់ទងជាមួយ ឡាច សាវិន ធ្វើសកម្មភាពចាប់ខ្មែរក្រហមបានម្នាក់ឈ្មោះ គីម នៅបឹងត្របែក។ ឆ្នាំ១៩៧៣ ប៉ែន សូត្រ បានចាត់តាំងខ្សែ សេ.អ៊ី.អា ទាំងអស់ឲ្យធ្វើជាមេ១០ខ្នង ទៅ៥០ខ្នងនៅក្នុងសង្កាត់លេខ១១ ដើម្បីឲ្យខ្សែ សេ.អ៊ី.អា ទាំងអស់ស្រួលធ្វើសកម្មភាពតាមដានខ្មែរក្រហម។ ក្រោយទទួលការចាត់តាំង និងទទួលផែនការហើយ ខ្ញុំបានមកធ្វើមេ១០ខ្នងនៅសង្កាត់លេខ១១ ក្រុងភ្នំពេញ។ ខ្ញុំបានឃោសនាឲ្យប្រជាជនស្អប់ខ្មែរក្រហម និងចាប់ខ្មែរក្រហមបានពីរនាក់ឈ្មោះតូច និង ថុនដាន នៅក្នុងសង្កាត់លេខ១១ ហើយកសាងកម្លាំង សេ.អ៊ី.អា បាន៤នាក់ មានឈ្មោះ ព្រុំ ឆែម (អតីតពេទ្យទាហាន), សួស ឈន (ប្រជាជនថ្មីនៅសហករណ៍ប៉ោយព្រីង), វ៉ិត ទឹម (ប្រជាជនថ្មីសហករណ៍ដកគោ), ទី សាគុណ (ប្រជាជនថ្មីសហករណ៍គិរីវ៉ិន)។ ពេលកសាងកម្លាំងទាំងនេះបានហើយ ប៉ែន សូត្រ បាននាំខ្ញុំឲ្យស្គាល់ និងទាក់ទងជាមួយខ្សែ សេ.អ៊ី.អា ម្នាក់ទៀតមានឈ្មោះ ជិន កែ (អតីតអធិការបឋមសិក្សាក្រុងតាកែវ)។*

*នៅខែមេសា ឆ្នាំ១៩៧៥ ក្រោយពីដឹងសភាពការណ៍កងទ័ពខ្មែរក្រហមវាយរំដោះជុំវិញភ្នំពេញហើយ ក្នុងអំឡុងពេលនោះខ្ញុំទទួលផែនកាពី ប៉ែន សូត្រ ឲ្យខិតខំកសាងកម្លាំង សេ.អ៊ី.អា បន្ថែម និងចាត់តាំងកម្លាំង សេ.អ៊ី.អា ឲ្យទៅលាក់ខ្លួនតាមផ្ទាំងថ្ម ចាំបាញ់យោធាខ្មែរក្រហមពេលចូលមកក្រុងភ្នំពេញ និងឲ្យលាក់អាវុធខ្លីគ្រាប់បែកទុកសម្លាប់ខ្មែរក្រហម។ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ មុនជម្លៀសមួយថ្ងៃ ខ្ញុំបានទទួលផែនការពី ប៉ែន សូត្រ ឲ្យកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនថ្មី និងបន្តធ្វើការទាក់ទងខ្សែ សេ.អ៊ី.អា ឲ្យជាប់។ ថ្ងៃទី១៨ មេសា អង្គការបានជម្លៀសខ្ញុំចេញពីភ្នំពេញ ហើយក្នុងអំឡុងពេលនោះខ្ញុំ ក៏បានទៅភ្ជាប់ខ្សែ សេ.អ៊ី.អា ចាស់ដែលមកជាមួយមានឈ្មោះ ស៊ួស ឈន និង ទី គុណ។ ខ្ញុំបានទៅនៅភូមិចំណោម ឃុំកំពែងជាស្រុកកំណើតរបស់ខ្ញុំ។ ខ្ញុំក៏បានទៅភ្ជាប់ខ្សែ សេ.អ៊ី.អា ចាស់ផ្សេងទៀតមានឈ្មោះ សួង ស្រេង, ហង់ អឿង និង កែវ សេថា ក្រៅពីឈ្មោះទាំងបីនាក់ខាងលើនេះ ខ្ញុំដាច់ការទាក់ទងទាំងអស់។ ក្នុងពេលភ្ជាប់ទំនាក់ទំនងឡើងវិញនេះ អឿង គឺជាអ្នកដឹកនាំកម្លាំង សេ.អ៊ី.អា នេះ ហើយខ្ញុំគឺជាអ្នកទទួលផែនការពី អឿង ឲ្យកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនថ្មីឲ្យបំភ្លៃមាគ៌ាបង្កបង្កើតផលរបស់អង្គការឃោសនាឲ្យប្រជាជនថ្មីស្អប់អង្គការ និងស្រាវជ្រាវរកខ្សែ សេ.អ៊ី.អា។ នៅខែឧសភា ឆ្នាំ១៩៧៥ ខ្ញុំនិង ហង់ អឿង បានធ្វើសកម្ម-ភាពកសាងកម្លាំង សេ.អ៊ី.អា ក្នុងចំណោមប្រជាជនចាស់ពីរនាក់គឺឈ្មោះ ហេង និង តាំង ឆេង។ ពេលកសាងបានហើយ អង្គការបានចាត់តាំងខ្ញុំ និងហង់ អឿង ឲ្យទៅលើកទំនប់ទឹកនៅកំពង់ចក ក្នុងឃុំព្រៃល្វា ស្រុក៤៥ ។ អំឡុងពេលនោះខ្ញុំ និង ហង់ អឿង បានស្រាវជ្រាវរកឃើញខ្សែ សេ.អ៊ី.អា ចាស់ម្នាក់គឺ មិញ ឈីវ។ ខ្ញុំ និង អឿង បានទទួលផែនការពី ឈីវ ឲ្យកសាងកម្លាំង សេ.អ៊ី.អា បំផុសឲ្យប្រជាជនថ្មីស្អប់អង្គការ និងធ្វើឲ្យមានការច្របូកច្របល់។*

*នៅខែកក្កដា និងខែសីហា ឆ្នាំ១៩៧៥ ខ្ញុំនិង អឿង រួមជាមួយ តាំ អែ និង ស៊ូ ក្រវ៉ាន់ បានបំផុសប្រជាជនថ្មីឲ្យមានការច្របូកច្របល់ក្នុងភូមិចំណោម ដោយបានបំផុសថាអង្គការនៅក្នុងភូមិនេះតឹងរ៉ឹងណាស់ ហើយបង្ខំឲ្យធ្វើការច្រើន។ បើស៊ី មិនដែលឆ្អែតទេ ប៉ុន្តែបើភូមិដទៃក្រៅពីភូមិចំណោមនេះធ្វើការងារតិច ហើយស៊ីបានឆ្អែតទៀតផង។ ក្នុងពេលនោះដែរ ខ្ញុំបានទទួលផែនការពី អឿង ធ្វើឲ្យស្ទះក្នុងការកសាងប្រទេសរបស់អង្គការ ដោយពេលស្ទូងបានបំផ្លាញសំណាប និងកសាងកម្លាំង សេ.អ៊ី.អា។ ក្រោយពេលទទួលផែនការហើយ ខ្ញុំ និង ហេង បានបំផ្លាញសំណាបអស់៦០កណ្តាប់ និងនង្គ័លអស់៥។ នៅខែកញ្ញា និងខែតុលា*







*កងចល័តនៅសហករណ៍ ក្នុងស្រុកមង្គលបូរី ភូមិភាគពាយ័ព្យ កំពុងសង់ទ្វារទឹក។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ឆ្នាំ១៩៧៥ ខ្ញុំរួមធ្វើសកម្មភាពជាមួយ ហេង និង ហង់ អឿង កសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់គឺ មុំ ស៊ិន និង ទូច មុិល។ ពេលកសាងកម្លាំងបបានហើយ អង្គការក៏បានចាត់តាំងខ្ញុំ និង មុំ ស៊ិន ព្រមទាំង ហេងឲ្យទៅដាំដំឡូង។*

*នៅខែវិច្ឆិកា ឆ្នាំ១៩៧៥ អង្គការជម្លៀសខ្ញុំពីភូមិចំណោមឲ្យទៅនៅខាងបាត់ដំបងវិញ។ នៅពេលនោះខ្សែ សេ.អ៊ី.អា របស់ខ្ញុំ ក៏ត្រូវបានអង្គការជម្លៀសមកខេត្តបាត់ដំបងដែរ ដូច្នេះហើយខ្ញុំនៅជាប់ខ្សែដដែល។ ក្រោយពេលជម្លៀស ខ្ញុំបានទៅនៅក្នុងសហករណ៍គោកលុន ឃុំទានកាំ ស្រុកព្រះនេត្រព្រះ តំបន់៥។ ខ្ញុំបានជាប់ខ្សែ សេ.អ៊ី.អា ចាស់ឈ្មោះ ជិន កែ ហើយ កែ បាននាំខ្ញុំឲ្យស្គាល់ និងធ្វើសកម្មភាពជាមួយឈ្មោះ សុក សាមិត, នូ យុន។ ជាមួយគ្នានេះដែរ ខ្ញុំបានទទួលផែនការពី ជិន កែ ឲ្យស៊ើបរកខ្សែ សេ.អ៊ី.អា ចាស់ដើម្បីទាក់ទងធ្វើសកម្មភាពបំផ្លាញក្នុងសហករណ៍តាមរយៈភារកិច្ចអង្គការឲ្យធ្វើដោយបំផុសប្រជាជនថ្មីឲ្យប្រឆាំងរបបសមូហភាពរបស់អង្គការ និងកសាងកម្លាំង សេ.អ៊ី.អា។*

*នៅខែមករា ឆ្នាំ១៩៧៦ ពេលទទួលផែនការហើយ ជិន កែ បានចាត់តាំងខ្ញុំឲ្យធ្វើសកម្មភាពជាមួយខ្សែ សេ.អ៊ី.អា ចាស់មានឈ្មោះ សាមិត និង នូ យុន។ យើងកសាងកម្លាំង សេ.អ៊ី.អា បានបីនាក់គឺ សុទ្ធ, ណែក, គីឈៀង លី ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៦ ប្រធានសហករណ៍គោកលុនបានចាត់តាំងខ្ញុំឲ្យទៅលើកទំនប់ទឹកនៅវាលដំបូកបី ក្នុងឃុំទានកាំ។ អំឡុងពេលនោះ ខ្ញុំបានទាក់ទងជាប់ជាមួយ ហង់ អឿង ដែលមកលើកទំនប់ដែរ។ នៅខែមិថុនា ឆ្នាំ១៩៧៦ ខ្ញុំបានមកនៅក្នុងសហករណ៍គោកលុនវិញ ហើយបានទទួលផែនការពី ឡេង និង ជិន កែ ម្តងទៀតឲ្យលួចស្រូវក្នុងសហករណ៍លាក់ទុកត្រៀមសម្រាប់បម្រើផែនការរដ្ឋប្រហារវាយយកខេត្តបាត់ដំបងឲ្យពង្រឹងការទាក់ទងខ្សែ សេ.អ៊ី.អា នៅខាងមូលដ្ឋានចាស់ បំផុសប្រជាជនថ្មីឲ្យរត់ចូលសៀម និងបំផុសឲ្យមានការច្របូកច្របល់ក្នុងសហករណ៍។ ក្រោយពេលទទួលផែនការហើយ ឡេង បាននាំខ្ញុំទៅជួប ឆោម អនុប្រធានសហករណ៍គោកលុន ដើម្បីទាក់ទងធ្វើសកម្មភាព ហើយជាមួយគ្នានេះ ខ្ញុំ និង ឆោម ក៏បានបំផុសប្រជាជនថ្មីឲ្យរត់ទៅសៀមបានពីរនាក់។ នៅខែកក្កដា និង ខែសីហា ឆ្នាំ១៩៧៦ ឆោមបាននាំខ្ញុំឲ្យស្គាល់ និងទាក់ទងឈ្មោះ ស ប្រធានឃុំទានកាំ ។ បន្ទាប់មក ខ្ញុំបានទាក់ទងឈ្មោះ ស៊ុំ និង ធី ទៀត។ នៅពេលទាក់ទងហើយ ខ្ញុំបានធ្វើសកម្មភាពរួមជាមួយអ្នកទាំងពីរដោយបំផុសប្រជាជនថ្មីឲ្យរត់ចូលសៀមអស់៧គ្រួសារ ដោយបំផុសថានៅក្នុងសហករណ៍នេះលែងចាយលុយ បើលក់ដូរអ្វីក៏មិនបាន មិនដូចទៅប្រទេសសៀមទេ ប្រជាជនអាចរកស៊ីលក់ដូរអ្វីបានតាមចិត្ត។ ក្រៅពីនេះ ខ្ញុំបានទាក់ទងជាមួយ វ៉ាន និង អឿង ធ្វើសកម្មភាពបង្ហូតទឹកឲ្យលិចសន្ទូងទើបនឹងស្ទូងហើយអស់ចំនួនពីរហិកតា។*

*នៅខែមករា និងខែមីនា ឆ្នាំ១៩៧៧ ខ្ញុំបានទទួលផែនការពី ឡេង ម្តងទៀតឲ្យកសាងកម្លាំង សេ.អ៊ី.អា បន្ថែមដើម្បីទុកបម្រើផែនការ និងឲ្យលួចស្រូវអង្គការក្នុងសហករណ៍ដើម្បីត្រៀមទុក។ ពេលទទួលផែនការហើយខ្ញុំកសាងកម្លាំង សេ.អ៊ី.អា បានពីរនាក់ទៀតគឺ ចក់ និង ញឹម មុន។ ក្រៅពីនេះ ឆោមឲ្យខ្ញុំទៅទាក់ទងជាមួយ វ៉ាន, ញយ និង អឿង ដើម្បីរៀបចំកម្លាំង។ មកដល់ខែកក្កដា ឆ្នាំ១៩៧៧ អង្គការចាប់ខ្សែរបស់ខ្ញុំមានឈ្មោះ ម៉ោង, សំអាត, ស, ឡេង ដូច្នេះខ្ញុំក៏បានទាក់ទងទៅឈ្មោះ ម៉ា និង ខុ ដើម្បីរៀបចំរកផ្លូវរត់ទៅសៀម។ ខ្ញុំក៏បានដើរទាក់ទងបបួលខ្សែក្បត់នៅតាមសហករណ៍គោកលុន សហករណ៍គីរីវ៉ិន បម្រុងរត់ចូលសៀមដែលឈ្មោះ ឈៀង លី, អ៊ូ ផល, ហង់ អឿង និង ទី សាគុណ។ ខ្ញុំនៅក្នុងសហករណ៍គោកលុនរហូតដល់ខែសីហា ឆ្នាំ១៩៧៧ ទើបអង្គការ ចាប់ខ្លួនខ្ញុំ។*

*កំណត់ចំណាំ ៖ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំ និងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះ យើងមិនអាចសន្និដ្ឋានបានថា ចម្លើយរបស់ ជូ ជុនហ៊ន ពិតប្រាកដណានោះទេ។*

# វិចិត្រសាលសិល្បៈ សហសម័យវិទ្យាស្ថានស្លឹករឹត









វិចិត្រសាលសិល្បៈសហសម័យវិទ្យាស្ថាន ស្លឹករឹត ជាទីតាំងមួយដើរតួនាទីជាកន្លែងអប់រំ បណ្តុះបណ្តាល និងលើកកម្ពស់ការអប់រំពីប្រវត្តិសាស្ត្រ និងកេរដំណែល ដែលបន្សល់ទុកពីរបបខ្មែរក្រហម ព្រមទាំងជាកន្លែង ដែលដាក់បង្ហាញពីសិល្បៈ និងវប្បធម៌ តាមរយៈ ការតាំងពិព័រណ៍ការចាក់បញ្ចាំងខ្សែភាពយន្តឯកសារ និង ការធ្វើបទបង្ហាញរបស់វាគ្មិននានា។ វិចិត្រសាលសិល្បៈ សហសម័យវិទ្យាស្ថានស្លឹករឹត រួមចំណែកដល់ការលើក កម្ពស់ និងគាំទ្រដល់វិចិត្រករកម្ពុជាទាំងអស់ ដោយផ្តល់ ជូននូវបរិវេណខាងក្នុងបន្ទប់ធំនៃអគារចំណាស់ កសាងឡើងក្នុងរជ្ជកាលបារាំង សម្រាប់ការដាក់តាំង ពិព័រណ៍ពីកិច្ចការសិល្បៈរបស់ខ្លួន។

សម្រាប់សិស្ស-និស្សិត អ្នកស្រាវជ្រាវ និង សាធារណជនទូទៅ ដែលមានចំណាប់អារម្មណ៍ មកទស្សនានៅមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-CAM) និងវិចិត្រសាលសិល្បៈសហសម័យ វិទ្យាស្ថានស្លឹករឹត, សូមទាក់ទងមកកាន់ **សាន ចិន្តា** អ្នកសម្របសម្រួល តាមរយៈ ទូរសព្ទលេខ ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖ truthchenda.s@dccam.org

សូមអរគុណ!

# ខ្ញុំមានជីវិតរស់ ដោយសារលួចដំឡូងមីហូប

ហូ ថុនា



ឡូត សៀ សព្វថ្ងៃគឺជាប្រជាជនប្រកបរបរធ្វើស្រែ និងចិញ្ចឹមត្រី នៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំមានជីវិតរស់នៅមកដល់សព្វថ្ងៃដោយសារតែ បានលួចដំឡូងមី ទោះបីជាដឹងថាប្រសិនបើខ្មែរក្រហម ចាប់បានច្បាស់ជាទទួលរងនូវទារុណកម្ម ឬអាចយក សម្លាប់ចោលយ៉ាងណាក៏ដោយ។

ខ្ញុំឈ្មោះ ឡូត សៀ អាយុ៥៩ឆ្នាំ រស់នៅភូមិដើង វត្តឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះខេត្តបន្ទាយមាន ជ័យ។ កាលពីកុមារភាពខ្ញុំរៀនបានដល់ថ្នាក់ទី១១សង្គម ចាស់ នៅសាលាបឋមសិក្សាព្រះនេត្រព្រះ។ ខ្ញុំឈប់រៀន នៅឆ្នាំ១៩៧៥ ដោយសារស្រុកទេសកើតមានភាពវឹក វរ។ កាលនោះ នៅក្នុងភូមិខ្ញុំមានកងទ័ព លន់ នល់ ប្រយុទ្ធ តទល់គ្នាជាមួយកងទ័ពខ្មែរក្រហម។ ប្រជាជនក្នុងភូមិ របស់ខ្ញុំមានការភិតភ័យយ៉ាងខ្លាំងក៏បាននាំគ្នារត់គេចខ្លួន ទៅទីដែលមានសុវត្ថិភាព ចំណែកឯគ្រួសារខ្ញុំបាននាំគ្នា ពួននៅក្នុងជង្រុកស្រូវ។ កងទ័ព លន់ នល់ បានទម្លាក់ គ្រាប់បែកនៅតាមជើងភ្នំស្រេះ និងភ្នំកូនដំរី។ រហូតដល់ ខែមេសា ឆ្នាំ១៩៧៥ កងទ័ពខ្មែរក្រហមទទួលបានជ័យ ជម្នះលើកងទ័ព នល់ នល់ ទាំងស្រុង។ ខ្មែរក្រហមបានចាប់ ផ្តើមជម្លៀសគ្រួសារខ្ញុំ និងប្រជាជនដែលរស់នៅភូមិដើង វត្តឲ្យទៅរស់នៅភូមិស្រេះខាងកើត។ កាលណោះខ្ញុំមាន អាយុប្រហែល១១ឆ្នាំ ដូច្នេះខ្ញុំមិនសូវយល់ពីគោល នយោបាយរបស់ខ្មែរក្រហមទេ ខ្ញុំដឹងត្រឹមថាខ្មែរក្រហម ឲ្យធ្វើអ្វីខ្ញុំនឹងធ្វើតាម ព្រោះខ្ញុំខ្លាចខ្មែរក្រហម។ ខ្មែរក្រហម ចាប់ផ្តើមស្រាវជ្រាវអ្នកដែលជាប់និន្នាការក្នុងរបបចាស់ ដូចជា គ្រូបង្រៀន ទាហាន មន្ត្រីរាជការ នាយទុន ពួកសក្តិភូមិ ដើម្បីយកទៅសម្លាប់។ ការស្រាវជ្រាវនេះ បានប្រើរយៈពេលកន្លះខែ។ ម្តាយខ្ញុំបាននិយាយប្រាប់ ខ្ញុំថា គ្រួសារយើងសំណាងហើយដែលខ្មែរក្រហម បញ្ឈប់ការស្រាវជ្រាវតទៅទៀត ព្រោះខ្មែរក្រហមបាន ដឹងថា គ្រួសារយើងគឺជានាយទុន។ ខ្មែរក្រហមបាន ស្រាវជ្រាវឃើញមេឃុំ ដែលបម្រើការក្នុងរបបចាស់ ហើយបានយកទៅសម្លាប់ចោលទាំងគ្រួសារ។

ខ្មែរក្រហមបានបន្តការជម្លៀសគ្រួសារខ្ញុំឲ្យទៅរស់នៅ ភូមិប៉ោយតាប៉ែន។ កាលនោះខ្ញុំនៅកងកុមារ។ ខ្ញុំត្រូវបាន ខ្មែរក្រហមបញ្ជូនឲ្យកាត់ទន្រ្ទានខែត្រ១៥គីឡូក្រោមក្នុង



ចម្ការដំឡូងមីនៅជាប់ជើងភ្នំព្រះនេត្រព្រះ ស្ថិតនៅក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

មួយថ្ងៃ ដើម្បីចិញ្ចាំធ្វើដីដាក់ស្រែ។ ប្រសិនបើខ្ញុំធ្វើការមិនគ្រប់ផែនការរបស់អង្គការនោះទេ ខ្ញុំក៏មិនអាចទទួលបានរបបអាហូបដែរ។ នៅពេលនោះរបបអាហាររបស់ខ្ញុំគឺទទួលបានបាយ។

មកដល់ឆ្នាំ១៩៧៧ នៅក្នុងភូមិឃុំ ស្រុកព្រះនេត្រព្រះ នៃតំបន់៥ ត្រូវបានផ្លាស់ប្តូរអ្នកគ្រប់គ្រងថ្មី គឺអ្នកគ្រប់គ្រងមកពីភូមិភាគនិរតី ហើយការរឹតត្បិតរបបអាហារចាប់ផ្តើមដែរ។ ខ្ញុំ ទទួលបានបបរសរាវស្ទើរតែគ្មានគ្រាប់អង្ករ ហូបលាយជាមួយអំបិល២ទៅ៣គ្រាប់ប៉ុណ្ណោះ។ រាងកាយខ្ញុំចាប់ផ្តើមស្គមស្គាំង និងគ្មានកម្លាំងសូម្បីតែដើរទៅមុខស្ទើរតែមិនរួច។ ដោយសារតែការស្រេកឃ្លាន ខ្ញុំ និងកុមារដទៃទៀតបានទៅលួចដំឡូងមីនៅចម្ការខាងជើងភូមិតាប៉ែន។ ខ្ញុំគឺជាអ្នកចូលលួចដកដំឡូងមី រីឯកុមារដទៃទៀតឡើងដើមឈើចាំឃ្លាំមើលឈ្លបខ្មែរក្រហមក្រែងលោមកទាន់។ នៅពេលដែលដុតដំឡូងមីហូប គឺខ្ញុំត្រូវមានការប្រុងប្រយ័ត្នដែរ ដោយចាត់តាំងឲ្យមានអ្នកចាំឃ្លាំមើលឈ្លបខ្មែរក្រហមពីលើដើមឈើ ដូចពេលលួចដំឡូងមីដែរ។ បន្ទាប់ពីដំឡូងមីឆ្អិនយើងបានចែកគ្នាហូប ក្នុងម្នាក់ទទួលបាន ២ទៅ ៣មើម។ សព្វថ្ងៃនេះនៅពេលដែលខ្ញុំហូបដំឡូងមី ខ្ញុំតែងតែនឹកស្រមៃដល់អតីតកាលដែលខ្ញុំធ្លាប់បានជួបប្រទះនៅអំឡុងពេលរបបខ្មែរក្រហម ព្រោះប្រសិនបើគ្មានដំឡូងមីទេ ខ្ញុំក៏មិនអាចមានជីវិតរស់មកដល់សព្វថ្ងៃនេះដែរ។

នៅឆ្នាំ១៩៧៨ បងប្រុសខ្ញុំ ឈ្មោះ សួយ បានយកខ្ញុំ ទៅនៅជាមួយគាត់នៅភូមិពករបុន ក្នុងស្រុកភ្នំស្រុក ព្រោះគាត់ឃើញខ្ញុំស្គមខ្លាំងពេក។ បងប្រុសខ្ញុំគឺជាអតីតយោធាខ្មែរក្រហមនៅភូមិភាគពាយ័ព្យ។ នៅពេលដែលខ្ញុំទៅដល់ស្រុកភ្នំស្រុក ខ្ញុំមានតួនាទីឃ្វាលគោ។ នៅទីនោះ ខ្ញុំហូបឆ្អែតជាងនៅភូមិតាប៉ែន នៃតំបន់៥ ទោះបីខ្ញុំទទួលបានបបរក៏ដោយ។ នៅតំបន់៥ ប្រជាជនធ្វើស្រែទទួលបានទិន្នផលស្រូវយ៉ាងច្រើន ប៉ុន្តែប្រជាជននៅតែអត់ឃ្លាន បើធៀបជាមួយតំបន់ផ្សេងទៀតនៃ





ភូមិភាគពាយ័ព្យ។ ប្រជាជននៅតំបន់៥ បានស្លាប់យ៉ាងច្រើនដោយសារអត់អាហារបរិភោគ។

ខ្ញុំបានឃ្វាលគោនៅស្រុកភ្នំស្រុករហូតដល់ខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ខ្ញុំក៏បានដឹកគោដែលខ្ញុំឃ្វាលត្រឡប់មកភូមិខ្ញុំវិញ។ នៅពេលដែលខ្ញុំមកដល់ផ្ទះ ផ្ទះរបស់ខ្ញុំ ត្រូវបានខ្មែរក្រហមរុះរើអស់ទៅហើយ។

នៅឆ្នាំ១៩៨១ ខ្ញុំបានចាប់ផ្តើមរៀនសូត្រនៅសាលាវត្តពោធិ៍កែវព្រះនេត្រព្រះ។ ដំបូង គ្រូរបស់ខ្ញុំគឺជាប្រជាជនថ្មីដែលត្រូវបានខ្មែរក្រហមជម្លៀសមកពីទីក្រុងភ្នំពេញ។ គាត់គឺជាអតីតនិស្សិតម្នាក់។ ខ្ញុំរៀននៅសាលាវត្តអស់រយៈពេល២ឆ្នាំ។ ក្រោយមកខ្ញុំបានមករៀនថ្នាក់ទី៤ នៅសាលាព្រះនេត្រព្រះ។ រហូតដល់ឆ្នាំ១៩៨៥ ខ្ញុំត្រូវប្រឡងចូលថ្នាក់ទី៥ ដែលស្មើនឹងថ្នាក់ឌីប្លូមសព្វថ្ងៃ នៅវិទ្យាល័យជប់វារី ដែលស្ថិតនៅទីរួមស្រុកព្រះនេត្រព្រះ។ ក្នុងឆ្នាំនោះដែរ ខ្ញុំមិនបានចូលរួមប្រឡងនោះទេ ព្រោះមានពាក្យចចាមអារ៉ាមតៗគ្នាថា យួនដាំតែអុង ដែលមានន័យថា យួនដឹករណ្តៅកប់ខ្លួនខ្មែរសល់ត្រឹមតែក្បាល រួចយកក្បាលធ្វើជាមុំចង្ក្រាន។ ពុកម្តាយខ្ញុំ និងបក្ខពួក ៥នាក់ទៀត បាននាំគ្នារត់ចូលព្រៃក្នុងភូមិស្វាយស ស្ថិតនៅឃុំតាវ៉ង ស្រុកភ្នំស្រុក ដើម្បីចូលធ្វើជាទាហានខាងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរ ដែលមានមូលដ្ឋាននៅតាមបណ្តោយព្រំដែនខ្មែរ-ថៃ ដឹកនាំដោយមេបញ្ជាការឈ្មោះ វ៉ូយ បានរយៈពេលជាងមួយឆ្នាំ។ ក្រោយមកខ្ញុំបានវិលត្រឡប់មកភូមិវិញ និងរៀបការប្រពន្ធនៅឆ្នាំ១៩៨៧។ ក្នុងឆ្នាំនោះដែរ ខ្ញុំក៏បានស្ម័គ្រចិត្តចូលធ្វើជាសេនាជនឃុំព្រះនេត្រព្រះ ដើម្បីការពារសន្តិសុខជូនប្រជាជនក្នុងភូមិឃុំឲ្យគេចផុតពីការធ្វើបាបរបស់កងទ័ពខ្មែរក្រហម។ ខ្ញុំបានស្នើសុំប្រធានសេនាជន ឈ្មោះ រឿន ធ្វើការងារនេះ។ ខ្ញុំមានតួនាទីដើរយាមល្បាតពីភូមិទៅភូមិមួយជារៀងរាល់យប់។ ខ្ញុំបានប្រើប្រាស់កាំភ្លើងអាកាស្ទេបត់ដើម្បីការពារខ្លួន។ មានយប់ខ្លះខ្ញុំបានប្រទះឃើញកងទ័ពខ្មែរក្រហមដើរតាមភូមិ ខ្ញុំនិងបក្ខពួកជាងដប់នាក់ទៀត បានប្រយុទ្ធតទល់ជាមួយខ្មែរក្រហម។



គ្រឿងឥស្សរិយយស ដែល ឡុត សៀ ទទួលបានពីរដ្ឋាភិបាលនៅពេលដែលគាត់ធ្វើជាប្រធានសេនាជនឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

រហូតដល់ឆ្នាំ១៩៩៣ ប្រធានសេនាជនឃុំបានលាឈប់ពីតំណែង ពេលនោះមេឃុំឈ្មោះ តាហាំ ក៏បានចាត់តាំងខ្ញុំធ្វើជាប្រធានសេនាជនឃុំ ដែលដឹកនាំសមាជិកក្រុមចំនួន៤៥នាក់។ ខ្ញុំ និងសមាជិកក្រុមទៅប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមនៅភូមិកំពង់ក្រសាំង ភូមិបែកអង្ករ ថ្មដប់ និងដូនឡឹក ដែលជាតំបន់លិចទឹក។ ការប្រយុទ្ធគ្នានេះកងកម្លាំងនគរបាលខេត្ត និងក្រុមសេនាជនបានសហការគ្នាយ៉ាងល្អ។ នៅពេលដែលភាគីខាងស្រុកឬខេត្តដឹងដំណឹងថា ខ្មែរក្រហមនៅទីណាតែងតែគេអូប្រាប់មកខាងសេនាជន ដើម្បីចូលរួមសហការគ្នាប្រយុទ្ធ។ ខ្ញុំមិនសូវបាននៅរួមរស់ជាមួយប្រពន្ធកូនខ្ញុំទេ ព្រោះខ្ញុំត្រូវចេញទៅវាយកម្លាំងខ្មែរក្រហមដែលនៅសេសសល់។ សព្វថ្ងៃ ខ្ញុំមិនចង់ឃើញខ្មែរបែកបាក់គ្នាតទៅទៀតទេ គឺខ្ញុំចង់ឃើញខ្មែររួបរួមគ្នាដើម្បីកសាងប្រទេសជាតិ ។

# ខ្ញុំរលូតកូនដោយសារវែកដី

អ៊ុន សុជាទី



ក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាជួបជាមួយអាជ្ញាធរឃុំ ស្ថិតក្នុងស្រុករំដួល ខេត្តស្វាយរៀង ដើម្បីសាកសួរព័ត៌មានទាក់ទងនឹងប្រជាជនដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម និងប្រជាជនដែលមានបញ្ហាសុខភាពដើម្បីសម្ភាសន៍។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ៊ឹម សំអ៊ិន ភេទស្រី អាយុ៦៥ឆ្នាំ រស់នៅភូមិធ្លក ឃុំធ្លក ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ សំអ៊ិន មានបងប្អូនចំនួន៦នាក់ ស្រីចំនួន៣នាក់ និងប្រុសចំនួន៣នាក់។ សព្វថ្ងៃនេះ សំអ៊ិន រស់នៅជាមួយកូនស្រីទី៤ ក្នុងចំណោមកូនរបស់គាត់ទាំង៧នាក់។ ប្តីរបស់គាត់បានស្លាប់អស់រយៈពេលប្រហែល៦ឆ្នាំកន្លងមកហើយ។ សំអ៊ិន ប្រកបមុខរបរធ្វើស្រែ ដាំដំណាំនៅក្បែរៗផ្ទះ និងមើលថែរក្សាចៅចំនួន២នាក់។ កូនៗរបស់សំអ៊ិន គឺជាអ្នកធ្វើការរោងចក្រ។ កូនៗខ្លះទៅធ្វើការនៅឆ្ងាយពីផ្ទះ ហើយស្នាក់នៅទីនោះ រីឯកូនៗខ្លះទៀតធ្វើការរោងចក្រនៅក្បែរផ្ទះ និងត្រឡប់មកផ្ទះវិញនៅពេលយប់។

រំឭកដល់រឿងរ៉ាវនៅក្នុងរបបខ្មែរក្រហម សំអ៊ិនបាននិយាយរៀបរាប់ថា នឹកឃើញដល់រឿងនោះ ខ្ញុំស្ទើរតែមិនអាចនិយាយចេញមកក្រៅបាន។ ខ្ញុំបានរៀបការនៅក្នុងឆ្នាំ១៩៧៥ ហើយរយៈពេល៦ខែក្រោយមកខ្ញុំមានកូនទី១។ ខ្មែរក្រហមប្រើឲ្យខ្ញុំទៅជីកអាង និងឲ្យខ្ញុំវែកដីចម្ងាយប្រហែល ២០០ម៉ែត្រពីកន្លែងជីកនោះ។ នៅពេលនោះ កូនរបស់ខ្ញុំដែលនៅក្នុងពោះមានអាយុត្រឹមតែពីរខែតែប៉ុណ្ណោះ។ នាល្ងាចថ្ងៃមួយពេលត្រឡប់មកពីធ្វើការងារវិញ ខ្ញុំធ្លាក់ឈាមយ៉ាងច្រើន។ ប្តីរបស់ខ្ញុំភិតភ័យយ៉ាងខ្លាំង ហើយក៏រត់ទៅហៅឆ្មបភូមិមកជួយសង្គ្រោះជីវិតខ្ញុំ។ គាត់គឺជាឆ្មបបុរាណដែលចេះវិជ្ជាឆ្មបនេះតៗគ្នា និងគ្មានសម្ភារពេទ្យប្រើប្រាស់ឡើយ។ ឆ្មបនោះប្រាប់ខ្ញុំថា ដោយសារតែខ្ញុំធ្វើការងារធ្ងន់ពេក ទើបធ្វើឲ្យខ្ញុំធ្លាក់ឈាមច្រើនរហូតដល់រលូតកូន។ ខ្ញុំភ័យខ្លាចណាស់ ព្រោះខ្ញុំទើបតែមានកូនដំបូង។ ខ្ញុំយំយ៉ាងខ្លាំងដោយសារតែឈឺចាប់ពេក ថែមទាំងខ្លាចឈាមដែលហូរធ្លាក់មកយ៉ាងច្រើនទៀត។ នឹកដល់រឿងនោះ ខ្ញុំស្រណោះកូនណាស់។ កូនខ្ញុំស្លាប់ដោយមិនទាន់ដឹងថាជាស្រីឬក៏ប្រុសផង។ ខ្ញុំពិតជាសោកស្តាយខ្លាំងណាស់ដែលមិនបានឃើញមុខកូន។ ខ្ញុំក៏មិនធ្លាប់សង្ឃឹមថាខ្ញុំនឹងមានជីវិតរស់ផុតពីយប់នោះដែរ ប៉ុន្តែខ្ញុំសំណាងល្អ ដែលអាចឆ្លងកាត់រឿងរ៉ាវជាច្រើននិងអាចកសាងគ្រួសារឡើងវិញរហូតដល់សព្វថ្ងៃនេះ។ បន្ទាប់ពីឆ្មបជួយជីវិតខ្ញុំបាន ប្តីរបស់ខ្ញុំបានរកខសមកបង្កាត់ភ្លើងអាំងឲ្យខ្ញុំនៅក្នុងយប់នោះ។ កាលពីសម័យនោះ មនុស្សស្រីដែលសម្រាលកូនរួច ឬរលូតកូន ដែលយើងតែងតែហៅថាសរសៃខ្ចីនោះ ត្រូវដេកឆ្អើរភ្លើងឲ្យឆ្អិនសរសៃរយៈពេលប្រហែលមួយសប្តាហ៍សិន ហើយថ្នមខ្លួនណាស់ព្រោះខ្លាចឈឺ ប៉ុន្តែខ្ញុំមិនដូច្នោះទេ។ លុះព្រឹកឡើងខ្ញុំបានទៅសុំអនុញ្ញាតមេកងដើម្បីឈប់សម្រាកពីការងារដោយប្រាប់ថា «មិត្តបង ខ្ញុំស្នើសុំ សម្រាកអាំងភ្លើងសិនព្រោះខ្ញុំទើបតែរលូតកូនយប់មិញនេះ» ប៉ុន្តែមេកងមិនព្រមឲ្យខ្ញុំឈប់សម្រាកទេ។ មេកងប្រាប់ខ្ញុំថា «គេគ្រប់គ្នាទៅធ្វើការងារនៅក្រៅផ្ទះ ដូច្នេះមិត្តឯងមិនអាចសម្រាកនៅផ្ទះបានទេ។ ប្រសិនបើមិត្តឯងធ្វើការមិនបានច្រើនដូចមុនមិត្តឯងអាចធ្វើស្រាលជាងមុនបន្តិចក៏បានប៉ុន្តែមិនអាចឈប់សម្រាកនៅផ្ទះបានទេ»។ ខ្ញុំដឹងថា មេកងមិនសូវចិត្តអាក្រក់នោះទេ ប៉ុន្តែមេកងក៏ខ្លាចថ្នាក់លើដាក់ទោសគាត់ដែរ។ ខ្ញុំក៏ប្រញាប់ប្រញាល់ចាកចេញទៅធ្វើការ។ ថ្ងៃនោះមេឃភ្លៀងខ្លាំងណាស់ ខ្ញុំទទឹកខ្លួនជោគជាំ។ ខ្ញុំរងាញ័រទទ្រើក។ ខ្ញុំទ្រាំមិនបានក៏បាននិយាយសុំទៅមេកងម្តងទៀតដើម្បីទៅជ្រកភ្លៀងសិនព្រោះខ្លាចធ្លាក់ខ្លួនឈឺធ្ងន់ ប៉ុន្តែមេកងមិនអនុញ្ញាតឡើយ។ ដោយសារតែភាពភ័យខ្លាចនឹងការដាក់ទោស ខ្ញុំនៅតែខិតខំធ្វើការដូចប្រជាជនដទៃទៀតនៅក្រោមមេឃដែលកំពុងតែភ្លៀងផ្គរយ៉ាងខ្លាំង។ ថ្ងៃនោះ ទោះបីភ្លៀងធ្លាក់មិនឈប់ លាយឡំជាមួយនឹងផ្លេកបន្ទោរ ក៏ប្រជាជននៅក្នុងកងទាំងអស់នៅតែខំធ្វើការងារមិនហ៊ានបង្អង់ឡើយ។

ក្រោយមក ខ្មែរក្រហមបានជម្លៀសប្រជាជនដែលរស់នៅក្នុងភូមិធ្លកទាំងអស់ឲ្យទៅរស់នៅក្នុងភូមិត្រពាំងថ្ម។ ខ្មែរក្រហមបានយកភូមិធ្លកជាមូលដ្ឋានរបស់ខ្លួនត្រៀមប្រយុទ្ធជាមួយកងទ័ពវៀតណាម។ ខ្ញុំបានផ្លាស់មកនៅក្នុងភូមិត្រពាំងថ្មជាមួយម្តាយ ឪពុក បងប្អូន និងក្រុមគ្រួសាររបស់ខ្ញុំ។ រស់នៅកន្លែងថ្មីក៏គ្មានអ្វីប្រសើរជាងកន្លែងចាស់ដែរ។ នៅក្នុងភូមិត្រពាំងថ្ម ខ្ញុំបានពរពោះកូនម្នាក់ទៀត ហើយខ្ញុំនៅតែធ្វើការងារធ្ងន់ដដែល។ ខ្មែរក្រហមបានឲ្យខ្ញុំបុកស្រូវ កិនស្រូវ ដើរកើបដីតាមផ្ទះវែកយកទៅដាក់ស្រែ ដែលពេលនោះ ខ្ញុំមានកូននៅក្នុងពោះអាយុរហូតដល់ប្រាំពីរខែហើយក៏ដោយ។ ទោះបីជាធ្វើការងារធ្ងន់យ៉ាងណា ខ្ញុំនៅតែអាចបង្កើតកូនទីពីររបស់ខ្ញុំបានដែរ។

ឪពុកខ្ញុំត្រូវអង្គការចោទប្រកាន់ថា «ក្បាលយួនខ្លួនខ្មែរ» ហើយយកទៅដាក់គុកនៅក្នុងវត្តធ្លក។ គុកនោះគឺជាកន្លែងលត់ដំ ឃុំឃាំង ធ្វើទារុណកម្ម និងជាទីតាំងសម្លាប់។ ខ្មែរក្រហមប្រើឪពុកខ្ញុំឲ្យឡើងត្នោត មើលគោ វែកដី និងវែកដី។ ក្រោយមកឪពុកខ្ញុំក៏ធ្លាក់ខ្លួនឈឺស្លាប់ដោយមិនអាចទ្រាំទ្រនឹងការងារធ្ងន់ទាំងអស់នេះបាន។ ក្រោយមកទៀត ម្តាយខ្ញុំកើតជំងឺម្រេញ ក៏បានស្លាប់ទៀត។ ចំណែកឯបងខ្ញុំពីរនាក់ដែលជាកងទ័ពខ្មែរក្រហមត្រូវបានខ្មែរក្រហមបញ្ជូនចេញពីភូមិ នៅពេលដែលកងទ័ពវៀតណាមវាយចូលមក។ រហូតមកដល់សព្វថ្ងៃនេះខ្ញុំមិនដែលឮដំណឹងបងប្រុសខ្ញុំទេ។ បន្ទាប់ពីកងទ័ពវៀតណាមចូលមករំដោះ យើងវិលត្រឡប់ទៅរស់នៅក្នុងភូមិធ្លកវិញ។ ខ្ញុំរស់នៅជាមួយប្តី កូន យាយ និងប្អូនៗ។ ខ្ញុំនិងប្តីគឺជាអ្នកទទួលបន្ទុកគ្រប់យ៉ាងនៅក្នុងគ្រួសារ។

នឹកឃើញដល់រឿងទាំងអស់នេះឡើង ខ្ញុំពិតជាខឹងណាស់។ ខ្មែរក្រហមបានយកអ្នកដែលខ្ញុំស្រឡាញ់ទៅដោយគ្មានថ្ងៃត្រឡប់មកវិញ។ ប៉ុន្មានឆ្នាំកន្លងមកនេះ ខ្ញុំធ្លាប់បានទៅទស្សនាគុកទួលស្លែង ហើយវាកាន់តែធ្វើឲ្យខ្ញុំឈឺចាប់ ព្រោះខ្ញុំឃើញតែរូបថតអ្នកទោសដែលខ្មែរក្រហមសម្លាប់ ធ្វើទារុណកម្ម និងខ្មោះប្រវាក់ដែលនៅសេសសល់។ ទិដ្ឋភាពក្នុងគុកទួលស្លែងបានធ្វើឲ្យខ្ញុំគិតដល់ឪពុករបស់ខ្ញុំដែលត្រូវខ្មែរក្រហមចាប់យកទៅដាក់គុកនៅក្នុងវត្តធ្លកដែរ។ ខ្ញុំបានសួរខ្លួនឯងថា តើខ្មែរក្រហមបានធ្វើទារុណកម្មឪពុករបស់ខ្ញុំដូចអ្នកទោសដែលនៅក្នុងគុកទួលស្លែងនេះដែរឬទេ។

ទោះបីជារឿងរ៉ាវទាំងនេះបានកន្លងហួសជាង៤០ឆ្នាំទៅហើយ ប៉ុន្តែខ្ញុំនៅតែបន្តរំឭកវាជាញឹកញាប់។ ខ្ញុំបាននិយាយប្រាប់រឿងរ៉ាវដែលបានកើតឡើងដល់កូន និងក្មេងៗជំនាន់ក្រោយ ប៉ុន្តែក្មេងៗមិនជឿខ្ញុំឡើយ។ ខ្ញុំនៅតែបន្តនិយាយ ព្រោះខ្ញុំចង់ឲ្យក្មេងៗដឹង និងរៀនសូត្រអំពីបទពិសោធន៍ដ៏អាក្រក់មួយនេះ។ ខ្ញុំស្ងប់ចិត្តខ្លះនៅពេលដែលតុលាការខ្មែរក្រហមស្វែងរកឃើញកំហុស និងកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអស់នោះដាក់គុកអស់មួយជីវិត។ ខ្ញុំក៏ចង់ទទួលបានព័ត៌មានបន្ថែមអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែរ។

សព្វថ្ងៃនេះ ខ្ញុំមានវ័យកាន់តែចំណាស់ ហើយសុខភាពរបស់ខ្ញុំក៏ទ្រុឌទ្រោមណាស់ដែរ។ ខ្ញុំមានជំងឺរលាកក្រពះ និងពោះវៀន ដែលតែងតែធ្វើឲ្យខ្ញុំចុក និងឆ្អល់ៗនៅក្នុងពោះ។ ក្រៅពីនោះ ខ្ញុំខ្វះជាតិស្ករ ដែលធ្វើឲ្យខ្ញុំស្រវាំងភ្នែក និងវិលមុខជាញឹកញាប់។ កាលពីមួយខែកន្លងទៅនេះ ខ្ញុំបានទៅព្យាបាលនៅមណ្ឌលសុខភាពស្រុកស្វាយជ្រំ ដោយចាក់ថ្នាំដាក់សេរ៉ូម និងទិញថ្នាំបន្ថែមយកមកលេបនៅឯផ្ទះ។ បន្ទាប់ពីបានព្យាបាល ខ្ញុំក៏បានធូរស្បើយជាងមុនខ្លះដែរ។ ជំងឺរបស់ខ្ញុំមិនមែនទើបតែឈឺនោះទេ ប៉ុន្តែខ្ញុំចេះតែព្យាយាមព្យាបាលវាម្តងបន្តិចៗ។ ក្រៅពីទៅព្យាបាលនៅពេទ្យ ខ្ញុំទម្លាប់ថែរក្សាអនាម័យរបស់ខ្ញុំ និងចៅៗជានិច្ច គឺខ្ញុំប្រើប្រាស់សាប៊ូដើម្បីលាងសម្អាតសម្លាប់មេរោគ។

រហូតមកដល់ពេលនេះ ខ្ញុំមិនចង់បានអ្វីឡើយ។ ខ្ញុំគិតដល់តែបញ្ហាសុខភាពដែលខ្ញុំត្រូវប្រឈមមុខព្យាបាលនាពេលខាងមុខបន្តទៀតតែប៉ុណ្ណោះ។ ខ្ញុំសង្ឃឹមថាមជ្ឈ-មណ្ឌលឯកសារកម្ពុជា អាចផ្តល់សេវាកម្មនេះដល់ខ្ញុំ និងជនរងគ្រោះពីរបបខ្មែរក្រហមដទៃទៀតបាន។ ខ្ញុំសង្ឃឹមថានឹងបានជួប និងសហការបន្តទៀតជាមួយនឹងមជ្ឈ-មណ្ឌលឯកសារកម្ពុជា។



ស្វែងរកការពិត-ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ
លេខ២៤៦ ខែមិថុនា ឆ្នាំ២០២០

# ថ្លាង កាន អតីតប្រធានពេទ្យ សេនាធិការភូមិភាគបូព៌ា

*សោម ប៊ុនថន*



រូបថតរបស់ ថ្លាង កាន នៅផ្ទះរបស់គាត់នៅភូមិពោធិ៍រោង ឃុំជីភុច ស្រុកមេសាង ខេត្តព្រៃវែងបន្ទាប់ពីគាត់បានផ្តល់បទសម្ភាសន៍ទាក់ទងប្រវត្តិការងាររបស់គាត់ និងរឿងរ៉ាវនៅក្នុងរបបខ្មែរក្រហមដល់លោក ឡុង ដានី អ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៥។ (សោម ប៊ុនថន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំកើតនៅឆ្នាំ១៩៣៩ នៅភូមិខ្ពប ឃុំរំចេក ស្រុកមេមត់ កំពង់ចាម (បច្ចុប្បន្នខេត្តត្បូងឃ្មុំ)។ កាលពីសម័យអាណានិគមនិយមបារាំង នៅក្នុងភូមិរបស់ខ្ញុំមានការប្រទាញប្រទង់គ្នាយ៉ាងខ្លាំងរវាងចលនាខ្មែរឥស្សរៈ និងបារាំង ព្រមទាំងរាជការខ្មែរ។ ដូច្នេះបារាំងក៏បានដាក់ប៉ុស្តិ៍ត្រួតពិនិត្យការធ្វើដំណើររបស់ប្រជាជននៅថ្នល់ជាតិ ហើយបារាំងក៏បានប្រមូលប្រជាជននៅតាមជនបទ ចុងកាត់មាត់ញកមួយចំនួនដែលរស់នៅស្រុកមេមត់ និងស្នួល ឲ្យមករស់នៅជុំគ្នានៅឃុំដំរីផុង ក្នុងស្រុកស្នួល ខេត្តក្រចេះ។ រហូតដល់ចលនាខ្មែរឥស្សរៈស្ងប់ស្ងាត់ ទើបបារាំងអនុញ្ញាតឲ្យប្រជាជនត្រឡប់ទៅរស់នៅតាមផ្ទះ ប៉ុន្តែខ្ញុំនិងឪពុកម្តាយ មិនបានត្រឡប់ទៅផ្ទះនៅក្នុងស្រុកមេមត់វិញទេ។ ខ្ញុំបានចូលរៀននៅសាលាវត្ត ក្នុងឃុំដំរីផុងបានដល់ថ្នាក់ទី១០ បន្ទាប់មកខ្ញុំបានបួសជានេននៅវត្តដំរីផុង ហើយតមកបានបួសជាភិក្ខុនៅវត្តស្នួលទៀត។ ខ្ញុំបួសជាសង្ឃនៅស្រុកស្នួល ខេត្តក្រចេះ បានរយៈពេល៩ព្រះវស្សា ក៏ផ្លាស់មកសិក្សាខាងធម៌វិន័យបន្តនៅវត្តប្រលោម (វត្តខណ្ឌាឡោម) នៅក្នុងក្រុងភ្នំពេញ ដោយខ្ញុំស្នាក់នៅកុដិលេខ៣០។

នៅអំឡុងពេលខ្ញុំរស់នៅក្រុងភ្នំពេញ ក្រុមបដិវត្តន៍ខ្មែរក្រហមបានធ្វើសកម្មភាពឃោសនាសម្ងាត់កាន់តែច្រើន ហើយបានរីករាលដាលចូលមកដល់វត្តទៀត។ ក្រោយមក ការឃោសនារបស់ខ្មែរក្រហមក៏បែកការណ៍ ដូច្នេះខ្មែរក្រហមមួយចំនួនបានកោរសក់ និងទិញស្បង់ចីពរពាក់បន្លំខ្លួនជាព្រះសង្ឃ ដើម្បីធ្វើសកម្មភាពឃោសនានៅក្នុងក្រុងបន្តទៀត។ ពេលនោះ ខ្ញុំក៏តែងតែឮព្រះចៅអធិការវត្តមួយចំនួនលើកឡើងពីទ្រឹស្តីលេនីន និងអង់គែលដែរ។ នៅឆ្នាំ១៩៦៩ ស្ថានការណ៍នៅក្នុងក្រុងភ្នំពេញកាន់តែច្របូលច្របល់ដូច្នេះខ្ញុំក៏បានលាចាកសិក្ខាបទ រួចហើយត្រឡប់មកផ្ទះនៅស្រុកស្នួលវិញ។ បន្ទាប់មកខ្ញុំបានចូលធ្វើការនៅរោងចក្រផលិតក្រដាសនៅក្នុងស្រុកស្នួល ខេត្តក្រចេះ។

នៅពេលកើតមានព្រឹត្តិការណ៍រដ្ឋប្រហារទម្លាក់សម្តេច ព្រះនរោត្តម សីហនុ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ប្រធានរោងចក្របានអនុញ្ញាតច្បាប់ឲ្យខ្ញុំឈប់សម្រាករយៈពេល៣ថ្ងៃ។ នៅថ្ងៃដែលខ្ញុំចូលធ្វើការវិញស្រាប់តែមានឈ្មោះរបស់ខ្ញុំនៅក្នុងកងទ័ព គឺចំពេលដែលរដ្ឋាភិបាលសាធារណរដ្ឋខ្មែររបស់លោក លន់ នល់ កំពុងដើរចាប់យុវជនដាក់រថយន្តធំៗដើម្បីបញ្ជូនទៅហ្វឹកហាត់និងបម្រើកងទ័ព។ ខ្ញុំបានមកលាឪពុកម្តាយរបស់ខ្ញុំចូលបម្រើកងទ័ពដែរ ប៉ុន្តែពេលនោះឪពុករបស់ខ្ញុំមិនអនុញ្ញាតឡើយ គឺគាត់បានប្រាប់ខ្ញុំឲ្យនៅលាក់ខ្លួនក្នុងភូមិមួយរយៈសិន។ ស្របពេលនោះ សម្តេចព្រះនរោត្តមដែលគង់នៅទីក្រុងប៉េកាំងក៏បានអំពាវនាវតាមវិទ្យុឲ្យកូនចៅចូលព្រៃដើម្បីវាយកងទ័ព លន់ នល់ ដែលគាំទ្រដោយអាមេរិកដើម្បីរំដោះប្រទេសជាតិ។

មួយរយៈក្រោយមក ភូមិរបស់ខ្ញុំត្រូវបានរំដោះ ហើយបដិវត្តន៍ខ្មែរក្រហមក៏បានរកមនុស្សឲ្យទៅរៀនផ្នែកពេទ្យរយៈពេលបីខែដើម្បីព្យាបាលប្រជាជនក្នុងភូមិ ដូច្នេះមេភូមិក៏បានជ្រើសរើសខ្ញុំ។ ខ្ញុំបានទៅរៀនជាមួយពេទ្យមកពីវៀតណាមខាងជើង នៅក្នុងព្រៃក្នុងភូមិប្រហូតក្នុងឃុំដំរីផុងដដែល។ ស្រាប់តែពេលនោះទាហានធីវគី (វៀតណាមខាងត្បូង) ក៏បានចូលមកបោះទីតាំងនៅទីរួមស្រុកស្នួល ដូច្នេះ ចៅហ្វាយស្រុកស្នួល និងអ្នកធ្វើការនៅស្រុកមួយចំនួនក៏បានភៀសខ្លួនមករស់នៅភូមិរបស់ខ្ញុំបណ្តោះអាសន្ន ព្រោះខ្លាចទាហានវៀតណាមខាងជើងនិងខាងត្បូងវាយប្រហារគ្នា ហើយប៉ះពាល់ដល់ខ្លួន។ បន្ទាប់មក ខាងកងទ័ពបដិវត្តន៍ខ្មែរក្រហម និងកងទ័ពវៀតកុង បានសហការណ៍គ្នាវាយបណ្តេញទាហានធីវគីចេញទៅវិញ។

បន្ទាប់ពីខ្ញុំរៀនពេទ្យចប់នៅចុងឆ្នាំ១៩៧០ កងទ័ពបដិវត្តន៍ខ្មែរក្រហមបានដកខ្ញុំពីពេទ្យភូមិព្រហូតឲ្យមកធ្វើការនៅអង្គភាពយោធាវិញ ដើម្បីរុំរបួស និងចាក់ថ្នាំឲ្យយុទ្ធជនខ្មែរក្រហមដែលរងរបួសនៅតាមសមរភូមិ។ ខ្ញុំនៅអង្គភាពយោធាវរសេនាតូចលេខ១១៨ ដែលដឹបូងគ្រប់គ្រងរួមគ្នារវាងកងទ័ពបដិវត្តន៍ខ្មែរក្រហម និងកងទ័ពវៀតកុង ដោយពេលនោះខាងវៀតកុងគឺអ្នកទំនុកបម្រុងបាយទឹក អង្ករ និង ថ្នាំពេទ្យ។ នៅពេលកងទ័ពវៀតកុងដកចេញទៅអស់ អង្គភាពពេទ្យនេះគឺខាងបដិវត្តន៍ខ្មែរក្រហមគ្រង់គ្រងវិញ ហើយខ្ញុំគឺជាប្រធានពេទ្យនៅពេលនោះ។ ក្រោយមក ខ្ញុំត្រូវបានខ្មែរក្រហមដកពីវរសេនាតូចលេខ១១៨ ឲ្យមកធ្វើការនៅអង្គភាពពេទ្យសេនាធិការភូមិភាគបូព៌ាវិញ។ អង្គភាពពេទ្យរបស់ខ្ញុំត្រូវចល័តទៅតាមកងយោធាខ្មែរក្រហមដែលឡើងទៅវាយនៅតាមសមរភូមិ ដើម្បីរង់ចាំព្យាបាល និងវះកាត់យុទ្ធដែលរងរបួសឲ្យបានទាន់ពេលវេលា និងកុំឲ្យគ្រោះថ្នាក់ដល់អាយុជីវិត។ នៅអង្គភាពពេទ្យសេនាធិការពេលនោះមានគ្រូពេទ្យប្រមាណ២០ទៅ ៣០នាក់ធ្វើការ។ គ្រូពេទ្យត្រូវបានបែងចែកជាក្រុម គឺក្រុមផ្តល់បាយទឹកដល់អ្នកជំងឺ ក្រុមបើកថ្នាំ ក្រុមបើកអង្ករ និងក្រុមរកបន្លែបង្កា និងត្រីសាច់។ នៅពេលនោះ អង្គភាពពេទ្យសេនាធិការភូមិភាគបូព៌ា ក៏បានហៅគ្រូពេទ្យតាមតំបន់មករៀនសូត្រអំពីមេរៀនពេទ្យថ្មីៗ និងបទពិសោធន៍ព្យាបាលអ្នកជំងឺដោយមានវេជ្ជបណ្ឌិតខ្មែរធ្លាប់ទៅរៀននៅក្រុងហាណូយ វៀតណាមខាងជើង គឺជាអ្នកខទ្ទេសនាម។

បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គភាពពេទ្យរបស់ខ្ញុំបានមកបោះទីតាំងនៅក្រុងព្រៃវែង (បច្ចុប្បន្ន មន្ទីរពេទ្យអង្គឌួង) សម្រាប់ព្យាបាលយុទ្ធជនខ្មែរក្រហម ចំណែកមន្ទីរពេទ្យចាស់នៅក្នុងព្រៃវែង សម្រាប់ព្យាបាលប្រជាជន។ នៅពេលនោះ កងពលមួយចំនួនដែលមិនមានគ្រូពេទ្យនៅប្រចាំការក៏បានធ្វើសំណើមក កែវ សំណាង ប្រធានសេនាធិការរបស់ភូមិភាគបូព៌ាដើម្បីសុំគ្រូពេទ្យ ដូច្នេះ កែវ សំណាង ក៏ចាត់តាំងខ្ញុំឲ្យជ្រើសរើសគ្រូពេទ្យដែលមានសមត្ថភាពប្រគល់ទៅខាងកងពលវិញ។ នៅអង្គភាពពេទ្យរបស់ខ្ញុំនៅដាច់ដោយឡែកពីយោធា ហើយពេលប្រជុំគឺខ្ញុំប្រធានពេទ្យ និងប្រធានខាងបច្ចេកទេសកោះប្រជុំ

តែជាមួយគ្រូពេទ្យនៅក្នុងអង្គភាពតែប៉ុណ្ណោះ ដើម្បីដកពិសោធន៍ពីបច្ចេកទេសព្យាបាលអ្នកជំងឺ និងការខ្វះខាតនៅក្នុងអង្គភាព ចំណែកខាងនយោបាយ និងយោធាមានអ្នកផ្សេងទៀតគ្រប់គ្រង។ ទោះបីយ៉ាងណា ទាំងអង្គភាពពេទ្យរបស់ខ្ញុំ អង្គភាពភ័ស្តុភា អង្គភាពកាត់ដេរ និង ដកស្ទូង គឺស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កែវ សំណាង ប្រធានសេនាធិការភូមិភាគបូព៌ា ដែលមានមន្ទីរសេនាធិការស្ថិតនៅតាមផ្លូវទៅមាត់ទន្លេក្នុងក្រុងព្រៃវែង។ ប៉ុន្តែពេលនោះ កែវ សំណាង មិនសូវនៅប្រចាំការនៅមន្ទីរសេនាធិការទេ គឺគាត់ត្រូវទៅប្រចាំការនៅសមរភូមិមុខ ក្នុងខេត្តស្វាយរៀង តំបន់២៣។ ថ្ងៃមួយ កែវ សំណាង បានហៅខ្ញុំឲ្យទៅពិនិត្យជំងឺរបស់គាត់នៅខេត្តស្វាយរៀង។ បន្ទាប់ពីពិនិត្យជំងឺរួច ខ្ញុំក៏បានឲ្យថ្នាំទៅគាត់សម្រាប់លេប។ នៅពេលព្រឹកនោះ កែវ សំណាង បានចេញទៅបាញ់សត្វលលក ព្រោះគាត់ស្មុគ្រស្មាញក្នុងការដឹកនាំយុទ្ធជនខ្មែរក្រហមទៅវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅសមរភូមិ។ កែវ សំណាង មានវិទ្យុមួយម៉ាកណាស្យូណាល់ពីរបង់មួយគ្រឿង ហើយមុនពេលចេញទៅ គាត់បានបើកវិទ្យុភាសាវៀតណាមដែលកំពុងចាក់ចម្រៀងកែលឿងបណ្ដើរ និងផ្សាយព័ត៌មានបណ្ដើរ ទុកចោលនៅមន្ទីររបស់គាត់។ ស្រាប់តែបែជន្យ អគ្គសេនាធិការកងទ័ពមជ្ឈិមឈ្មោះ ណាត បានចូលមក។ ណាត មិនបានសួរនាំខ្ញុំដែលអង្គុយនៅទីនោះទេ ហើយក៏មិនបានសួររក កែវ សំណាង ដែរ។ ណាត បានដើរចុះឡើងមួយជុំក៏ត្រឡប់ទៅវិញ។ នៅពេល កែវ សំណាង មកពីបាញ់សត្វលលក ខ្ញុំបានប្រាប់គាត់ថា បងអើយ! បងឯងបើកវិទ្យុ (វៀតណាម) ហ្នឹងធ្វើអី ព្រោះ ណាត មកម៉ិញហ្នឹង។ កែវ សំណាង តបមកខ្ញុំវិញថា មិនមានបញ្ហាទេ គាត់បើកវិទ្យុដើម្បីស្ដាប់ព័ត៌មានរាយការណ៍ទៅខាងមជ្ឈិម។ ស្រាប់តែយប់នោះ បាត់ខ្លួន កែវ សំណាង តែម្ដង។

នៅវេលាព្រឹកម៉ោង៨ ក្នុងខែមិថុនា នៅឆ្នាំ១៩៧៨ ដោយសារសភាពការច្របូកច្របល់កាន់តែខ្លាំង សោ ភឹម ប្រធានភូមិភាគបូព៌ា បានមកបើកអង្គប្រជុំចំហរមួយនៅមន្ទីរសេនាធិការរបស់ភូមិភាគបូព៌ាក្នុងក្រុងព្រៃវែង ដែលជាផ្ទះរបស់ កែវ សំណាង រយៈពេល៣ម៉ោង។ ការប្រជុំនៅពេលនោះ មានសមាសភាពចម្រុះនៅក្នុងអង្គភាពសេនាធិការទាំងស៊ីវិល និងយោធា ចូលរួមប្រមាណ៤០នាក់ ដែលមានតួនាទីត្រឹមតែប្រធាន «យ» ចំណែកកងទ័ព និងកម្មាភិបាលធំៗមួយចំនួនបានចេញទៅសមរភូមិមុខ ហើយមួយចំនួនទៀតបានបាត់ខ្លួន។ ខ្ញុំបានទៅចូលរួមប្រជុំក្រោយគេ ព្រោះខ្ញុំនៅជាប់រវល់រៀបចំ និងមើលថែយុទ្ធជនខ្មែរក្រហមដែលរងរបួសបាក់ដៃបាក់ជើងសម្រាកនៅមន្ទីរពេទ្យ។ ខ្ញុំបានអង្គុយនៅទល់មុខ សោ ភឹម ព្រោះកៅអីនៅខាងក្រោយមានមនុស្សអង្គុយពេញអស់ហើយ។ មុននឹងបើកអង្គប្រជុំ សោ ភឹម បាននិយាយថា កែ ពក បានហៅគាត់ទៅប្រជុំនៅថ្នល់ទទឹងដែរ ប៉ុន្តែគាត់មិនបានទៅចូលរួម ព្រោះគាត់មិនស្រួលខ្លួន។ សោ ភឹម បានប្រាប់សមាជិកនៅក្នុងអង្គប្រជុំថា សភាពការណ៍ដែលបានកើតឡើងកន្លងមក រួមទាំងហេតុការណ៍ «ចាប់» យុទ្ធជននៅក្នុងភូមិភាគបូព៌ាគាត់មិនបានដឹងឡើយ។ សោ ភឹម បានស្នើសមាជិកនៅក្នុងអង្គប្រជុំទាំងអស់មានមតិ ប៉ុន្តែគ្មាននរណាម្នាក់ឡើងនិយាយឡើយ។ ដូច្នេះគាត់បានបន្តថា បើយើងឱនកឲ្យគេ (ខាងមជ្ឈិម) គឺយើងស្លាប់ទាំងអស់ ដូច្នេះបើតាមមតិរបស់គាត់គឺមានតែវាយ ព្រោះអាចមានឈ្នះ និងអាចចាញ់។ ប្រសិនបើវាយឈ្នះគឺជារបស់យើង។ ពាក្យ សោ ភឹម និយាយដូច្នេះសមាជិកទាំងអស់បានឯកភាព និងយល់ស្របតាម។ នៅពេលនោះ អង្គភាពសេនាធិការភូមិភាគបូព៌ាមិនមានអាវុធគ្រប់គ្រាន់ឡើយ ចំណែកកងទ័ព និងកម្មាភិបាលធំៗមួយចំនួនក៏ត្រូវបានមជ្ឈិមចាប់ខ្លួនដែរ គឺសល់តែចាស់ជរា និងយុទ្ធជនដែលភាគច្រើនរងរបួស និងពិការប៉ុណ្ណោះ។ បន្ទាប់មក សោ ភឹម បានចាត់តាំង យ៉ាន់ ឲ្យទៅដឹកកាំភ្លើងពីឈូក រួមមាន អ៊ែរកែង អឹមសី និងការ៉ាប៊ីន ដែលជាកាំភ្លើងចាស់ៗមកចែកគ្នា និងត្រូវរកកម្លាំងយុទ្ធជនដែលត្រៀមចេញទៅសមរភូមិដើម្បីមកបំពាក់អាវុធ។ ខ្ញុំបានយកកាំភ្លើងទៅចែកឲ្យយុទ្ធជនដែលមកព្យាបាលនៅមន្ទីរពេទ្យសេនាធិកាដើម្បីវាយតទល់ជាមួយយោធាតំបន់ ២៤ ដែលមានការគាំទ្រពីកងទ័ពមជ្ឈិម នៅម្តុំស្នេហ៍ ក្នុងស្រុកមេសាង និងពាមម៉ាណាម ខាងកើតអ្នកលឿង។ នៅក្នុងអង្គប្រជុំ សោ ភឹម បានលើកឡើងទៀតថា កងទ័ពរបស់យើងត្រូវទប់ទល់ជាមួយកងទ័ពតំបន់ ២៤ ឲ្យជាប់ កុំឲ្យចូលមកក្នុងក្រុងព្រៃវែង ចាំគាត់ទៅពិភាក្សាជាមួយបង ប៉ុល ពត។ សោ ភឹម បានស្នើទាក់ទងតាមគេអូរជួប ប៉ុល ពត ដើម្បីសួរនាំពីសភាពការណ៍ដែលមជ្ឈិមចុះមកចាប់កម្មាភិបាល និងយុទ្ធជននៅក្នុងភូមិភាគបូព៌ា ប៉ុន្តែ ប៉ុល ពត បានប្រាប់ សោ ភឹម ថាមិនដឹងហេតុការណ៍នេះទេ និងស្នើឲ្យ សោ ភឹម ស៊ើបការណ៍ឲ្យបានច្បាស់លាស់បន្ថែមទៀតដើម្បីដោះស្រាយ។ ដូច្នេះ សោ ភឹម នៅតែមិនជឿថាផែនការចាប់កម្មាភិបាល និងយុទ្ធជននៅភូមិភាគបូព៌ា រៀបចំដោយ ប៉ុល ពត ឡើយ។ សោ ភឹម បានវិភាគថាគឺខាងយោធាដឹកនាំដោយ សុន សេន បានរៀបចំរដ្ឋប្រហារ ហើយចាប់យុទ្ធជន និងកម្មាភិបាលនៅខាងភូមិភាគបូព៌ា។ ដូច្នេះ សោ ភឹម ក៏បានឲ្យនីសារជូនគាត់ទៅតំបន់ ២២ ដែលស្ថិតនៅតាមបណ្ដោយមាត់ទន្លេ (ម្តុំអរិយក្សត្រ) ដើម្បីរង់ចាំជួប ប៉ុល ពត ព្រោះអំឡុងពេលនោះ ប៉ុល ពត ជាប់រវល់ទទួលជួបគណៈប្រតិភូបរទេស។ ចាប់តាំងពីពេល សោ ភឹម ចេញពីក្រុងព្រៃវែង ខ្ញុំក៏លែងទទួលដំណឹងពីគាត់ទៀតដែរ។ ក្រោយមកខ្ញុំក៏ឮដំណឹងថា សោ ភឹម បានបាញ់សម្លាប់ខ្លួនឯង។

បន្ទាប់ពីទទួលដំណឹងថា សោ ភឹម ស្លាប់ ឈ្មោះ វ៉ិន និងអ្នកធ្វើការក្នុងអង្គភាពពេទ្យរបស់ខ្ញុំឈ្មោះ សាម៉េន បានចេញទៅជួបប្រធានពលលេខ៤ទាំងយប់ ហើយខាងកងពលក៏សរសេរសំបុត្រមួយច្បាប់ផ្ញើត្រឡប់មកខ្ញុំនិងអង្គភាពសេនាធិការ នៅក្នុងក្រុងព្រៃវែងឲ្យដកកងទ័ពដែលបោះទីតាំងនៅស្នេហ៍ចេញ និងត្រូវប្រមូលអាវុធយកមកទុកនៅក្នុងក្រុងព្រៃវែង។ បន្ទាប់ពីទទួលបានសំបុត្រនេះ វ៉ុន ប្រធានមន្ទីរ០៥ បានទៅដកកម្លាំងយុទ្ធជនចេញពីស្នេហ៍អស់។ បន្ទាប់ពីដកកម្លាំងអស់ហើយ វ៉ុន និង សាម៉េន រួមទាំងមេដឹកនាំធំៗមួយចំនួនទៀតនៅអង្គភាពសេនាធិការ ត្រូវបានកងទ័ពមជ្ឈិមចាប់ខ្លួនទាំងអស់។ កងទ័ពមជ្ឈិមបានហៅមិត្តនារីដែលធ្វើការនៅក្នុងអង្គភាពសេនាធិការភូមិភាគបូព៌ាមកសួរនាំទាក់ទងនឹងប្រវត្តិរូបរបស់ខ្ញុំទៀត ដោយឲ្យនាឡិកាដៃទៅនារីទាំងនោះ ម្នាក់មួយគ្រឿងដើម្បីឲ្យឆ្លើយការពិត។ កងទ័ពមជ្ឈិមនៅពេលនោះគឺ ចង់សួររកយុទ្ធជនដែលបានទៅឈរជើងនៅស្នេហ៍ ក្នុងស្រុកមេសាង ប៉ុន្តែនារីទាំងនោះបានបដិសេធថា ខ្ញុំមិនបានទៅឈរជើងនៅទីនោះឡើយ ទើបខ្ញុំបានរួចខ្លួន។ មួយរយៈក្រោយ កងទ័ពស្ម័គ្រចិត្តវៀតណាមបានវាយចូលមកដល់ខេត្តព្រៃវែង ខ្ញុំក៏បានរត់ភៀសខ្លួនទៅនៅក្រាំងយ៉ូវ ក្នុងខេត្តកណ្ដាលមួយរយៈ ក៏ត្រឡប់ទៅផ្ទះនៅជីរដុងវិញ។ ប៉ុន្តែពេលទៅដល់ផ្ទះ ខ្ញុំបានជួបតែម្ដាយប៉ុណ្ណោះ ព្រោះឪពុករបស់ខ្ញុំបានស្លាប់ហើយ។ ក្រោយមក ខ្ញុំបានចូលធ្វើពេទ្យនៅចម្ការកៅស៊ូជប់ ក្នុងខេត្តកំពង់ចាម បានមួយរយៈ ក៏ឈប់ពីពេទ្យមកធ្វើស្រែជាមួយប្រពន្ធកូន និងរស់នៅឃុំជីផុច ស្រុកមេសាង ខេត្តព្រៃវែង រហូតមក។

**ចម្រៀងបដិវត្តន៍ខ្មែរក្រហម**

**«កងឈ្លបមូលដ្ឋាន»**

ដៃកាន់អាវុធ មោះមុតអង់អាចក្លាហាន កងឈ្លបមូលដ្ឋាន
យើងនាំគ្នាក្រោកឈរឡើងហើយ ពួនស្ទាក់ចាំវាយទាហាន លន់ នល់ សាមាន្យ
មើលវាថ្លើមធំហួសប្រមាណ ហ៊ានរុករានចូលដែនដីយើង។
វាយយើងវាយ វាយឥតបន្ធូរដៃ វាយនឹងស្មារតីយើងអង់អាចក្លាហាន
វាយជាសំខាន់ជាមួយអាវុធបុរាណ វាយលុះត្រារំដោះបាន
ភូមិឃុំកម្ពុជាយើងអើយ។

# យុទ្ធនារីបដិវត្តន៍

**សោម ប៊ុនថន**



នូ ផេង នៅខាងមុខផ្ទះរបស់គាត់ ស្ថិតនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ /មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ នូ ម៉ែត។ ខ្ញុំបានបែកពីឪពុកម្តាយរបស់ខ្ញុំតាំងពី១៩៧៣ នៅពេលដែលប្រធានភូមិបានមកជ្រើសរើស និងកត់ឈ្មោះខ្ញុំឲ្យទៅរៀនខាងតម្បាញជាមួយបដិវត្តន៍ខ្មែរក្រហមនៅមន្ទីរឈើជ្រុំ ស្ថិតនៅខាងជើងផ្ទះរបស់ខ្ញុំ ក្នុងឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ។ ប៉ុន្តែខ្ញុំមិនបានរៀនខាងតម្បាញដូចដែលមេភូមិមកប្រាប់ឡើយ គឺខ្ញុំត្រូវបានបញ្ជូលទៅខាងយោធាវិញ ដោយសារប្រទេសកំពុងមានសង្គ្រាម។ ខ្ញុំមានអាយុ២១ឆ្នាំនៅពេលនោះ។ ខ្ញុំនិងក្មេងស្រីៗដែលមានវ័យស្របាលគ្នា បានចូលហាត់ក្បួនយុទ្ធសាស្ត្រយោធា នៅកងអនុសេនាធំ៣២០ តំបន់៣២ ឬ អង្គភាពនារីតំបន់៣២ ដឹកនាំដោយយាយ ហាន។ អង្គភាពយោធានៅពេលនោះ ត្រូវបានបែងចែកជាពីរគឺ អង្គភាពនារី និងអង្គភាពបុរសដែលត្រូវហ្វឹកហាត់ និងស្នាក់នៅដាច់ដោយឡែកពីគ្នា។

នៅក្នុងអង្គភាពរបស់ខ្ញុំមានសមាជិកនារីប្រមាណជាង១០០នាក់។ សមាជិកនារីមួយចំនួនមានឈ្មោះ ម៉ែត ដូចខ្ញុំដែរ ដូច្នេះដើម្បីកុំឲ្យប្រធានកងហៅច្រឡំឈ្មោះគ្នាទៀត ខ្ញុំក៏បានប្តូរពីឈ្មោះ ម៉ែត មកជាក់ថា ផេង រហូតមក។ ដំបូងខ្ញុំមិនទាន់បានឡើងទៅវាយតទល់ជាមួយកងទ័ពរបស់ លន់ នល់ នៅសមរភូមិទេ គឺអង្គភាពយោធាបញ្ជូនតែយុទ្ធនារីដែលមានវ័យច្រើនជាងខ្ញុំ និងធ្លាប់ហ្វឹកហាត់មុនខ្ញុំទៅវាយនៅសមរភូមិ។ ចំណែកខ្ញុំគឺនៅដាំបាយនៅសមរភូមិក្រោយ ហើយនៅពេលយប់ ខ្ញុំត្រូវរែកបាយដែលដាំរួចយកទៅឲ្យយុទ្ធនារីត្រៀមប្រយុទ្ធនៅតាមលេណដ្ឋាននៅសមរភូមិមុខ ស្ថិតនៅខាងជើងខេត្តកំពង់ស្ពឺ។ នៅអំឡុងពេលនោះ យុទ្ធនារីនិងយុទ្ធជន របស់ខ្មែរក្រហមត្រូវឡើងទៅវាយតទល់ជាមួយកងទ័ពរបស់ លន់ នល់ នៅសមរភូមិទាំងអស់គ្នា។ ក្រោយមកសមរភូមិបានរំកិលមកដល់អ្នកតាធំស្ថិតនៅខាងជើងទីរួមខេត្តកំពង់ស្ពឺ (មិនឆ្ងាយប៉ុន្មានពីក្រុងច្បារមន) ប៉ុន្តែនៅទីនោះក៏មានយោធាខ្មែរក្រហមស្លាប់ច្រើនដែរ ដូច្នេះហើយខ្មែរក្រហមក៏បានហៅទីកន្លែងនោះថា «បឹងយុទ្ធជន»។ បន្ទាប់ពីយោធាខ្មែរក្រហមទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា នៅឆ្នាំ១៩៧៥ ខ្ញុំត្រូវបានចាត់តាំងឲ្យមករៀបចំ និងបោសសម្អាតផ្សារនៅក្នុងក្រុងច្បារមន។ នៅពេលដែលខ្មែរក្រហមចាប់ផ្តើមកសាងសេដ្ឋកិច្ច និងប្រទេសជាតិឡើងវិញ ខ្ញុំនិងយុទ្ធនារី ព្រមទាំងយុទ្ធជនមួយចំនួននៅក្នុងកងអនុសេនាធំ៣២០ តំបន់ ៣២ ត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែនៅព្រៃបេង និង ចម្ការធំ នៅ «បឹងយុទ្ធជន» វិញ។

រយៈពេលពីរឆ្នាំក្រោយមក គឺនៅឆ្នាំ១៩៧៧ អង្គភាពយោធារបស់ខ្ញុំត្រូវបានរំសាយ ហើយសមាជិកមួយចំនួនត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅតាមសហករណ៍ ចំណែកខ្ញុំត្រូវទៅធ្វើការនៅមន្ទីរនៅបាតដឹង ឬ ហៅថាមន្ទីររោងចក្រស្ករស ស្ថិតនៅខាងកើតចំណតរថភ្លើង។ ដំបូងទីតាំងរោងចក្រស្ករសនេះគឺជាវាល និងព្រៃរបោះ ដូច្នេះយើងត្រូវកាប់ឆ្ការសម្អាត និងសាងសង់មន្ទីរនេះដោយខ្លួនឯង។ មន្ទីរនេះមានអតីតយុទ្ធនារីខ្មែរក្រហមប្រមាណ២៥០ នាក់ និងយុទ្ធជនខ្មែរក្រហមប្រមាណ២៥០នាក់ មកពីតំបន់៣២ នៅធ្វើការរួមគ្នា និងមានប្រធានគ្រប់គ្រងម្នាក់ឈ្មោះ ជឹម គឺជាមេបញ្ជាយោធាខ្មែរក្រហម។ នៅសម័យនោះ ខ្មែរក្រហមហៅកន្លែងខ្ញុំធ្វើការថា រោងចក្រស្ករស ប៉ុន្តែមិនមែនយកស្ករអំពៅមកចម្រាញ់ទេ គឺយើងប្រមូលស្ករត្នោតដែលប្រជាជនធ្វើបានមកចម្រាញ់ធ្វើស្ករសជំនួសវិញ។ មន្ទីររបស់ខ្ញុំក៏មានអ្នកជំនាញខាងរោងចក្រ និងអ្នកបច្ចេកទេសខាងផលិតស្ករសនៅធ្វើការដែរ រីឯអ្នកមិនមានជំនាញបច្ចេកទេស គឺជួយលើកស្ករចាក់ចូលទៅក្នុងអាងរម្ងាស់ និងជួយធ្វើការនៅតាមផ្នែកផ្សេងៗទៀត។ នៅពេលចម្រាញ់ដំបូង ស្ករចេញមកមិនបានល្អឡើយ គឺស្ករនោះមានពណ៌ក្រហម។ មន្ទីររបស់ខ្ញុំចម្រាញ់ស្ករសបានជារៀងរាល់ថ្ងៃ បន្ទាប់មកយើងត្រូវប្រកចូលបាវរក្សាទុក។ នៅរយៈពេលមួយសប្តាហ៍ម្តងឡានបានមកដឹកស្ករសប្រមាណ ១០ ទៅ ២០ តោន ចេញពីរោងចក្ររបស់ខ្ញុំយកទៅ ប៉ុន្តែខ្ញុំមិនដឹងថាឡានដឹកយកទៅទីណាឡើយ។ នៅទីនោះខ្ញុំត្រូវធ្វើការវេនពីរពេលគឺ ពេលព្រឹកចាប់ផ្តើមធ្វើការពីម៉ោង ៧ ដល់ម៉ោង ១១ ចំណែកពេលរសៀល ចាប់ផ្តើមធ្វើការពីម៉ោង ១ ដល់ ម៉ោង៤។ ប៉ុន្តែនៅពេលដែលខ្មែរក្រហមត្រូវការស្ករសបន្ទាន់ ខ្ញុំត្រូវធ្វើការវេនទាំងយប់ដោយមិនគិតពីពេលវេលាឡើយ។ ចំណែករបបអាហារនៅអង្គភាពរបស់ខ្ញុំមានហូបរាល់ថ្ងៃ ប៉ុន្តែម្ហូបដែលចុងភៅចម្អិនញ៉ាំញាប់ជាងគេ គឺមានតែព្រលិត ដៃកំប្លោកស្លជាមួយកូនត្រីតូចៗប៉ុណ្ណោះ។ ដូច្នេះ ខ្ញុំនិងសមាជិកនៅរោងចក្រស្ករសទាំងអស់ ត្រូវបានបែងចែកក្រុមដាំបន្លែបង្ការផ្សេងៗ ដើម្បីផ្គត់ផ្គង់ដល់អង្គភាពបន្ថែមទៀត។ ទោះបីយ៉ាងណារោងបាយរបស់ក្រុមយុទ្ធនារី និងយុទ្ធជន ត្រូវបានបែងចែកឲ្យនៅដាច់ដោយឡែកពីគ្នា។ ចំណែកការរស់នៅ ក៏យើងស្នាក់នៅតាមផ្ទះរៀងៗខ្លួនដែលសង់ជាជួរនៅក្នុងបរិវេណរោងចក្រស្ករស។ នៅរោងចក្ររបស់ខ្ញុំពេលនោះ ពុំមានកៅស៊ូក្រាលហាលស្ករសឲ្យស្ងួតបន្ទាប់ពីចម្រាញ់ទេ ដូច្នេះខ្ញុំនិងសមាជិកកងត្រូវបានចាត់តាំងឲ្យក្រងកន្ទេលស្លឹកត្នោតសម្រាប់ហាលស្ករសជំនួសវិញ។ ក្រៅពីធ្វើការនៅរោងចក្រស្ករស ខ្ញុំត្រូវបានចាត់តាំងឲ្យទៅជួយធ្វើស្រែប្រជាជន នៅពេលខាងសហករណ៍ខ្វះខាតកម្លាំង និងបានស្នើមកប្រធានរោងចក្ររបស់ខ្ញុំ។

ខ្ញុំមិនដែលបានទៅលេងឪពុកម្តាយនៅស្រុកភ្នំស្រួចទេ ចាប់តាំងពីពេលដែលខ្ញុំចូលធ្វើយោធា និងធ្វើការនៅរោងចក្រស្ករសបាតដឹងព្រោះខ្ញុំមិនស្គាល់ផ្លូវទៅផ្ទះ។ រហូតដល់កងទ័ពវៀតណាមវាយចូលមកនៅដើមឆ្នាំ១៩៧៩ សមាជិកនៅក្នុងរោងចក្រស្ករសបានរត់បែកខ្ញែកគ្នា សមាជិកខ្លះបានរត់ត្រឡប់ទៅនៅផ្ទះវិញ សមាជិកខ្លះស្ម័គ្រចិត្តទៅនៅជាមួយយោធា ចំណែកខ្ញុំបានសម្រេចចិត្តនៅរោងចក្រស្ករសរង់ដែល ដែលដឹកនាំដោយ ជឹម។ ជឹម បានដឹកនាំសមាជិកទាំងអស់ដែលនៅសេសសល់រត់ចូលក្នុងព្រៃ ដើម្បីគេចចេញពីកងទ័ពវៀតណាម។ ខ្ញុំមិនបានដឹងថា ជឹម នាំខ្ញុំទៅនៅទីណាខ្លះទេ ព្រោះខ្ញុំមិនស្គាល់ភូមិសាស្ត្រច្បាស់លាស់។ ខ្ញុំនៅចាំបានថា ខ្ញុំទៅនៅភ្នំពាម និងចំណតរថភ្លើងក្រាំងស្តៀ ក្នុងស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង។ ដំបូងខ្ញុំមានអង្ករនៅក្នុងថង់វែងៗដែលស្ពាយ និងក្រវាត់ជាប់នឹងខ្លួនម្នាក់មួយថង់សម្រាប់ដាំបាយហូប។ ប៉ុន្តែនៅពេលដែលយើងហូបអស់អង្ករទាំងនេះអស់ ខ្ញុំនិងសមាជិកកងបាននាំគ្នាទៅលួចដកដំឡូងជ្វាតាមចម្ការ ដែលប្រជាជនដាំនៅក្បែរៗភូមិយកមកស្ងោរហូប ជាមួយស្មៀតគោដែលនៅសេសសល់។ ថ្ងៃខ្លះពេលរកអាហារពុំបាន ខ្ញុំផឹកទឹកតែប៉ុណ្ណោះ។ នៅពេលនោះកងរបស់ខ្ញុំក៏មានកាំភ្លើងនៅជាប់ខ្លួនដែរ ប៉ុន្តែមិនមានគ្រាប់រំសេវច្រើនទេ។ ដូច្នេះនៅពេលយើងជួបកងទ័ពវៀតណាមម្តងៗយើងក៏បាញ់ ២ទៅ ៣គ្រាប់ ដើម្បីទប់ទល់ បន្ទាប់មកយើងបានដកកម្លាំងមកក្រោយ ចំណែក



ផ្ទះរបស់ នូ ផេង ស្ថិតនៅក្នុងឃុំក្រពើពីរ ស្រុកវាលវែង ខេត្តពោធិ៍សាត់។ (សុខ វណ្ណៈ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កងទ័ពវៀតណាមបានឡើងមកមុខបន្តទៀត។

ពេលចេញពីឃុំក្រាំងស្វៀមក ខ្ញុំលែងស្គាល់ទីតាំងភូមិសាស្ត្រទៀតហើយ។ ខ្ញុំបានដើរដោយថ្មើរជើងរហូតដល់ព្រំដែនថៃ នៅខែមេសា ឆ្នាំ១៩៨០។ ខ្ញុំបានមកនៅមន្ទីរច-២ នៅខាងជើងប្រកថ្មដា ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់។ ខ្ញុំត្រូវបានចាត់តាំងឲ្យធ្វើការនៅខាងផ្នែកដឹកជញ្ជូននៅក្នុងកងពលលេខ៣៦ ដឹកនាំដោយយាយឿន។ ពេលនោះខ្ញុំបានដឹកជញ្ជូនអង្ករ និងគ្រាប់ពីមន្ទីរច-១ ទៅផ្តល់ឲ្យយោធាខ្មែរក្រហមនៅសមរភូមិមុខ នៅស្ទឹងមេទឹក។ ផ្នែកដឹកជញ្ជូនពេលនោះមិនមានរថយន្តឡើយ គឺខ្ញុំដាក់អាហារ សម្លៀកបំពាក់ និងគ្រាប់នៅក្នុងសម្ពាយរួចស្ពាយយកទៅឲ្យយោធាខ្មែរក្រហមនៅសមរភូមិមុខ។ ដោយសារសម្ពាយមានទម្ងន់ធ្ងន់ ដូច្នេះខ្ញុំដើររយៈពេលមួយម៉ោងត្រូវឈប់សម្រាកម្តង។ ប៉ុន្តែនៅពេលសង្កេតឃើញថាមានកងទ័ពវៀតណាមឆ្លងកាត់កន្លែងខ្ញុំដើរញឹកញាប់ គឺខ្ញុំត្រូវបន្តដំណើរទៅមុខដោយមិនហ៊ានឈប់សម្រាកឡើយ។ ខ្ញុំបានដើរជាមួយក្រុមតូចៗ ហើយនៅពេលទៅដល់កន្លែងដែលមានទឹកគឺខ្ញុំត្រូវឈប់ដាំបាយហូប និងផ្ទុតទឹក ដោយមានក្រុមប្រុសៗដើរល្បាតជុំវិញដើម្បីការពារ។ ខ្ញុំនិងក្រុមដឹកជញ្ជូនមិនហ៊ាននិយាយគ្នាដោយសំឡេងខ្លាំងៗ និងស្រែកឡូឡាឡើយ ព្រោះខ្លាចកងទ័ពវៀតណាមស្លាប់ៗ។ ចំណែកអាហារនៅពេលនោះមានតែត្រីខកំប៉ុងដែលខាងអង្គភាពបើកឲ្យប៉ុណ្ណោះ។ ដូច្នេះយើងត្រូវបេះបន្លែឬស្លឹកឈើព្រៃដែលយើងស្គាល់មកស្ងហូបបន្ថែមទៀត។ ក្រៅពីដឹកជញ្ជូនទៅស្ទឹងមេទឹក ខ្ញុំត្រូវជញ្ជូនស្បៀងទៅសមរភូមិនៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងទៅសមរភូមិក្នុងស្រុកម៉ោងឫស្សី ខេត្តបាត់ដំបង ទៀត។ ខ្ញុំត្រូវចំណាយពេលមួយខែដើម្បីជញ្ជូនស្បៀងទៅសមរភូមិនីមួយៗ ទើបត្រឡប់មកអង្គភាពរបស់ខ្ញុំនៅមន្ទីរ ច-២ វិញ។

នៅឆ្នាំ១៩៨៨ ខ្ញុំបានរៀបការជាមួយប្តីដែលជាអតីតយោធាខ្មែរក្រហមនៅខាងភូមិភាគពាយ័ព្យនៅម្តុំកញ្ចែក្នុងទឹកដីថៃ ស្ថិតនៅជាប់ព្រំដែនជាមួយស្រុកសំឡូត ខេត្តបាត់ដំបង។ បន្ទាប់ពីរៀបការរួច ខ្ញុំក៏ឈប់ពីកងដឹកជញ្ជូនរួចហើយទៅស្នាក់នៅជំរំក្នុងទឹកដីថៃ។ នៅពេលមេដឹកនាំខ្មែរក្រហមចូលរួមចរចាជាមួយរដ្ឋាភិបាលកម្ពុជានៅទសវត្សរ៍ ៩០ ខ្ញុំបានចេញពីដីថៃ មកនៅខាងអូររំចេកវិញ។ ប៉ុន្តែខ្ញុំរស់នៅអូររំចេកបានរយៈពេល៤ឆ្នាំប៉ុណ្ណោះ ក៏កងទ័ពរាជរដ្ឋាភិបាលកម្ពុជាវាយចូលមក ហើយខ្ញុំក៏ភៀសខ្លួនរត់ទៅរស់នៅក្នុងជំរំអូរល្ហុង ប្ការសាថៃហៅថា ជំរំខាងភ្លូ ក្នុងទឹកដីថៃម្តងទៀត។ រយៈពេលមួយឆ្នាំក្រោយមកបន្ទាប់ពីមានការចរចាត្រូវរ៉ូវគ្នារវាងកម្លាំងខ្មែរក្រហម និងរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំក៏បានចេញពីដីថៃមករស់នៅឃុំក្រពើពីររហូតមក។ ពេលមកដល់ដំបូង កន្លែងដែលខ្ញុំរស់នៅហ៊ុំព័ទ្ធដោយព្រៃឈើ និងមើលមិនឃើញពន្លឺព្រះអាទិត្យឡើយ។ ខ្ញុំបានរានព្រៃដើម្បីសង់ផ្ទះស្នាក់នៅ ហើយខ្ញុំក៏មិនហ៊ានដើរឆ្ងាយពីផ្ទះដែរព្រោះមានជ្រូកព្រៃ ឈ្លូស និងសត្វជាច្រើនប្រភេទទៀតនៅជុំវិញផ្ទះ។ ក្រោយមកខ្ញុំបានរានព្រៃបានដីទំហំ ៣ហិកតាដើម្បីធ្វើស្រែ និងចម្ការ។ ប៉ុន្តែមកដល់សព្វថ្ងៃខ្ញុំបានចែកដីមួយចំនួនឲ្យកូនរបស់ខ្ញុំដាំដំឡូង និងពោតហើយ។ ខ្ញុំបានទៅលេងស្រុកកំណើតនៅភ្នំស្រួចបានបីដងបន្ទាប់ពីសមាហរណកម្ម ប៉ុន្តែដោយសារគ្មានប្រាក់ខ្ញុំក៏មិនបានទៅលេងស្រុកទៀត។ ចំណែកបងប្អូនរបស់ខ្ញុំដែលរស់នៅស្រុកកំណើត ក៏មិនដែលបានមកលេងខ្ញុំដែរ។





# បូជាភ្លើង

## សំណួរដែលបានសួរមកខ្ញុំអំពីការសម្លាប់រង្គាលនៅអឺរ៉ុប

**ហេឌី ប្រ៊ាយ**

(តពីលេខមុន)




ពិព័រណ៍រូបថតនៅ សារមន្ទីរ ស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ ( សូរិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

### តើអ្នកអាចស្រមៃឃើញខ្លួនឯងដូចជាជនភៀសខ្លួនសព្វថ្ងៃនេះដែរឬទេ?

ខ្ញុំបានមកដល់ប្រទេសស៊ុយអែតនៅរដូវក្តៅក្នុងឆ្នាំ ១៩៤៥ តាមរយៈការសន្ដោសប្បុរសធម៌របស់រដ្ឋាភិបាលប្រទេសស៊ុយអែត ក្នុងការទទួលយកអ្នករស់រានមានជីវិតដែលមានជំងឺចំនួន១ម៉ឺននាក់ ដើម្បីព្យាបាលជំងឺក្នុងរយៈពេល៦ខែ។ ប៉ុន្តែ៦ខែនោះ បានប្រែទៅជាមួយជីវិតដែលពោរពេញទៅដោយការតស៊ូរួមទាំងភាពបរាជ័យ និងភាពជោគជ័យ។

យើងគឺជាជនភៀសខ្លួនចេញពីអតីតកាល និងបានដឹងគុណចំពោះសប្បុរសធម៌ដែលបានធ្វើមកលើយើង។ ដើម្បីទទួលបាននូវសេចក្តីថ្លៃថ្នូរមកវិញ យើងចង់ចាប់ផ្តើមធ្វើការងារឲ្យបានឆាប់នៅពេលណាដែលមានកម្លាំងភ្លាមៗ។ ការងារអ្វីគឺមិនសំខាន់នោះទេ យើងទទួលយកអ្វីទាំងអស់ដែលគេឲ្យធ្វើ។ យើងបានគិតថាប្រសិនបើរៀនចេះភាសាយើងនឹងអាចសម្រេចក្តីបំណងដ៏ធំបំផុតដើម្បីឲ្យខ្លួនយើងក្លាយទៅជាពលរដ្ឋដែលមានប្រយោជន៍ម្នាក់។ យើងដឹងច្បាស់ថាយើងមិនចង់វិលត្រឡប់ទៅប្រទេសរបស់ខ្លួនវិញនោះទេ ដូច្នេះហើយ យើងគឺមិនខុសគ្នាពីជនភៀសខ្លួន

សព្វថ្ងៃនេះនោះទេ។ អ្វីដែលខុសគ្នានោះ គឺយើងមិនចង់ត្រឡប់ទៅវិញ ប៉ុន្តែពួកគេគឺមិនអាចត្រឡប់ទៅវិញ។

នៅពេលដែលខ្ញុំឃើញរូបភាពរន្ធត់របស់អាគារដែលទ្រុឌទ្រោម និងទូកដែលណែនតាន់តាប់ដោយមនុស្សនៅលើសមុទ្រមេឌីទែរ៉ាណេ ខ្ញុំអាចស្រមៃឃើញខ្លួនឯងកំពុងតែអង្គុយនៅទីនោះ។ ខ្ញុំក៏ប្រហែលជាឡើងទៅលើទូកនោះដែរទោះបីជាមានក្តីសង្ឃឹមតិចតួចក្នុងការរស់រានមានជីវិតក៏ដោយ។ មនុស្សទាំងអស់នោះដឹងថាខ្លួននឹងមិនត្រូវបានទទួលស្វាគមន៍នៅទីកន្លែងណានោះទេ ដូចដែលយើងបានដឹងដែរថា ជនជាតិជ្វីហ្វមិនត្រូវបានទទួលស្វាគមន៍នោះទេនៅក្នុងអំឡុងឆ្នាំ១៩៣៨។ ទោះបីជាបន្ទាប់ពីឆ្នាំ១៩៤៥ក៏ដោយ ក៏នៅតែមិនប្រសើរឡើងដែរ បុរេវិនិច្ឆ័យគឺនៅតែមានជាប់ជានិច្ច។ បុរេវិនិច្ឆ័យបានចាប់ផ្តើមក្លាយទៅជាការស្លាប់បាត់សង្គមមួយដែលស្វែងរកការអះអាង គឺប្រៀបបានដូចជាទំនាយមួយ ដែលឆ្លើយតបសំណួរដោយខ្លួនឯង ហើយក៏ក្លាយទៅជាដំណើរវិលជុំដ៏កាចសាហាវមួយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រទេសស៊ុយអែតបានបើកទទួលយ៉ាងហោចណាស់ យើងទាំងអស់គ្នាចំនួន១ម៉ឺននាក់។

នៅពេលដែលខ្ញុំមើលទៅជនភៀសខ្លួនសព្វថ្ងៃនេះ ខ្ញុំយល់អារម្មណ៍របស់អ្នកដែលបាត់បង់ក្តីសង្ឃឹមទាំងនោះដែលជម្រើសតែមួយគត់សម្រាប់ឲ្យពួកគេជៀសផុតពីសេចក្តីស្លាប់បាននោះ គឺការធ្វើដំណើរដែលប្រឈមមុខនឹងគ្រោះថ្នាក់ទៅទីកន្លែងដែលគ្មាននរណាម្នាក់ដឹង។ ជំនួសទៅដោយការជួយយកអាសារ អ្នកទាំងនោះបែរជាជួបជាមួយនឹងជញ្ជាំងខ្ពស់ និងមនុស្សព្រងើយកន្តើយដែលបានបាត់បង់សេចក្តីករុណាទៅវិញ។ ខ្ញុំមើលឃើញភាពអាត្មានិយម និងភាពមិនទទួលខុសត្រូវដូចដែលមាននៅក្នុងដើមទសវត្សរ៍ឆ្នាំ១៩៣០ដដែល។ ក៏ប៉ុន្តែ វាគឺមានកាន់តែខ្លាំងឡើង១។

កាលពីមុនដូចជាបច្ចុប្បន្ននេះដែរ មិនមានមនុស្សជាច្រើនទេដែលអាចស្រមៃឃើញថានឹងមានរឿងអាក្រក់កើតឡើងចំពោះខ្លួន។ បុព្វជិតប្រូតេស្តង់ជនជាតិអាល្លឺម៉ង់លោក ម៉ាទីន ម៉ូរលឺ ក៏មិនបានជឿដូចគ្នាពីព្រោះតែហ៊ីត្លែរមុនដំបូងមិនបានប៉ះពាល់វិហារប្រូតេស្តង់នោះទេ។ ក្រោយមកនៅពេលដែលត្រូវបានចាប់ដាក់ពន្ធនាគារបុព្វជិតនោះបាននិយាយថា "ដំបូងពួកគេបានមករកអ្នកកាន់លិទ្ធិកុម្មុយនីស្ត ខ្ញុំមិនបាននិយាយអ្វីនោះទេពីព្រោះខ្ញុំមិនមែនជាកុម្មុយនីស្ត។ បន្ទាប់មកពួកគេបានមករកជនជាតិជ្វីហ្វ ហើយខ្ញុំក៏មិននិយាយអ្វីដែរពីព្រោះខ្ញុំមិនមែនជាជនជាតិជ្វីហ្វ។ បន្ទាប់មកពួកគេមករកខ្ញុំ ហើយនៅពេលនោះគឺគ្មានសេសសល់នរណាម្នាក់ដែលអាចនិយាយការពារខ្ញុំនោះទេ"។

ហេតុការណ៍ដែលអាក្រក់បំផុតអាចកើតឡើងចំពោះយើងគ្រប់រូបទោះបីជាយើងព្យាយាមប្រាប់ខ្លួនឯងយ៉ាងណាក៏ដោយ។ យើងនៅមិនទាន់អាចមើលឃើញទីបញ្ចប់នៃវិបត្តិអន្តោប្រវេសន៍ដែលកំពុងកើតមានឡើងសព្វថ្ងៃនេះទេ ហើយក៏មិនអាចនិយាយបានដែរថាថ្ងៃណាមួយយើងនឹងមិនត្រូវផ្លាស់ទីកន្លែងហើយស្វែងរកផ្ទះថ្មីម្តងទៀតឡើយ។ ប្រសិនបើអ្នកធ្លាប់ឆ្លងកាត់ម្តង ហើយអ្នកនឹងដឹងថាវាអាចកើតឡើងម្តងទៀតបាន។

## តើអ្នកត្រូវបានគំរាមកំហែងដោយណាហ្ស៊ីថ្មីដែរឬទេ?

កាលពី៣០ឆ្នាំមុនខ្ញុំបានទទួលទូរសព្ទពីអ្នកកាសែតម្នាក់ដែលចង់ពិភាក្សាជាមួយខ្ញុំអំពីហូឡូខសត៍នៅលើកញ្ចក់ទូរទស្សន៍ជាមួយនឹងអតីតមេដឹកនាំណាហ្ស៊ីម្នាក់។ គេគឺជាអ្នកដែលមិនយល់ព្រមទទួលស្គាល់ថាហូឡូខសត៍ពិតជាបានកើតឡើងមែន ហើយទើបនឹងតែត្រូវបានដោះលែងពីពន្ធនាគារ។ ខ្ញុំបានបដិសេធ។ ខ្ញុំអាចនិយាយតែអំពីអ្វីដែលខ្ញុំបានឆ្លងកាត់ ខ្ញុំមិនអាចបញ្ចុះបញ្ចូលអ្នកដែលមិនជឿខ្ញុំទេ។ នៅពេលដែលពួកគេប្រកែកថាគ្មាននរណាម្នាក់បានឃើញបន្ទប់ផ្សែងពុលពីខាងក្នុងនោះ ខ្ញុំបានត្រឹមតែយល់ស្របតែប៉ុណ្ណោះ ពីព្រោះនេះគឺជាការពិត មិនមាននរណាម្នាក់ធ្លាប់ឃើញបន្ទប់ផ្សែងពុលពីខាងក្នុងនោះទេពីព្រោះគ្មាននរណាម្នាក់ដែលបានចូលទៅក្នុងបន្ទប់ផ្សែងពុលនោះ ហើយមានជីវិតចេញមកខាងក្រៅនោះទេ។

វាគឺពិតជាមានការលំបាកក្នុងការផ្លាស់ប្តូរផ្នត់គំនិតរបស់ណាហ្ស៊ីនិយម ប៉ុន្តែអ្វីដែលសំខាន់នោះគឺការអប់រំយុវវ័យមុនពេលដែលពួកគេធ្លាក់ចូលទៅក្នុងមនោគមវិជ្ជានៃការស្អប់ខ្ពើម។ អប់រំអ្នកដែលចូលរួមជាមួយណាហ្ស៊ីព្រោះគិតថាគឺជាគំនិតមួយដែលសប្បាយ។ តើយុវវ័យអាចទទួលយកអ្វីដែលបានកើតឡើងនៅហូឡូខសត៍មកដាក់ក្នុងបេះដូងរបស់ខ្លួនដែរឬទេ? តើវាអាចរារាំងពួកគេមិនឲ្យចូលរួមជាមួយក្រុមណាហ្ស៊ីដែលទាក់ទាញពួកគេតាមរយៈវិធីផ្សេងៗ ដូចជា ចម្រៀងតន្ត្រីស្រា និងដំណើរផ្សងព្រេងដែរឬទេ?







ពិព័រណ៍រូបថតនៅ សារមន្ទីរ ស្តុតថូហ្វ ក្នុងទីក្រុងដាស្គុំនៃប្រទេសប៉ូឡូញ។ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីលើកជាឧទាហរណ៍ថាការអប់រំអ្នកដែលបានចូលរួមជាមួយណាហ្ស៊ីយ៉ាងស្មោះស្ម័គ្រ ម្នាក់មានការលំបាកយ៉ាងដូចម្តេច ខ្ញុំនឹងប្រាប់អំពីរឿងរបស់ជូឌីត អ្នករស់រានមានជីវិតម្នាក់ដែលបានជួបជាមួយនឹងជនអនាមិកណាហ្ស៊ីក្មេងខ្ចីម្នាក់ដែលបានដើរចែកខិត្តប័ណ្ណសរសេរថា " អូសឈ្វិចមិនដែលកើតឡើងនោះទេ" ។ ជូឌីត បានដើរទៅរកក្មេងម្នាក់នោះហើយសួរថា តើក្មេងម្នាក់នោះអាចដឹងបានដោយរបៀបណា ពីព្រោះគេមានវ័យក្មេងណាស់នៅពេលដែលរឿងនោះបានកើតឡើង។ ណាហ្ស៊ីក្មេងខ្ចីម្នាក់នោះឆ្លើយថាខ្លួនបានឮវាមកពីសាស្ត្រាចារ្យល្បីឈ្មោះម្នាក់។ ជូឌីតបានលាត់ដៃអាវរបស់ខ្លួនដើម្បីបង្ហាញលេខសាក់នៅលើដៃ A-51792។ ក្មេងណាហ្ស៊ីម្នាក់នោះសើចហើយនិយាយថា ជូឌីតអាចធ្វើបែបនេះដោយខ្លួនឯងបាន។

## តើអ្នកអាចអត់ឱនទោសបានដែរឬទេ?

នេះគឺជាសំណួរមួយដែលខ្ញុំតែងតែគិតដល់រហូតទាល់តែខ្ញុំដឹងថាខ្ញុំមិនចាំបាច់គិតអំពីវានោះទេ។ អ្វីដែលកើតឡើងហើយមិនអាចកែប្រែបានទេ។ ពេលវេលាក៏មិនអាចវិលត្រឡប់ក្រោយបានដែរ ចំណែកឯអ្នកដែលបានស្លាប់ហើយក៏មិនអាចមានជីវិតវិញបានដែរ។ ថ្ងៃនេះគឺសម្រាប់អនាគតកាល។ អ្វីដែលយើងអាចធ្វើថ្ងៃនេះបាន គឺធ្វើកិច្ចការណាដែលមិនធ្វើឲ្យព្រឹត្តិការណ៍នេះកើតឡើងបានម្តងទៀត។

## តើអ្នកបានធ្វើដំណើរត្រឡប់ទៅស្រុកកំណើតវិញដែរឬទេ?

ខ្ញុំត្រូវស៊ូទ្រាំជាមួយនឹងសុបិនអាក្រក់របស់ខ្ញុំអស់រយៈពេលយ៉ាងយូរអង្វែង។ នៅពេលដែលខ្ញុំរៀបការហើយមានកូន ខ្ញុំបានយល់សប្តិថាខ្ញុំកំពុងតែនៅស៊ីហ្គេតឯក្រុមគ្រួសាររបស់ខ្ញុំនៅទីក្រុងស្តុកខុល។ ខ្ញុំគិតថាខ្ញុំនឹងមិនហ៊ានត្រឡប់ទៅទីនោះម្តងទៀតទេ។ ប៉ុន្តែពេលវេលាបានកន្លងផុតទៅហើយ នៅពេលដែលកូនៗរបស់ខ្ញុំបានធំដឹងក្តីពួកគេចាប់ផ្តើមសួរសំណួរជាច្រើននៅពេលដែលបានដឹងអំពីរឿងរ៉ាវដែលកើតឡើងមកលើគ្រួសាររបស់យើង។ យ៉ាងណាមិញ កូនៗរបស់ខ្ញុំមិនមានជីដូនជីតា អ៊ំ មីង បុគ្រួសារ ដែលអាចចំណាយពេលវេលាជាមួយនៅពេលវិស្សមកាលដូចជាមិត្តរួមថ្នាក់ដ៏ទៃទៀតរបស់ខ្លួននោះទេ។ ពួកគេក៏មិនមានថ្ងៃឈប់សម្រាកដែលគ្រួសារទាំងមូលបានជួបជុំគ្នាដែរ។ នៅពេលដែលកូនៗរបស់ខ្ញុំឈានចូលវ័យជំទង់ ខ្ញុំបានសម្រេចចិត្តថាយើងនឹងធ្វើដំណើរទៅស៊ីហ្គេតម្តងទៀត។ ធ្វើបែបនេះពួកគេអាចនឹងមានអារម្មណ៍ជិតស្និទ្ធជាមួយនឹងដើមកំណើតរបស់ខ្លួនហើយអាចយល់ដឹងទាំងអស់គ្នាអំពីស្ថានភាពរបស់យើង។ នៅពេលដែលធ្វើដំណើរ គឺពិតជាមានភាពពិបាកខ្លាំងណាស់ក្នុងការប្រាប់កូនៗរបស់ខ្ញុំអំពីសមាជិកគ្រួសារដែលយើងបានបាត់បង់។ ខ្ញុំមិនចង់ឲ្យពួកគេឃើញថាខ្ញុំពិបាកចិត្តនោះទេ។ ដូច្នេះហើយទើបខ្ញុំនិយាយហាក់បីដូចជាខ្ញុំជាអ្នកទេសចរណ៍ម្នាក់ដែលមកធ្វើដំណើរកំសាន្តនៅបរទេស។ ខ្ញុំមិនបានអនុញ្ញាតឲ្យខ្លួនឯងមានអារម្មណ៍អ្វីទាំងអស់។ ខ្ញុំមិនទាន់យល់ច្បាស់ថាការរៀបរាប់អំពីការពិតផ្តល់ចំណេះដឹងតែផ្នែកបញ្ញាដែលអាចជ្រាបដល់ត្រឹមតែស្មារតីរបស់មនុស្សម្នាក់ៗតែប៉ុណ្ណោះ។

សម្រាប់ការយល់ដឹងច្បាស់ដោយអារម្មណ៍រឿងរ៉ាវទាំងនោះត្រូវតែជ្រាបឲ្យដល់បេះដូងរបស់មនុស្សម្នាក់ៗ។



ពិព័រណ៍រូបថតនៅ សារមន្ទីរស្តុតថូហ្វ ក្នុងទីក្រុងដាស្គ័នៃប្រទេសប៉ូឡូញ។ (សូវិចិត្រ មេត្តា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

កូនៗរបស់ខ្ញុំបានចម្លើយសម្រាប់សំណួររបស់ខ្លួន ប៉ុន្តែខ្ញុំមិនបានដឹងអំពីអ្វីដែលពួកគេបានគិតនោះទេ។ ខ្ញុំគ្មានបទពិសោធន៍ពិតប្រាកដអំពីការទៅលេងផ្ទះកុមារភាពរបស់ខ្លួននោះទេ ហើយនោះគឺជាមូលហេតុដែលខ្ញុំបានសម្រេចចិត្តធ្វើដំណើរទៅទីនោះម្តងទៀត។ ដើម្បីធ្វើធម្មយាត្រាជាមួយប្អូនស្រីខ្ញុំនិងទៅទស្សនាកន្លែងទាំងអស់ដែលមានសារសំខាន់ចំពោះយើងដើម្បីឲ្យអារម្មណ៍ទាំងនោះអោបក្រសោបយើងហើយធ្វើឲ្យយើងយំចេញមកក្រៅ។ នៅរដូវក្តៅបន្ទាប់យើងក៏បានចេញដំណើរ។ ដំណើរកំសាន្តលើកដំបូងរបស់យើង គឺទៅផ្នែកកណ្តាលនៃទីក្រុងដែលខឡានត្រូវបានជំនួសទៅដោយហាងទំនិញជាច្រើន។ នេះហាក់បីដូចជាការចូលរោងភាពយន្តដើម្បីមើលការសម្តែងដែលខ្ញុំធ្លាប់បានឃើញម្តងរួចទៅហើយ។ ទេសភាពគឺនៅដដែល ប៉ុន្តែតួអង្គទាំងអស់ត្រូវបានផ្លាស់ប្តូរ។ ឆាកតន្ត្រីនៅក្នុងខឡាននៅតែមានប៉ុន្តែត្រូវបានកសាងថ្មី។ ផ្លាកនៅខាងក្រៅហាងទំនិញត្រូវបានផ្លាស់ប្តូរ។ ជំនួសទៅដោយឈ្មោះរបស់ជនជាតិជ្វីហ្វ ឥឡូវនេះ គឺពោរពេញទៅដោយឈ្មោះជនជាតិរូម៉ានី។ ខ្ញុំបានដើរចូលទៅក្នុងហាងមួយដែលពីមុនធ្លាប់ជាកម្មសិទ្ធិរបស់ពូខ្ញុំ។ នៅពេលនេះវាគឺគ្រប់គ្រងដោយម្ចាស់ដែលខ្ញុំមិនស្គាល់ និងលក់ក្រណាត់ដូចដែលខ្ញុំធ្លាប់បានជ្រើសរើសនៅក្នុងហាងរបស់ពូខ្ញុំ។ ខ្ញុំដើរជុំវិញទីក្រុង ហើយបានឃើញមីងរបស់ខ្ញុំនៅជ្រុងម្ខាងនៃផ្លូវ ប៉ុន្តែពេលខ្ញុំដើរទៅរកគាត់ៗ គឺជាមនុស្សផ្សេងទៅវិញទេ។

ផ្ទះចាស់របស់យើងនៅដដែល ប៉ុន្តែម្ចាស់ផ្ទះបានមើលមកយើងដោយសង្ស័យនៅពេលដែលយើងនិយាយថាធ្លាប់រស់នៅទីនេះក្នុងអំឡុងពេលកុមារភាពរបស់យើង។ ពួកគេភ័យខ្លាចថាយើងចង់យកផ្ទះវិញ ប៉ុន្តែពួកគេនៅតែអនុញ្ញាតឲ្យយើងចូលទៅក្នុងនិងដើរមើលជុំវិញ។ នៅខាងក្នុងខ្ញុំមិនបានឃើញអ្វីដែលនៅចំពីមុខខ្ញុំនោះទេ។ ផ្ទុយទៅវិញខ្ញុំបានឃើញបន្ទប់គេងរបស់ឪពុកម្តាយខ្ញុំដូចដែលនៅពេលនោះ។ នៅក្នុងបន្ទប់របស់ខ្ញុំៗបានឃើញវត្ថុដែលខ្ញុំស្រឡាញ់ជាងគេ គឺព្យាណូនិងសៀវភៅ។ ខ្ញុំស្ទើរតែអាចព្ញសំឡេងផ្លែរបស់យើងព្រុសនៅខាងក្រៅទីធ្លា។ លីវីនិងខ្ញុំបានស្រក់ទឹកភ្នែកជាច្រើន។ យើងប្រៀបបានដូចជាកុមារដែលបានចាកចេញពីផ្ទះដោយគ្មានការអនុញ្ញាត ហើយឥឡូវនេះគឺកំពុងតែភ្លក់រសជាតិនៃផលវិបាកបន្ទាប់ពីនោះ។ ការធ្វើដំណើរនេះនាំមកនូវផលវិជ្ជមានជាច្រើន។ សុបិនអាក្រក់របស់ខ្ញុំបានកាត់បន្ថយ។ ទោះបីជាសុបិនអាក្រក់ទាំងនោះមិនបានបាត់ទៅណា ប៉ុន្តែជារឿយៗខ្ញុំឈប់ភ្ញាក់ឡើងដោយបែកញើសជោគខ្លួន និងជាមួយអារម្មណ៍ថាកូនរបស់ខ្ញុំកំពុងនៅប្រទេសស៊ុយអែតហើយខ្ញុំនៅឆ្ងាយពីពួកគេ នឹងមិនអាចឃើញពួកគេម្តងទៀតទេ។ នេះធ្វើឲ្យខ្ញុំយល់ថា មនុស្សគឺត្រូវតែប្រឈមមុខនឹងភាពភ័យខ្លាច។ មានតែបែបនោះទេទើបយើងអាចយកឈ្នះភាពភ័យខ្លាចរបស់ខ្លួនបាន។

## តើអ្នកបានគិតអំពីពេលវេលានៅក្នុងជំរំជាញឹកញាប់ដែរឬទេ?

ខ្ញុំបានបង្រៀនអំពីពេលដែលខ្ញុំនៅតាមជំរំផ្សេងៗគ្នាស្ទើរតែជារៀងរាល់ថ្ងៃចាប់តាំងពីអំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ហើយរាល់ពេលដែលខ្ញុំនិយាយអំពីវា ខ្ញុំមានអារម្មណ៍ថាធូរចិត្ត។ ទោះបីជាពិបាកខ្លាំងប៉ុន្តែវាបាននាំទៅរកអ្វីដែលល្អ និងបានក្លាយទៅជាវិធីមួយសម្រាប់ការជាសះស្បើយអំពីការប៉ះទង្គិចផ្លូវចិត្តរបស់ខ្ញុំ។ អ្នករស់រានមានជីវិតភាគច្រើនមានការពិបាកក្នុងការនិយាយអំពីអ្វីដែលបានកើតឡើងចំពោះខ្លួន។ ដូច្នេះហើយវាបានក្លាយទៅជាសេចក្តីឈឺចាប់មួយដែលមិនអាចប្រែប្រួលបាន ពីព្រោះតែខ្ញុំធ្វើការជារៀងរាល់ថ្ងៃដោយនិយាយអំពីវា និងសរសេរសៀវភៅអំពីវាៗមិនមានតទៅទៀតទេនៅពេលដែលខ្ញុំឈប់ធ្វើការ។ សេចក្តីឈឺចាប់ទាំងនោះមិនមានវត្តមាននៅក្នុងស្មារតីរបស់ខ្ញុំទៀតនោះទេ ទោះបីជានៅតែកប់នៅក្នុងដួងចិត្តរបស់ខ្ញុំហើយអាចលេចចេញមកក្រៅម្តងទៀតគ្រប់ពេលណាក៏ដោយ។

ប្រសិនបើខ្ញុំកំពុងតែដើរតាមផ្លូវ ហើយឮសំឡេងឆ្កែព្រុសនៅពីក្រោយ ខ្ញុំៗនឹងមានអារម្មណ៍ថាខ្លួនឯងបានវិលត្រលប់ទៅជំរំវិញភ្លាមៗដែលមានក្រុមក្មេងស្រីដើរជាប្រាំជួរនៅតាមផ្លូវទៅធ្វើការងារ និងមានកងការពារណាហ្ស៊ីដើរពីខាងក្រោយជាមួយសត្វឆ្កែ។ ប្រសិនបើមាននរណាម្នាក់ដួលចេញពីជួរ កងការពារណាហ្ស៊ីនោះនឹងឲ្យឆ្កែហក់មកខាំអ្នកនោះ។ ខ្ញុំនៅតែអាចចងចាំអំពីអារម្មណ៍ភ័យខ្លាច និងខ្យល់បក់ត្រជាក់ដែលប៉ះសម្លៀកបំពាក់ដ៏ស្តើងរបស់ខ្ញុំ និងអារម្មណ៍ឈឺចាប់នៅលើជើងដែលបណ្តាលមកពីស្បែកជើងរបស់ខ្ញុំ។ នៅពេលខ្លះទៀតខ្ញុំស្រមៃឃើញបំពង់ផ្សែង ហើយមានអារម្មណ៍ឈឺចាប់នៅពេលដែលខ្ញុំដឹងថាបំពង់ផ្សែងនៅក្នុងអូសឈ្វិចនោះគេប្រើសម្រាប់ធ្វើអ្វី។

ពេលខ្ញុំរស់នៅជាមួយប្អូនស្រី យើងកម្រនិយាយគ្នាអំពីហូឡូខស៍ណាស់។ ប៉ុន្តែអ្វីដែលធ្វើឲ្យខ្ញុំនឹកគិតឃើញអំពីអតីតកាល វាក៏បែបនោះសម្រាប់នាងដែរ។ យើងគ្រាន់តែមើលមុខគ្នាទៅវិញទៅមកតែប៉ុណ្ណោះដើម្បីដឹងថាយើងទាំងពីរនាក់កំពុងគិតអំពីអ្វី។

ខ្ញុំបានជួបណាហ្ស៊ីថ្មីនៅដើមទសវត្សរ៍ឆ្នាំ១៩៩០ នៅពេលដែលគេត្រូវបានកាត់ទោសពីបទបរិហាកេរ្តិ៍។ បុរសម្នាក់នោះបានសរសេរសំបុត្រស្អប់ខ្ពើមផ្ញើទៅអ្នករស់រានមានជីវិតជាច្រើននាក់រួមទាំងខ្ញុំទៀតផង។ ខ្ញុំត្រូវបានតុលាការកោះហៅ ដើម្បីធ្វើជាសាក្សីហើយបានស្នើឲ្យនិយាយអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់ខ្ញុំ។ បុរសម្នាក់នោះត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារ ប៉ុន្តែសូម្បីតែនៅទីនោះក៏គេនៅតែបន្តផ្ញើសំបុត្រស្អប់ខ្ពើមនោះមកខ្ញុំដដែល។ ខ្ញុំបានប្រគល់សំបុត្រនោះឲ្យទៅប៉ូលីស។ អ្វីដែលកើតឡើងបន្ទាប់ខ្ញុំមិនបានដឹងនោះទេ។ នាយកសាលារៀននៅទីក្រុងតាប៊ីបានហៅខ្ញុំឲ្យទៅបង្រៀននៅទីនោះ ពីព្រោះតែមានក្មេងខូចៗដែលវាយតប់គ្នា និងបានគូររូបសញ្ញាណាហ្ស៊ីនៅលើជញ្ជាំងសាលារៀន។ បន្ទាប់ពីការបង្រៀនរបស់ខ្ញុំដែលជារឿងធម្មតាដែលក្មេងប្រុសៗទាំងនោះមិនមកចូលរួម មានក្មេងស្រីមួយចំនួនបានមករកខ្ញុំ ហើយនិយាយអរគុណខ្ញុំ។ ក្មេងស្រីទាំងនោះគិតថា គឺពិតជាមានសារសំខាន់ខ្លាំងណាស់ក្នុងការស្តាប់អំពីរឿងរ៉ាវរបស់ខ្ញុំ ហើយឥឡូវនេះពួកគេនឹងមិនទៅលេងជាមួយក្មេងប្រុស ទាំងនោះទៀតនោះទេ។ នៅពេលដែលក្មេងប្រុស ទាំងនោះបានបាត់បង់ការគាំទ្រ សាលារៀនបានវិលត្រឡប់ទៅរកភាពស្ងប់ស្ងាត់វិញ ហើយរូបសញ្ញាណាហ្ស៊ីក៏បាត់ទៅជាមួយដែរ។ ខ្ញុំបានទទួលរងការប្រមាថ និងសំបុត្រគំរាមកំហែងជាច្រើនឆ្នាំមកហើយ។ ជាធម្មតាខ្ញុំតែងតែប្រគល់សំបុត្រទាំងនោះទៅឲ្យប៉ូលីស។ សំបុត្រទាំងនោះមិនអាចបំភ័យខ្ញុំបានទេ។ គោលបំណងរបស់អ្នកសរសេរសំបុត្រទាំងនោះគឺគ្រាន់តែដើម្បីបង្កើតឲ្យមានភាពភ័យខ្លាចតែប៉ុណ្ណោះ។

## តើអ្នកស្អប់ជនជាតិអាល្លឺម៉ង់ដែរឬទេ?

ក្រុមការងាររបស់យើងទើបតែត្រឡប់មកជំរំវិញបន្ទាប់ពីចេញទៅធ្វើការនៅក្រោមភ្លៀងដ៏ធំមួយនៅតាមសំណង់បាក់បែក។ ស្បែកជើងគ្នាយើងមួយចំនួនមានសភាពចាស់ និងដាច់រហែក។ នៅពេលនោះមានពាក្យចចាមអារ៉ាមថាមានកញ្ចប់ដឹកអីវ៉ាន់ថ្មីបានចូលមកដល់។ តើអ្នកណាអាចយកបានអីវ៉ាន់ថ្មីនោះ? ឃ្លានហើយរងា

ជាមួយនឹងជើងដែលសើមនៅក្នុងស្បែកជើងដែលមានតែឈ្មោះនោះ ខ្ញុំបានដើរទៅរកប្រធានជំរំ ហើយសួរថា តើខ្ញុំអាចបានស្បែកជើងថ្មីមួយគូដែរឬទេ។ ប្រធានជំរំបានសម្លឹងមើលមកខ្ញុំដោយទឹកមុខចំអកឡកឡឺយហើយទះកំភ្លៀងខាងឆ្វេងរបស់ខ្ញុំយ៉ាងខ្លាំងរហូតដល់ខ្ញុំហ៊ឹងស្ទើកត្រចៀក។ ខ្ញុំស្ទើរតែដួលទៅហើយនៅពេលដែលមួយកំភ្លៀងក្រោយទៀតមកលើថ្ពាល់ស្ដាំរបស់ខ្ញុំដែលជំនួសឲ្យខ្ញុំមានលំនឹងឡើងវិញ វាបានធ្វើឲ្យខ្ញុំដួលទៅលើដី។ ការឈឺចាប់ត្រូវបានគ្របដណ្ដប់ដោយការស្អប់ខ្ពើម ខ្ញុំចង់ហក់ទៅរកប្រធានជំរំនោះហើយវាយគេម្ដងហើយម្ដងទៀត។ ប៉ុន្តែខ្ញុំមិនហ៊ាននោះទេ។ គេមានអំណាចជាងខ្ញុំ។

មកពីប្រទេសហុងគ្រី ខ្ញុំមានគោលដៅចំនួនពីរ នោះគឺស្អប់ជនជាតិអាល្លឺម៉ង់និងជនជាតិហុងគ្រី។ ជនជាតិអាល្លឺម៉ង់ គឺជាអ្នកដែលធ្វើទារុណកម្មយើង ប៉ុន្តែជនជាតិហុងគ្រី គឺជាអ្នកដែលបានប្រគល់យើងឲ្យទៅឃាតករ។ បន្ទាប់ពីសង្គ្រាមបានបញ្ចប់ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនដើម្បីបញ្ឈប់ការស្អប់មួយនេះ។ គួរឲ្យចម្លែកដែលខ្ញុំស្អប់ជនជាតិហុងគ្រី យូរជាងពេលដែលខ្ញុំស្អប់ជនជាតិអាល្លឺម៉ង់។ រូបភាពនៃមួកក្រណាត់របស់ប៉ូលិសហុងគ្រីនឹងតាមលងបន្លាចនៅក្នុងសុបិនអាក្រក់របស់ខ្ញុំជានិច្ច។

ខ្ញុំអាចរួចផុតពីសុបិនអាក្រក់នេះបានដោយសារតែជនអន្តោប្រវេសន៍ជនជាតិហុងគ្រីម្នាក់ដែលខ្ញុំបានជួបកាលពីប៉ុន្មានឆ្នាំមុន។ គាត់បានប្រាប់ខ្ញុំថា គាត់បានកើតនៅភូមិតូចមួយនៅ ហុងគ្រី-ភូស្តា ហើយគាត់មិនដែលបានឃើញជនជាតិជ្វីហ្វទេ រហូតទាល់តែគាត់បានមកដល់ប្រទេសស៊ុយអែត។ ប៉ុន្តែគាត់បានដឹងថាជនជាតិជ្វីហ្វគឺត្រូវតែស្អប់ខ្ពើមព្រោះពួកគេបានធ្វើឲ្យព្រះយេស៊ូស្លាប់។ គាត់បានរៀនអំពីរឿងនេះមុនគាត់ចេះអានអក្សរទៅទៀត។ គាត់រៀនអំពីរឿងនេះមកពីបុព្វជិតគ្រិស្តសាសនាម្នាក់នៅសាលារៀនរៀងរាល់ថ្ងៃអាទិត្យ។

ខ្ញុំបានសញ្ជឹងគិតហើយទីបំផុតអាចមើលឃើញជ្រុងម្ខាងទៀតនៃកាក់។ ខ្ញុំចាប់ផ្តើមដឹងថាគឺមិនមែនជាប្រទេសជិតខាងរបស់យើងនៅស៊ីហ្គេតនោះទេ ដែលបាននាំយើងទៅរកទូរថភ្លើង ប៉ុន្តែគឺជាប៉ូលិសវ័យក្មេងទៅវិញទេដែលចិញ្ចឹមនិងបណ្តុះនូវគំនិតស្អប់ខ្ពើម។ អ្នកដទៃទៀតដែលរស់នៅស៊ីហ្គេត ប្រហែលជាមិនមានអារម្មណ៍រីករាយក្នុងការកម្ចាត់យើងចោលនោះទេ។ អ្នកជិតខាងរបស់យើងខ្លះបានព្យាយាមជួយយើង។ ជាងកាត់សក់ម្ដាយរបស់ខ្ញុំបានប្រឆាំងនឹងការហាមឃាត់មិនឲ្យចូលមកក្នុងហ្គេតូដោយបានមកសួរសុខទុក្ខយើងនិងយកគ្រឿងទេសមួយចំនួនមកឲ្យ។

សេចក្ដីស្អប់ខ្ពើម គឺជាប្រតិកម្មស្វ័យប្រវត្តិមួយនៅពេលដែលនរណាម្នាក់ធ្វើទង្វើមិនល្អអ្វីមួយទៅលើនរណាម្នាក់ផ្សេងទៀត។ ប៉ុន្តែយើងមិនអាចទទួលបានជោគជ័យជាមួយនឹងសេចក្តីស្អប់ខ្ពើមនោះទេ ពីព្រោះឥទ្ធិពលរបស់វាអាចវាយបកត្រឡប់មកវិញបាន។ សេចក្តីស្អប់ខ្ពើមមិនបានប៉ះពាល់ដល់អ្នកដែលត្រូវគេស្អប់នោះទេ ប៉ុន្តែអ្នកដែលស្អប់គេទៅវិញទេដែលមានអារម្មណ៍មិនល្អ។ នេះបង្កឲ្យមានអារម្មណ៍សងសឹកគ្នាទៅវិញទៅមកហើយនៅពេលនោះអ្នកដែលស្អប់គេនឹងត្រូវបានគេស្អប់វិញ ហើយវានឹងក្លាយទៅជាវដ្តនៃការស្អប់ខ្ពើមដែលគ្មានទីបញ្ចប់។ យើងត្រូវការពេលវេលាមុនពេលដែលយើងអាចលះបង់សេចក្តីស្អប់ខ្ពើមបាន យើងត្រូវសញ្ជឹងគិតអំពីអ្វីដែលបានកើតឡើងដើម្បីបញ្ចប់ការស្អប់ខ្ពើមនោះ។ បន្ទាប់មកទើបយើងអាចរស់នៅក្នុងជីវិតមួយដែលគ្មានភាពជូរចត់បាន។ នេះគឺមិនមែនជាសំណួរអំពីការអត់ឱននោះទេ។ ខ្ញុំមិនអាចអត់ទោសជំនួសអ្នកដែលត្រូវបានគេសម្លាប់បាននោះទេ ដូចដែលអ្នកប្រមាញ់ណាហ្ស៊ីដ៏ល្បីល្បាញលោក សាយម៉ុន វៀសេនស៉ាល បាននិយាយដូច្នេះដែរ។ ប៉ុន្តែយើងអាចរៀនរស់នៅជាមួយអ្វីដែលកើតឡើងបាន។ យើងអាចរស់នៅជាមួយអតីតសត្រូវ ហើយទទួលស្គាល់គ្នាទៅវិញទៅមក។ យើងគួរយល់ដឹងឲ្យបានច្បាស់ថា យើងនឹងមិនអាចដឹងបានទេថាខ្លួនឯងនឹងមានប្រតិកម្មយ៉ាងណាក្នុងស្ថានភាពដែលងាយធ្វើឲ្យឈឺចាប់។ ពេលដែលខ្ញុំនៅក្នុងជំរំ ខ្ញុំស្អប់ជនជាតិអាល្លឺម៉ង់ទាំងអស់ ខ្ញុំមានអារម្មណ៍សងសឹក។ ប្រសិនបើខ្ញុំមានឱកាសខ្ញុំប្រហែលអាចនឹងធ្វើការសងសឹក។ ប៉ុន្តែបន្ទាប់ពីការរំដោះ ខ្ញុំនិងអ្នកដទៃទៀតជាច្រើនបានយល់ថា ការសងសឹកនឹងធ្វើឲ្យយើងមានកម្រិតស្មើគ្នាទៅនឹងឃាតករ។ បន្ទាប់ពីការរំដោះនៅបែលជិន-បឺសិន ទាហានអង់គ្លេសបានប្រមូលអតីតអ្នកយាមរបស់យើងដាក់នៅលើឡាន ហើយបានបើកជុំវិញជាមួយពាក្យប្រកាសថា «នៅទីនេះមានឃាតកររបស់អ្នកៗអាចធ្វើតាមចិត្តរបស់អ្នកបាន និងធ្វើការសងសឹក» ។ មិនមានមនុស្សជាច្រើនទេដែលធ្វើដូច្នេះ។





ភាគច្រើន គឺគ្រាន់តែដើរចេញឆ្ងាយហើយសប្បាយចិត្តដែលដឹងថាអ្នកយាមទាំងនោះមិនអាចគ្រប់គ្រងលើយើងទៀតនោះទេ។

សម្រាប់យើងទាំងអស់គ្នាការសងសឹកនោះ គឺយើងដែលត្រូវបានសន្មតថានឹងត្រូវសម្លាប់ចោលនៅតែបន្តរស់រានមានជីវិត និងមានក្រុមគ្រួសារថ្មី។ ការសងសឹករបស់យើងគឺ ណាហ្ស៊ីនាពេលអតីតកាលបានបាត់បង់ទៅហើយ។ សព្វថ្ងៃនេះកូនចៅរបស់ពួកគេកាន់តែច្រើនបានស្ដាប់អំពីរឿងរ៉ាវរបស់យើង ហើយក៏កំពុងតែធ្វើសកម្មភាពផ្សេងៗ ដើម្បីឲ្យប្រាកដថាហូឡូខស្ត៍នឹងមិនកើតឡើងម្ដងទៀត។

សព្វថ្ងៃនេះខ្ញុំមានមិត្តភក្តិជាច្រើនដែលជាជនជាតិអាល្លឺម៉ង់ និងជនជាតិហុងគ្រីដែលភាគច្រើនជាកូនៗរបស់ជនល្មើស អ្នកទាំងនោះមានគោលដៅដូចខ្ញុំដែរ។

ជាអកុសល ជួនកាលខ្ញុំនៅតែជួបមនុស្សមួយចំនួនដែលជាថ្មីម្ដងទៀតបានជឿងប់ងល់ទៅលើមនោគមន៍វិជ្ជានៃការស្អប់ខ្ពើម។ អ្នកទាំងនោះមិនស្ដាប់រឿងរ៉ាវរបស់ខ្ញុំនោះទេ ពួកគេគ្រាន់តែនិយាយឡើងវិញនូវឃ្លាដែលពួកគេព្យាយាមផ្សព្វផ្សាយនៅក្នុងចំណោមមនុស្សវ័យក្មេង។ ក្រុមណាហ្ស៊ីថ្មីទាំងនេះត្រូវតែបំបែកចេញឲ្យឆ្ងាយដើម្បីបង្ការកុំឲ្យមានអ្នកចូលរួមកាន់តែច្រើនឡើង។

នៅពេលខ្លះមានមនុស្សមួយចំនួនដែលនៅក្នុងរង្វង់អ្នកស្គាល់គ្នាបាននិយាយដោយមានបុរេវិនិច្ឆ័យអំពីរឿងដែលបានកើតឡើង។ នៅពេលនោះ ខ្ញុំពិតជាចង់សួរថាតើពួកគេសំអាងលើអ្វី? ខ្ញុំចង់ឲ្យអ្នកទាំងនោះពិនិត្យពិច័យលើមតិរបស់ខ្លួនឯងនិងអ្នកដទៃឡើងវិញនិងធ្វើការវិនិច្ឆ័យដោយខ្លួនឯងម្ដងទៀតអំពីការពិត។ ខ្ញុំបានចាប់ផ្ដើមការពិភាក្សាដែលមិនអាចមានលទ្ធផលភ្លាមៗ ប៉ុន្តែប្រសិនបើមានការលើកឡើងជាច្រើនដងខ្ញុំអាចសង្ឃឹមបានថានឹងមានការផ្លាស់ប្តូរមួយ។

## តើអ្នកធ្លាប់បានជួបជាមួយជនល្មើសដែរឬទេ?

បន្ទាប់ពីសង្គ្រាមបានបញ្ចប់ទៅភាពស្អប់ខ្ពើមរបស់ខ្ញុំចំពោះជនជាតិអាល្លឺម៉ង់នៅតែមាន។ ខ្ញុំបានចំណាយពេលអស់ជាច្រើនដើម្បីលះបង់វាចោល។ អ្វីដែលនៅតែមាននោះគឺភាពភ័យខ្លាចដោយមិនដឹងខ្លួន។ នៅក្នុងរយៈពេលពីរទៅបីឆ្នាំបន្ទាប់ពីសង្គ្រាមបានបញ្ចប់ ខ្ញុំបានធ្វើដំណើរតាមរថភ្លើងនៅពេលយប់ដែលធ្វើដំណើរឆ្លងកាត់ប្រទេសអាល្លឺម៉ង់ ហើយក៏បានភ្ញាក់ដឹងខ្លួនដោយបែកញើសជោគពីសុបិនអាក្រក់មួយថា ជនជាតិអាល្លឺម៉ង់ហៀបនឹងព្យួរកខ្ញុំ។ ខ្ញុំភ្ញាក់ឡើងដោយភ័យស្លន់ស្លោ។ ខ្ញុំចំណាយពេលមួយភ្លែតទើបដឹងថា វាគឺគ្រាន់តែជាសុបិនមួយដែលបណ្ដាលមកពីរូបដេកយប់ដែលព័ទ្ធរុំករបស់ខ្ញុំ ។

មុនដំបូងខ្ញុំបានបដិសេធមិននិយាយភាសាអាល្លឺម៉ង់ ឬក៏ធ្វើដំណើរទៅប្រទេសអាល្លឺម៉ង់នោះទេ។ ក្រោយមកនៅពេលដែលខ្ញុំបើកក្រុមហ៊ុនតូចមួយ ខ្ញុំគ្មានជម្រើសច្រើនទេហើយកាន់តែមានភាពពិបាកថែមទៀត។ ខ្ញុំបានសង្កេតមើលទៅមនុស្សគ្រប់គ្នាដែលមានអាយុដំណាលខ្ញុំ ឬចាស់ជាងខ្ញុំ ហើយក៏បានចាត់ទុកអ្នកទាំងនោះថាគឺជាជនល្មើស។ ខ្ញុំមិនដែលអនុញ្ញាតឲ្យខ្លួនឯងចូលរួម នៅក្នុងសន្ទនាណាដែលមានលក្ខណៈជាឯកជនជាមួយអ្នកទាំងនោះទេ។ បែបនេះ គឺជាការដាក់ទោសដោយមិនទាន់បានកាត់ក្តី។ ខ្ញុំបានចំណាយអស់រយៈពេលជាច្រើនឆ្នាំមុនពេលដែលខ្ញុំយល់ថា នេះគឺជាការរើសអើងដែលខ្ញុំយល់ឃើញថាជនជាតិអាល្លឺម៉ង់ទាំងអស់គឺជាជនល្មើស។ ប៉ុន្តែទីបញ្ចប់ ខ្ញុំបានដោះលែងខ្លួនឯងអំពីការសង្ស័យ និងការស្អប់ខ្ពើមទាំងនោះ។ ច្រើនឆ្នាំកន្លងផុតទៅ ខ្ញុំចាប់ផ្តើមទទួលការអញ្ជើញទៅកម្មវិធីជាច្រើននៅក្នុងប្រទេសអាល្លឺម៉ង់ ហើយក៏ឃើញថា គឺកាន់តែមានភាពងាយស្រួលក្នុងការទាក់ទងជាមួយជនជាតិអាល្លឺម៉ង់។ ខ្ញុំថែមទាំងបានធ្វើមិត្តភក្តិជាមួយពួកគេទៀតផង។ ក្នុងចំណោមនោះ គឺមានកូនប្រុសរបស់ជនល្មើសឈ្មោះថាម៉ាទីន បូម៉ាន់ ដែលជាដៃស្ដាំរបស់ហ៊ីត្លែរ។ មិត្តម្នាក់នោះក៏មានឈ្មោះថាម៉ាទីនដែរ។

ដូចជាយុវវ័យដ៏ទៃទៀតដែរ គាត់ក៏ធ្លាប់ជាសមាជិករបស់ហ៊ីត្លែរជូយេន់ ហើយនៅពេលដែលសង្គ្រាមបានបញ្ចប់គាត់កំពុងតែធ្វើការប្រយុទ្ធនៅក្នុងសមរភូមិនៅឡើយ។ គាត់មានភាពលំបាកវេទនាណាស់នៅពេលដែលហ៊ីត្លែរចុះចាញ់សង្គ្រាម។ គាត់មានគម្រោងធ្វើអត្តឃាត ហើយក៏ដើរចូលទៅក្នុងព្រៃជាមួយនឹងកាំភ្លើងមួយដើម និងដោយគ្មានអាហារបរិភោគអស់រយៈពេលជាច្រើនសប្តាហ៍។ ប៉ុន្តែសេចក្តីស្រេកឃ្លានបានធ្វើឲ្យគាត់សម្រេចចិត្តគោះទ្វារផ្ទះស្បូវមួយ។ នោះគឺជាផ្ទះរបស់បុព្វជិតគ្រិស្តសាសនា

ម្នាក់ៗ មិត្តរបស់ខ្ញុំបានប្រាប់ឈ្មោះផ្សេងរបស់ខ្លួន ហើយបានសុំអាហារដើម្បីបរិភោគ។ នៅពេលដែលបុព្វជិតគ្រិស្តសាសនាម្នាក់នោះសួរនាំ ម៉ាទីនបានឆ្លើយប្រាប់ថា ឪពុករបស់គាត់បានស្លាប់នៅក្នុងសមរភូមិ ចំណែកឯម្តាយរបស់គាត់បានបាត់ខ្លួន។ បុព្វជិតនោះមានចិត្តអាណិតអាសូរគាត់ ហើយក៏អនុញ្ញាតឲ្យគាត់ស្នាក់នៅទីនោះអស់រយៈពេលជាច្រើនឆ្នាំ។ នៅពេលនោះហើយគឺជាលើកដំបូងដែលគាត់បានស្គាល់អំពីសេចក្តីស្រឡាញ់ ហើយវាបានដក់ជាប់នៅក្នុងអារម្មណ៍របស់គាត់ជារៀងរហូត។ គាត់បានដឹងពីភាពខុសគ្នារវាងជីវិតពីរផ្សេងគ្នាដែលគាត់បានរស់នៅ ហើយក៏សម្រេចចិត្តចែកចាយក្តីស្រលាញ់ទៅអ្នកដទៃទៀត។

ម៉ាទីន មិនមែនជាមនុស្សតែម្នាក់ដែលបានដកខ្លួនចេញឆ្ងាយចេញពីអតីតកាលរបស់ខ្លួននោះទេ។ ខ្ញុំបានជួបជនជាតិអាល្លឺម៉ង់ជាច្រើននាក់ដែលខុសប្លែកពីជំនាន់ឪពុកម្តាយរបស់ពួកគេ ហើយអ្នកទាំងនោះមានគោលបំណងក្នុងការកែប្រែកំហុសខុសឆ្គងរបស់ឪពុកម្តាយខ្លួន។

ចៅគីម គឺជាអ្នកជំនួញវ័យក្មេងម្នាក់ដែលរឿងរ៉ាវជីវិតរបស់គាត់បានធ្វើឲ្យខ្ញុំរំជួលចិត្តយ៉ាងខ្លាំង។ គាត់គ្មានឪពុកនោះទេហើយបានជឿជាក់ថា ឪពុករបស់គាត់បានស្លាប់នៅក្នុងសមរភូមិដូចជាអ្នកដទៃទៀតដែលនៅក្នុងជំនាន់នោះដែរ។ ម្តាយរបស់គាត់បានរៀបការជាមួយអតីតទាហានម្នាក់ ហើយមិនយូរប៉ុន្មានក៏មានកូនទៀតផង។ គាត់ធំធាត់ឡើងនៅក្នុងមជ្ឈដ្ឋានដែលពោរពេញទៅដោយសេចក្តីស្រឡាញ់ប៉ុន្តែត្រូវបានលាបពណ៌ដោយគំនិតណាហ្ស៊ីនិយមដែលនៅតែមានឥទ្ធិពលនៅក្នុងគ្រួសាររបស់គាត់ជានិច្ច។ គាត់ចងចាំពាក្យជីដូនរបស់គាត់ដែលបាននិយាយថា "ទោះបីជាយ៉ាងណាក៏ដោយកុំរៀបការជាមួយជនជាតិជ្វីហ្វ"។ គាត់មិនអាចចាំបានទេថានៅពេលណាដែលគាត់បានឮជាលើកដំបូងថាឪពុករបស់គាត់គឺជាជនល្មើស។ គាត់បានសួរជីដូនរបស់គាត់ដែលជាអ្នកបញ្ជាក់អំពីទំនាក់ទំនងរបស់ឪពុកគាត់ជាមួយណាហ្ស៊ី ដែលនៅពេលនោះគឺជាតម្រូវការសម្រាប់ជនជាតិអាល្លឺម៉ង់ទាំងអស់។ ប៉ុន្តែជីដូនរបស់គាត់មិនចង់សារភាពថាឪពុករបស់គាត់បានប្រព្រឹត្តបទល្មើសណាមួយនោះឡើយ។ នៅពេលធំដឹងក្តីឡើងគាត់បានស្តាប់ឮការចោទប្រកាន់ជាញឹកញាប់ថា ឪពុករបស់គាត់គឺជាឧក្រិដ្ឋជនណាហ្ស៊ីម្នាក់ដែលបានរត់គេចខ្លួនចេញពីសំណាញ់យុត្តិធម៌បន្ទាប់ពីសង្គ្រាមបានបញ្ចប់។ គាត់បានគិតថា នោះគឺគ្រាន់តែជាការកុហកហើយបានជួលមេធាវីម្នាក់ដើម្បីបង្ហាញភស្តុតាងឲ្យច្បាស់លាស់។ មេធាវីបានស៊ើបអង្កេត ហើយអ្វីដែលធ្វើឲ្យគាត់អស់សង្ឃឹមខ្លាំង គឺនៅពេលដែលមេធាវីបានបញ្ជាក់ថាការចោទប្រកាន់នោះគឺជាការពិត។ ឪពុករបស់គាត់ធ្លាប់ជាមន្ត្រីកាន់តំណែងធំម្នាក់ដែលទទួលមើលការខុសត្រូវចំពោះការសម្លាប់ជនជាតិជ្វីហ្វនៅព្រំប្រទល់នៅប្រទេសអ៊ុយក្រែន។ នៅពេលសង្គ្រាមបានបញ្ចប់ គាត់បានជំនួយពីវិហារកាតូលិកមួយ ហើយបានរត់គេចខ្លួនទៅប្រទេសអ៊ីតាលីដើម្បីរង់ចាំទិដ្ឋាការចូលទៅក្នុងប្រទេសអាហ្សង់ទីន។ នៅពេលដែលគាត់បានដឹងអំពីរឿងទាំងអស់នេះ គាត់បានកាត់ផ្តាច់ទំនាក់ទំនងទាំងអស់ជាមួយក្រុមគ្រួសារ ហើយបានប្តេជ្ញាចិត្តប្រើជីវិតរបស់គាត់ដើម្បីប្រយុទ្ធប្រឆាំងនឹងណាហ្ស៊ីនិយម។

ខ្ញុំបានជួបបុរសវ័យក្មេងម្នាក់ឈ្មោះថា ហ្រ្វាយរីដ នៅពេលដែលខ្ញុំធ្វើដំណើរទៅសន្និសីទស្តីអំពីសិទ្ធិមនុស្សមួយ។ អំឡុងពេលដែលយើងកំពុងសន្ទនាគ្នា គឺបានបង្ហាញយ៉ាងច្បាស់ថា គាត់ធ្លាប់ជាសមាជិកម្នាក់របស់ហ៊ីត្លែរជូយេន៍។ នៅពេលនេះគាត់កំពុងព្យាយាមស្វែងយល់អំពីអតីតកាលរបស់ខ្លួនដើម្បីទទួលបានចម្លើយឲ្យច្បាស់ពីមូលហេតុដែលធ្វើឲ្យគាត់មិនដែលគិតអំពីខ្លួនឯង ហើយតែងតែស្តាប់បង្គាប់ និងធ្វើតាមអ្វីដែលគេបានបញ្ជា។ គាត់បានសួរអំពីជីវប្រវត្តិរបស់ខ្ញុំហើយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងនៅពេលដែលគាត់ដឹងថា ខ្ញុំធ្លាប់នៅក្នុងជំរំប្រមូលផ្តុំ។ ខ្ញុំមិនចង់ដឹងបន្ថែមអំពីអតីតកាលរបស់គាត់ថា តើគាត់ធ្លាប់ទៅទីណា? ហើយតើគាត់ធ្លាប់បានធ្វើអ្វីខ្លះនោះទេ។ បច្ចុប្បន្ន គាត់បានចូលរួមធ្វើកិច្ចការដូចជាខ្ញុំដែរ ដូចនេះអតីតកាលមិនសំខាន់នោះទេ។ លុះត្រាណាតែអតីតសត្រូវអាចផ្សះផ្សា និងធ្វើការរួមគ្នាសម្រាប់គោលដៅតែមួយ ទើបយើងអាចសង្ឃឹមថានឹងមានអនាគតមួយដ៏ល្អប្រសើរដែលជាអនាគតនៅក្នុងសង្គមប្រកបដោយភាពថ្លៃថ្នូរនិងជីវិតដែលគ្មានភាពស្អប់ខ្ពើម ឬការសងសឹក។





# វែកប្រាក់ដែលបន្សល់ទុកពី សម័យខ្មែរក្រហម

**ហូ ថុនា**

នៅក្នុងរបបខ្មែរក្រហម របស់របរមានតម្លៃរបស់ប្រជាជន រហូតដល់សម្ភារប្រើប្រាស់ប្រចាំថ្ងៃនៅក្នុងផ្ទះ គឺត្រូវបានប្រមូលយកមកដាក់ជារបស់រួមទាំងអស់។ ខ្មែរក្រហមហាមដាច់ខាតមិនឲ្យប្រជាជនរក្សាទុករបស់របរទាំងនេះជាកម្មសិទ្ធិផ្ទាល់ខ្លួនឡើយ ប៉ុន្តែយាយរបស់ខ្ញុំបានលួចលាក់វែកបាយដែលធ្វើពីប្រាក់ទុក ហើយវែកនេះបាននៅសល់រហូតមកដល់សព្វថ្ងៃ។



វែកប្រាក់ ដែលបានបន្សល់ទុកពីរបបខ្មែរក្រហម។
(ហូ ថុនា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

យាយទួតរបស់ខ្ញុំឈ្មោះ ស៊ុំ។ នៅពេលយោធាខ្មែរក្រហមបានចូលមកដល់ភូមិកណ្តាល ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រ តំបន់៥ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាប់ផ្តើមជម្លៀសប្រជាជនចេញ និងបានដុតបំផ្លាញផ្ទះរបស់ប្រជាជនមួយចំនួន រួមទាំងផ្ទះយាយរបស់ខ្ញុំដែរ។ នៅពេលដែលភ្លើងកំពុងឆាបឆេះ យាយទួតរបស់ខ្ញុំបានលួចចូលទៅយកបង្អួចខោអាវ និងវែកបាយធ្វើពីប្រាក់ដែលបានលាក់ទុកនៅក្នុងផ្ទះនោះមកជាមួយ។ ចំណែកទ្រព្យសម្បត្តិនៅក្នុងផ្ទះទាំងប៉ុន្មានត្រូវភ្លើងឆេះគ្មានសេសសល់ឡើយ។ យាយទួតរបស់ខ្ញុំ ម្តាយរបស់ខ្ញុំ និងប្រជាជនដែលរស់នៅក្នុងភូមិកណ្តាលទាំងអស់បានទៅរស់នៅភ្នំកូនដំរី ដែលស្ថិតនៅកណ្តាលវាលស្រែល្ហឹងល្ហើយ។ រយៈពេល១៥ថ្ងៃក្រោយមក ខ្មែរក្រហមបានជម្លៀសគាត់ឲ្យទៅរស់នៅភូមិស្រះខាងកើតវិញ។ បន្ទាប់មក ខ្មែរក្រហមបានដើរប្រមែប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនទាំងអស់មកដាក់ជាកម្មសិទ្ធិរួម។ យាយទួតរបស់ខ្ញុំបានដោះក្រវិលពីត្រចៀកម្តាយរបស់ខ្ញុំ និងគ្រឿងអលង្ការរបស់គាត់ ព្រមទាំងរបររបរប្រើប្រាស់មួយចំនួនទៀតប្រគល់ទៅឲ្យខ្មែរក្រហម លើកលែងតែវែកធ្វើពីប្រាក់របស់គាត់។ យាយទួតរបស់ខ្ញុំបានលាក់វែកប្រាក់នោះនៅក្នុងបង្អួចខោអាវរបស់គាត់បានយ៉ាងល្អ។

មិនយូរប៉ុន្មាន ខ្មែរក្រហមបានជម្លៀសគ្រួសារយាយទួត និងម្តាយរបស់ខ្ញុំទៅរស់នៅភូមិត្រពាំងវែង ដែលជាភូមិមួយបង្កើតឡើងដោយយោធាខ្មែរក្រហម និងមានចម្ងាយមិនសូវឆ្ងាយពីភូមិកណ្តាលឡើយ។ ភូមិត្រពាំងវែងនេះមានព្រៃដុះព័ទ្ធជុំជិត។

នៅពេលនោះ ខ្មែរក្រហមបានបែងចែកការងារឲ្យម្តាយរបស់ខ្ញុំកាប់ដើមទន្ទ្រានខែត្រ និងរើសអាចម៍គោ



ឆ្នាំងបាយដែលត្រូវបានបន្សល់ទុកពីរបបខ្មែរក្រហម។
(ហូ ថុនា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដើម្បីធ្វើជីដាក់ស្រែ។ ចំណែកយាយទួតរបស់ខ្ញុំមានតួនាទីមើលថែក្មេងតូចៗ ដែលឪពុកម្តាយរបស់ក្មេងៗទាំងនោះ ត្រូវបានខ្មែរក្រហមចាត់តាំងឲ្យទៅធ្វើការនៅវាលស្រែឆ្ងាយពីភូមិ។

នៅអំឡុងឆ្នាំ១៩៧៦ យាយទួតរបស់ខ្ញុំចាប់ផ្តើមកើតជំងឺហើមដោយសារមិនមានអាហារហូបគ្រប់គ្រាន់។ យាយរបស់ខ្ញុំបានដើររកឫសឈើមកដាំធ្វើថ្នាំ ហើយស្រាប់តែពេលនោះ មានប្រធានចុងភៅនៅក្នុងសហករណ៍រួមឈ្មោះ ឈុន់ បានតាមទាន់ពេលគាត់កំពុងតែស្ងោរថ្នាំដឹក។ ប្រធានចុងភៅបានយកឆ្នាំងដែលកំពុងស្ងោរថ្នាំនោះទៅចាក់ចោល និងបានព្រមានយាយទួតរបស់ខ្ញុំថា «អង្គការមិនអនុញ្ញាតឲ្យដាំថ្នាំដឹកដោយខ្លួនឯងឡើយ»។ យាយរបស់ខ្ញុំនៅស្ងៀមមិនតបតឡើយ ប៉ុន្តែគាត់មិនពេញចិត្តទង្វើរបស់ប្រធានចុងភៅដែលប្រព្រឹត្តមកលើគាត់ និងការដឹកនាំរបស់ខ្មែរក្រហមនៅក្នុងភូមិឡើយ។ ក្រោយមកដោយសារជំងឺយាយរបស់ខ្ញុំកាន់តែធ្ងន់ធ្ងរ មីងរបស់ខ្ញុំក៏បានសម្រេចចិត្តយកមាស២ជី ទៅដោះដូរយកអង្ករពីប្រជាជនក្នុងភូមិមកដាំបាយឲ្យគាត់ហូប។ នៅអំឡុងពេលនោះមាស២ជី ដូរបានអង្ករតែ៥កំប៉ុងប៉ុណ្ណោះ។ ប៉ុន្តែយាយទួតរបស់ខ្ញុំមិនព្រមហូបបាយនោះទេ ដោយគាត់និយាយទៅកាន់មីង និងម្តាយរបស់ខ្ញុំថា «យាយមិនចង់រស់នៅក្នុងសង្គមបែបនេះតទៅទៀតទេ»។ ពីមួយថ្ងៃទៅមួយថ្ងៃ យាយទួតរបស់ខ្ញុំកាន់តែទ្រុឌទ្រោម ហើយបានស្លាប់នៅចុងឆ្នាំ១៩៧៦។

បន្ទាប់ពីយាយទួតរបស់ខ្ញុំស្លាប់ទៅ ម្តាយរបស់ខ្ញុំបានយកវែកដែលគាត់បានលួចលាក់ទុកមករក្សាទុកបន្តទៀត។ ម្តាយរបស់ខ្ញុំបានយកវែកប្រាក់នេះលាក់ទុកនៅក្នុងបង្អេចខោអាវរបស់គាត់ ព្រោះខ្លាចខ្មែរក្រហមមកឆែកឆេររកឃើញ។ រហូតដល់របបខ្មែរក្រហមត្រូវបានផ្តួលរំលំដោយកងទ័ពស្ម័គ្រចិត្តវៀតណាមនៅឆ្នាំ១៩៧៩ ទើបម្តាយរបស់ខ្ញុំបានយកវែកនោះមកប្រើសម្រាប់ដួសបាយ។ ម្តាយរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា វែកប្រាក់នេះមានអាយុកាលជាច្រើនជំនាន់មកហើយ។ យាយទួតរបស់ខ្ញុំតែងតែយកវែកប្រាក់នេះដួសបាយប្រគេនចង្ហាន់ដល់ព្រះសង្ឃនៅវត្តជារៀងរាល់ថ្ងៃ នៅក្នុងសម័យសង្គមរាស្ត្រនិយម និងសម័យ លន់ នល់ ព្រោះយាយទួតរបស់ខ្ញុំបានប្រណិប័តន៍ព្រះពុទ្ធសាសនាយ៉ាងខ្ជាប់ខ្ជួន។

មកដល់សព្វថ្ងៃ ម្តាយរបស់ខ្ញុំលែងប្រើប្រាស់វែកប្រាក់នេះទៀតហើយ គឺគាត់ចង់ថែរក្សាវែកនេះទុកជាកេរមរតកដែលបន្សល់ទុកពីយាយទួតរបស់ខ្ញុំ ឲ្យកូនចៅជំនាន់ក្រោយបានឃើញ។














# ការិយាល័យ ព័ត៌មានសាធារណៈ

«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូន និស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសស្នឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមានៈ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្ថនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨៖០០ ដល់ម៉ោង ១២៖០០ និងពេលរសៀលពីម៉ោង ២៖០០ ដល់ម៉ោង ៥៖០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!












# សាលក្រមសំណុំរឿង០០២/០២

## ដកស្រង់ចេញពីឯកសារដែលបានផ្សព្វផ្សាយជាសាធារណៈរបស់សាលាក្ដីខ្មែរក្រហម

*ហូ ថុនា និង ដារ៉ារដ្ឋ មេត្តា*

(តពីលេខមុន)



*អៀង សារី ឧបនាយករដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងការបរទេសនៃរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ទទួលគណៈប្រតិភូបរទេស នៅព្រលានយន្តហោះអន្តរជាតិពោធិ៍ចិនតុង។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

**១៥៣.** វិធាន ៩៨(២) នៃវិធានផ្ទៃក្នុងចែងថា៖ «សាលក្រមត្រូវសម្រេចត្រឹមតែអង្គហេតុទាំងឡាយណាដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះប៉ុណ្ណោះ។ អង្គជំនុំជម្រះអាចផ្លាស់ប្ដូរការកំណត់បទចោទដែលបានកំណត់ក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះបាន ប៉ុន្តែមិនអាចបញ្ជូននូវធាតុថ្មីនៃបទចោទបានឡើយ»។ អនុលោមតាមវិធាននេះ និងដូចដែលបានកំណត់នៅក្នុងយុត្តិសាស្ត្រនៃតុលាការនេះ អង្គជំនុំជម្រះសាលាដំបូងមិនជាប់កាតព្វកិច្ចត្រូវអនុវត្តតាមការកំណត់បទចោទដែលបានសម្រេចដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះនៅក្នុងដីកាដំណោះស្រាយនោះទេ។ អង្គជំនុំជម្រះសាលាដំបូងអាចកែប្រែបទចោទជាថ្មីឡើងវិញចំពោះអង្គហេតុដែលបានកំណត់ក្នុងដីកាដំណោះស្រាយនៅពេលណាមួយក៏បាន ដើម្បីឲ្យស្របតាមបទល្មើស ឬទម្រង់ផ្សេងទៀតនៃការទទួលខុសត្រូវព្រហ្មទណ្ឌដែលអនុវត្តបានរហូតដល់មានសាលក្រម និងរួមទាំងនៅក្នុងសាលក្រមផងដែរ។ ប្រការនេះ គឺអាស្រ័យទៅលើលក្ខខណ្ឌតម្រូវលើសលុបនៃការជំនុំជម្រះក្ដីដោយយុត្តិធម៌។ ជាពិសេស ចំណុចនេះតម្រូវឲ្យអង្គជំនុំជម្រះត្រូវស្ថិតនៅក្នុងព្រំដែនកំណត់នៃអង្គហេតុទាំងឡាយដែលមាននៅក្នុងដីកាដំណោះស្រាយ និងជូនដំណឹងដល់ជនជាប់ចោទអំពីលទ្ធភាពនៃការកំណត់បទចោទឡើងវិញនោះ។ ហេតុនេះ ការផ្លាស់ប្ដូរការកំណត់បទចោទត្រូវតែពិនិត្យពិច័យដោយផ្អែកទៅលើអង្គហេតុនៃរឿងក្ដី ដើម្បីកំណត់ថា តើមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ដែរឬទេ។

**១៥៤.** នៅក្នុងសំណុំរឿងនេះ អង្គជំនុំជម្រះទទួលយកអង្គហេតុនានាពាក់ព័ន្ធនឹងការស្លាប់របស់បុគ្គលទាំងឡាយដែលត្រូវបានចោទប្រកាន់ថា បានស្លាប់ក្នុងទ្រង់ទ្រាយធំនៅក្នុងទីតាំងឧក្រិដ្ឋកម្មនានា ដោយសារលក្ខខណ្ឌនៃការរស់នៅ និង/ឬលក្ខខណ្ឌការងារដែលពួកគាត់ទទួលរង។ អង្គហេតុទាំងនេះត្រូវបានកំណត់ប្រភេទត្រឹមតែជាការសម្លាប់រង្គាលប៉ុណ្ណោះនៅក្នុងដីកាដំណោះស្រាយ។ បញ្ហានៅត្រង់ថា តើអង្គជំនុំជម្រះអាចកំណត់បទចោទឡើងវិញថា ជាការធ្វើមនុស្សឃាតបានដែរឬទេ ជាពិសេស ចេតនាដោយប្រយោល (DOLUS EVENTUALIS) ក្នុងករណីដែលមានភ័ស្តុតាងបង្ហាញ។ ប្រការនេះអាចធ្វើទៅបានតែក្នុងករណីដែលពុំមានការរំលោភបំពានលើសិទ្ធិរបស់ជនជាប់បចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ប៉ុណ្ណោះ។

**១៥៥.** ពាក់ព័ន្ធនឹងបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ពីការបកស្រាយរបស់អង្គជំនុំជម្រះតុលាការកំពូល អំពីភាពអនុវត្តបាននៃវិធាន ៩៨(២) នៃវិធានផ្ទៃក្នុងនៅក្នុងសាលដីកានៃការធ្វើមនុស្សឃាត ចំពោះអង្គហេតុជាក់លាក់ដែលបានរៀបរាប់នៅក្នុងដីកាដំណោះស្រាយថាជាការសម្លាប់រង្គាលនោះ។ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា «វិធាននេះបានបើកទូលាយសម្រាប់អង្គជំនុំជម្រះតុលាការកំពូល នៅដំណាក់កាលបណ្ដឹងសាទុក្ខឲ្យធ្វើការកែប្រែប្រភេទបទចោទដែលមាននៅក្នុងដីកាដំណោះស្រាយ (ឯកសារ D427) ដែលសហចៅក្រមស៊ើបអង្កេតបានចាត់ទុកថាជាបទសម្លាប់រង្គាលជាជាងបទមនុស្សឃាត។ ការយល់ឃើញនេះ ធ្វើឡើងដោយស្របតាមអង្គហេតុដែលថាដីកាដំណោះស្រាយមិនបានចោទប្រកាន់ជនជាប់ចោទពីការធ្វើមនុស្សឃាត ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ឡើយ ប៉ុន្តែគ្រាន់តែចោទប្រកាន់ពីការសម្លាប់រង្គាលប៉ុណ្ណោះ។ ពាក់ព័ន្ធនឹងការស្លាប់ដែលបានកើតឡើងដោយសារតែលក្ខខណ្ឌ និងកាលៈទេសៈនៃការផ្លាស់ទីលំនៅប្រជាជន អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ទោះបីជាអង្គហេតុទាំងនេះមិនបានបំពេញនូវធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការសម្លាប់រង្គាល ព្រោះធាតុផ្សំអត្តនោម័តនៃការសម្លាប់រង្គាលតម្រូវឲ្យមានចេតនាដោយចំពោះក្នុងការសម្លាប់ (ក្នុងទ្រង់ទ្រាយធំ) ប៉ុន្តែអង្គហេតុទាំងនេះបានបំពេញនូវធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិតាមរយៈការធ្វើមនុស្សឃាត ជាពិសេស អំពីដែលបង្កឲ្យមនុស្សម្នាក់ទៀតស្លាប់យ៉ាងហោចណាស់មានមានចេតនាដោយប្រយោល (DOLUS EVENTUALIS)។ នៅក្នុងការសម្រេចបែបនេះ អង្គជំនុំជម្រះតុលាការកំពូលមិនបានលើកឡើងអំពីបញ្ហានៃការជូនដំណឹងនោះទេ។

**១៥៦.** អង្គជំនុំជម្រះសាលាដំបូងសូមរំឭកថាសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ គឺផ្អែកទៅលើដីកាដំណោះស្រាយតែមួយ ដោយសំណុំរឿង ០០២/០២ ត្រូវបានបង្កើតឡើងអនុលោមតាមសេចក្ដីសម្រេចមួយស្ដីពីការបំបែកដំណើរការនីតិវិធី ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៤។ បន្ទាប់ពីការបំបែកកិច្ចដំណើរការនីតិវិធីរួចមក សំណុំរឿង ព្រមទាំងភាគីនិងតំណាងរបស់ពួកគាត់ គឺមិនមានការផ្លាស់ប្ដូរនៅក្នុងសំណុំរឿងទាំងពីរនេះឡើយ។

**១៥៧.** ដោយសារសំណុំរឿងទាំងពីរនេះមានទំនាក់ទំនងគ្នាជាក់លាក់ និងកាលៈទេសៈអង្គហេតុជាមូលដ្ឋានមានភាពស្រដៀងគ្នានោះ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា តាំងពីខែវិច្ឆិកា ឆ្នាំ២០១៦ ភាគីបានទទួលការជូនដំណឹង

តាមរយៈសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះរបស់តុលាការកំពូលទៅបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង នៅក្នុងសំណុំរឿង០០២/០១ ដូចមានភាគីដូចគ្នានឹងសំណុំរឿងនេះដែរថា អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល អាចផ្លាស់ប្ដូរការកំណត់បទចោទពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាតវិញ ដែលក្នុងនោះរួមមាន ចេតនាដោយប្រយោល (DOLUS EVENTUALIS) ជាពិសេស ពាក់ព័ន្ធនឹងការស្លាប់មនុស្សដែលបានកើតឡើងដោយសារតែលក្ខខណ្ឌ និងកាលៈទេសៈដែលជនរងគ្រោះបានទទួលរង។ ភាគីនានាបានទទួលឱកាសដើម្បីធ្វើសេចក្ដីសន្និដ្ឋាននៅក្នុងអំឡុងកិច្ចប្រជុំរៀបចំសវនាការ កាលពីខែធ្នូ ឆ្នាំ២០១៦ ស្ដីពី «ផលប៉ះពាល់នៃសាលដីការបស់អង្គជំនុំជម្រះរបស់តុលាការកំពូលដែលអាចមានមកលើការបិទបញ្ចប់សវនាការពិនិត្យដេញដោលភស្តុតាងក្នុងសំណុំរឿង ០០២/០២» ដែលផ្ដោតជាពិសេសលើបញ្ហាដែល «អាចប៉ះពាល់ភ្លាមៗលើការពិនិត្យពិភាក្សាដេញដោលពិនិត្យភស្តុតាង»។ ភាគីផ្សេងទៀត មិនបានដាក់សារណាពាក់ព័ន្ធនឹងការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលទៅលើបញ្ហានេះទេ ហើយនៅក្នុងរឿងក្ដីនេះមិនមានភាគីណាមួយជំទាស់នឹងការអនុវត្តសេចក្ដីសម្រេចនេះដែរ។ ម្យ៉ាងវិញទៀត ភាគីមិនបានស្នើសុំពេលបន្ថែមដើម្បីរៀបចំសារណាពាក់ព័ន្ធ ឬដាក់សេចក្ដីសន្និដ្ឋាននៅដំណាក់កាលក្រោយទៀតទេ។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា មិនមានការរំលោភបំពានទៅលើសិទ្ធិរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ក្នុងសំណុំរឿង ០០២/០២ ដែលកើតឡើងចេញពីលទ្ធភាពនៃការកំណត់បទចោទឡើងវិញចំពោះអង្គហេតុដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយពីការសម្លាប់រង្គាលទៅជាការធ្វើមនុស្សឃាតវិញនោះឡើយ។ អង្គជំនុំជម្រះនឹងដោះស្រាយបញ្ហានេះនៅក្នុងផ្នែកពាក់ព័ន្ធនៅក្នុងសាលក្រមនេះ ប្រសិនបើបញ្ហានេះកើតមានឡើងនៅផ្នែកអង្គហេតុ។

**២.៥.៦.៣.** *ការកម្រិតទៅលើវិសាលភាពនៃការជំនុំជម្រះតែចំពោះអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម*

**២.៥.៦.៣.១.** *សារណារបស់ភាគី*

**១៥៨.** មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងថា ដោយសារតែសហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់បានទទួលយកអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ទើបសហចៅក្រមស៊ើបអង្កេតមិនអាចបញ្ជូនសំណុំរឿងទៅជំនុំជម្រះទៅលើអង្គហេតុដែលខ្លួនមិនបានទទួលនោះឡើយ។ ហេតុដូច្នេះ ក្នុងករណីដែលដីកាដំណោះស្រាយមានអង្គហេតុលើសពីអង្គហេតុដែលមានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ អង្គជំនុំជម្រះសាលាដំបូងមិនត្រូវពិចារណាទៅលើអង្គហេតុទាំងនោះឡើយ។ វិធាននេះមានគោលបំណងការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជូនដំណឹងសមស្របអំពីលក្ខណៈ និងមូលហេតុនៃការចោទប្រកាន់ប្រឆាំងនឹងរូបគាត់។ មេធាវីការពារក្ដីបានលើកឡើងបន្ថែមថា មេធាវីការពារក្ដីមិនមានឱកាសណាមួយក្នុងការជំទាស់ទៅនឹងកំហុសឆ្គងដែលប៉ះពាល់ដល់វិសាលភាពនៃការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះឡើយ ព្រោះអង្គបុរេជំនុំជម្រះបានសម្រេចថា បញ្ហានេះត្រូវដោះស្រាយដោយអង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ មេធាវីការពារក្ដីបានលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងចាំបាច់ត្រូវតែសម្រេចទៅលើបញ្ហាទាំងអស់នេះ ព្រោះបើមិនដូច្នេះទេ ជនជាប់ចោទមិនមានលទ្ធភាពទទួលបានមធ្យោបាយប្រកបដោយប្រសិទ្ធភាពក្នុងការជំទាស់ទៅនឹងកំហុសនីតិវិធីឡើយ។

**១៥៩.** មេធាវីការពារក្ដី ខៀវ សំផន បានជំទាស់ដោយផ្អែកលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងបានទទួលយកដោយមិនត្រឹមត្រូវនូវអង្គហេតុដូចខាងក្រោមនេះ៖

ក. ការនិរទេសជនជាតិវៀតណាមដែលរស់នៅក្នុងប្រទេសកម្ពុជាទៅប្រទេសវៀតណាម ដោយសារតែអង្គហេតុបែបនេះ មិនបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយអង្គជំនុំជម្រះបានដកចេញនូវការចោទប្រកាន់ពីការនិរទេសនៅសហករណ៍ត្រាំកក់ពីសំណុំរឿង ០០២/០២



ស្វែងរកការពិត-ផ្នែកច្បាប់ លេខ២៤៦ ខែមិថុនា ឆ្នាំ២០២០





កងទ័ពវៀតណាមដែលខ្មែរក្រហមចាប់ខ្លួនបាន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ. ការបោសសម្អាតផ្ទៃក្នុង ក្រោយពីអង្គហេតុដែលបានកម្រិតដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺអង្គហេតុដែលបានកើតឡើងនៅភូមិភាគឧត្ដរក្នុងឆ្នាំ១៩៧៦ និងនៅក្នុងភូមិភាគបូព៌ាក្នុងឆ្នាំ១៩៧៨។

គ. ការប្រព្រឹត្តចំពោះពុទ្ធសាសនិក នៅស្រុកត្រាំកក់ (ដោយសារតែស្រុកនេះស្ថិតក្នុងខេត្តតាកែវ ដែលជាខេត្តមិនស្ថិតក្នុងចំណោមខេត្តទាំងប្រាំដែលបានលើកឡើង នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ) អង្គហេតុទាក់ទងនឹងគោលនយោបាយទូទាំងប្រទេសប្រឆាំងពុទ្ធសាសនិក (ដោយសារតែដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ យោងតែទៅលើអង្គហេតុដែលកើតឡើងនៅក្នុងវត្តចំនួនប្រាំពីរ។ វត្តដទៃទៀតដែលត្រូវបានលើកឡើងនៅពេលបន្ទាប់ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមិនទាក់ទងជាមួយនឹងការប្រព្រឹត្តទៅលើពុទ្ធសាសនិកឡើយ គឺលើកឡើងដោយសារតែវត្តទាំងនោះត្រូវបានគេប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខ)។

ឃ. អំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាមតាមរយៈការសម្លាប់ហួសពីអង្គហេតុដែលបានកើតឡើងក្រោយឆ្នាំ១៩៧៧ នៅក្នុងស្រុកកងមាស (ភូមិភាគកណ្ដាល) និង ក្រូចឆ្មារ (ភូមិភាគបូព៌ា) (ដោយសារតែមានពេលវេលានេះ និងទីតាំងទាំងអស់នេះ ដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ហើយដោយកត់សម្គាល់បន្ថែមទៀតថា អង្គហេតុដែលបានកើតឡើងនៅមន្ទីរសន្តិសុខស្រុកក្រូចឆ្មារត្រូវបានដកចេញ ពីវិសាលភាពសំណុំរឿង ០០២/០២ ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីសវនាការ)។

ង. ការស្លាប់អ្នកជាប់ឃុំដោយសារតែការអត់អាហារ ការសម្លាប់ ឬការសម្លាប់រង្គាលជនជាតិវៀតណាម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត (បទល្មើសប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងការបាត់ខ្លួនដោយបង្ខំ) និងការដាក់ឲ្យទៅជាទាសករ

មជ្ឈមណ្ឌលឯកសារកម្ពុជា 

*នៅមន្ទីរសន្តិសុខក្រាំងតាចាន់ (ដោយសារតែមិនមានអង្គហេតុត្រូវបានលើកឡើងទាក់ទងនឹងបទចោទទាំងអស់នេះ នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមដែលពាក់ព័ន្ធ*

*ប. ការស្លាប់របស់អ្នកជាប់ឃុំដោយសារការអត់អាហារ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងទៀងទាត់ នៅមន្ទីរសន្តិសុខអូរកន្សែង (ដោយសារតែមិនមានអង្គហេតុបែបនេះត្រូវបានលើកឡើងទាក់ទងបទចោទទាំងអស់នេះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង*

*ឆ. ការដាក់ឲ្យទៅជាទាសករ (លើសពីអង្គហេតុនៃការងារដោយបង្ខំនៅអង្គភាព ក-១១) ការធ្វើទារុណកម្ម និងអំពើអមនុស្សធម៌ដទៃទៀត ដោយសារការពឹងផ្អែកទៅលើការប្រើប្រាស់ទារុណកម្មនៅមន្ទីរសន្តិសុខភ្នំក្រោល និងការបាត់ខ្លួនដោយបង្ខំក្រៅពីការបាត់បង់ខ្លួនដែលកើតឡើងនៅទីតាំងអង្គភាព ក-១៧។*

**២.៥.៦.៣.២.** *ភាពអាចទទួលយកបាននៃសំណើសុំរបស់មេធាវីការពារក្តី*

**១៦០.** *អង្គជំនុំជម្រះរំឭកថា យោងតាមច្បាប់កម្ពុជា និងវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង «លើកលែងតែជាកម្មវត្ថុនៃបណ្តឹងឧទ្ធរណ៍ ដីកាដំណោះស្រាយត្រូវតែកែតម្រូវកំហុសនៃការមិនគោរពវិធានបញ្ញត្តិក្នុងការស៊ើបសួរ។ គ្មានបញ្ហាណាមួយដែលពាក់ព័ន្ធនឹងកំហុសនីតិវិធីបែបនេះអាចត្រូវបានលើកឡើងទៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូលឡើយ។ គោលបំណងនៃបទបញ្ញត្តិនេះគឺដើម្បីធានាថាភាគីដែលមានសិទ្ធិចូលពិនិត្យសំណុំរឿងក្នុងអំឡុងកិច្ចស៊ើបសួរ និងបានដឹងអំពីកំហុសនីតិវិធីដែលអាចមោឃភាពផ្នែកខ្លះនៃកិច្ចស៊ើបសួរ ត្រូវអនុវត្តដោយប្រុងប្រយ័ត្នដើម្បីដោះស្រាយបញ្ហានីតិវិធីនៅដំណាក់កាលមុនពេលជំនុំជម្រះ ដើម្បីកុំឲ្យបញ្ហាទាំងនេះប៉ះពាល់ដល់ដំណើរការជំនុំជម្រះ។ ហេតុដូច្នេះ នៅពេលដែលភាគីចោទ*



*កងទ័ពវៀតណាមដែលខ្មែរក្រហមចាប់ខ្លួនបាន។*
*(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

*ប្រកាន់ថាមានកហុសនីតិវិធីដែលប៉ះពាល់ដល់កិច្ចស៊ើបសួររបស់តុលាការ រួមទាំងដីកាដំណោះស្រាយដែលចេញដោយសហចៅក្រមស៊ើបអង្កេតផងនោះ មធ្យោបាយធម្មតាក្នុងការស្វែងរកដំណោះស្រាយចំពោះកំហុសនីតិវិធីនេះគឺអង្គបុរេជំនុំជម្រះ។ ប៉ុន្តែមិនមានភាពច្បាស់លាស់ទេថាតើវិធាន ៧៦(៧) នៃវិធានផ្ទៃក្នុងអនុញ្ញាតធ្វើការជំទាស់ទៅលើកំហុសនៅក្នុងដីកាដំណោះស្រាយ នៅក្នុងដំណាក់កាលជំនុំជម្រះដែរឬទេ។*

**១៦១.** *យោងតាមវិធាន៨៩ នៃវិធានផ្ទៃក្នុង នៅពេលដែលមានបញ្ហាទាក់ទងនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូង ឬបញ្ហាណាមួយដែលទាមទារឲ្យមានការបញ្ចប់ការចោទប្រកាន់ ឬការមោឃភាពកិច្ចដំណើរការនីតិវិធី ដែលបានធ្វើឡើងបន្ទាប់ពីចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ បញ្ហានេះត្រូវលើកឡើងជាអញ្ញត្រកម្ម «យ៉ាងយូរ ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេ អញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ។ គោលបំណងនៃអញ្ញត្រកម្ម គឺដើម្បីបញ្ជាក់វិសាលភាពនៃការជំនុំជម្រះនៅមុនពេលចាប់ផ្តើមសវនាការពិនិត្យភស្តុតាង រួមទាំងការកំណត់បញ្ហាដែលតម្រូវឲ្យមានការបញ្ចប់កិច្ចដំណើរការនីតិវិធីដែរ។ មាត្រា៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មានគោលបំណងស្រដៀងគ្នានេះ នៅពេលដែលតម្រូវឲ្យភាគីនានាលើកឡើងនូវការជំទាស់ណាមួយចំពោះ «ភាពត្រឹមត្រូវ» នៃមធ្យោបាយចោទប្រកាន់មុនពេលចាប់ផ្តើមការសួរដេញដោលទៅលើអង្គសេចក្តី។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថា សំណើសុំទាក់ទងនឹងសិទ្ធិអំណាចរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការដោះស្រាយទៅលើផ្នែកផ្សេងៗនៃដីកាដំណោះស្រាយដែលត្រូវបានលើកឡើងក្រោយពេលបញ្ចប់រយៈពេលកំណត់សម្រាប់ការដាក់អញ្ញត្រកម្មនោះ នឹងត្រូវបានចាត់ទុកថាយឺតពេល ហើយត្រូវបដិសេធចោល។*

**១៦២.** *មេធាវីការពារក្តី ខៀវ សំផន បានអះអាងថា អង្គហេតុមួយចំនួនដែលបានលើកឡើងក្នុងដីកាដំណោះស្រាយនោះ តាមពិតទៅមិនស្ថិតនៅក្នុងវិសាលភាពនៃកិច្ចស៊ើបសួររបស់តុលាការឡើយ ហេតុដូច្នេះ វាមិនស្ថិតក្នុងវិសាលភាពនៃបទចោទដែលត្រូវជំនុំជម្រះនោះទេ។ អាចនិយាយម្យ៉ាងទៀតថា មេធាវីការពារក្តីជំទាស់ទៅនឹងយុត្តាធិការរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការវិនិច្ឆ័យលើអង្គហេតុទាំងអស់នេះដែលនឹងធ្វើឲ្យមានការបញ្ចប់ការចោទប្រកាន់ទៅលើបទចោទទាំងអស់នោះ ប្រសិនបើការជំទាស់នេះត្រូវបានអនុញ្ញាត។*

**១៦៣.** *ក្នុងចំណោមសំណើសុំជាច្រើនដែលមេធាវីការពារក្តី ខៀវ សំផន បានលើកឡើង និងបានរៀបរាប់នៅក្នុងកថាខណ្ឌ ១៥៩ ខាងលើ មានតែការចោទប្រកាន់ពីការនិរទេសជនជាតិវៀតណាម ថាជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប៉ុណ្ណោះ ដែលត្រូវបានលើកឡើងជាមួយមូលដ្ឋានសម្រាប់ការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ហើយករណីនេះត្រូវបានធ្វើឡើងដោយមេធាវីការពារក្តី អៀង សារី។ អង្គជំនុំជម្រះកត់សម្គាល់ថា អង្គបុរេជំនុំជម្រះទុកឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចលើបញ្ហានេះ ហើយមេធាវីការពារក្តី អៀង សារី បានលើកឡើងចំណុចនេះនៅក្នុងអញ្ញត្រកម្មបឋមរបស់ខ្លួន មុនការចាប់ផ្តើមសំណុំរឿង ០០២។ ក្រោយមរណភាពរបស់ អៀង សារី អង្គជំនុំជម្រះបានចោទសួរថា តើមានភាគីផ្សេងទៀតឯកភាពទៅនឹងការជំទាស់ចំពោះបទចោទនៃការនិរទេសដែរឬទេ មេធាវីការពារក្តី ខៀវ សំផន បានឆ្លើយតបថាខ្លួនឯកភាពតាម។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចទៅលើសំណើនេះនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ ដោយច្រានចោលការជំទាស់របស់មេធាវីការពារក្តីទៅនឹងការដាក់បញ្ចូលបទចោទទាំងនេះ។*

**១៦៤.** *នៅក្នុងសេចក្តីសម្រេចកន្លងមករបស់ខ្លួនលើបញ្ហានេះ អង្គជំនុំជម្រះសាលាដំបូងមិនបានពិចារណាទៅលើចំណុច ដែលអង្គបុរេជំនុំជម្រះមិនបានធ្វើការសម្រេចទៅលើមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ខាងលើនេះទេ ដែលកាលនោះអង្គបុរេជំនុំជម្រះបានសម្រេចទុកបញ្ហានេះឲ្យអង្គជំនុំជម្រះសម្រេច នៅក្នុងដំណាក់កាលជំនុំជម្រះ។ ទោះបីជាសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះអាចនាំឲ្យចោទជាបញ្ហាអំពីភាពសមស្របក៏ដោយ ក៏ប៉ុន្តែអង្គជំនុំជម្រះកត់សម្គាល់ថាការមិនបានពិចារណាទៅលើបញ្ហានេះនៅដំណាក់កាលជំនុំជម្រះក្នុងកាលៈទេសៈទាំងអស់នេះ អាចធ្វើឲ្យជនជាប់ចោទមិនមានមធ្យោបាយប្រកបដោយប្រសិទ្ធភាព ដើម្បីជំទាស់ទៅនឹងកំហុសឆ្គងនីតិវិធីនៅក្នុងដីកាដំណោះស្រាយ។ ដោយសារតែបញ្ហានេះត្រូវបានលើកឡើងក្នុងពេលវេលាដ៏សមស្របនៅក្នុងសវនាការក្នុងលក្ខណៈជាអញ្ញត្រកម្ម អនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះនឹងពិនិត្យមើលទៅលើមូលដ្ឋាននៃការជំទាស់ទៅនឹងការនិរទេសនេះ។*

**(តនៅលេខក្រោយ)**

# ការឈឺចាប់ដែលមិនអាចបំភ្លេចបាន នៅសម័យខ្មែរក្រហម

ហូ ថុនា



នេត វើត អាយុ៧៦ឆ្នាំ រស់នៅភូមិប៉ោយក្អឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ការឈឺចាប់ដែលខ្ញុំមិនអាចបំភ្លេចបាននៅសម័យខ្មែរក្រហមនោះគឺនៅពេលដែលខ្មែរក្រហមបានបញ្ជូនឲ្យខ្ញុំទឹមនង្គ័លភ្ជួរស្រែ ប៉ុន្តែថ្ងៃមួយខ្ញុំបានព្យាយាមប្រកែកតវ៉ាព្រោះខ្ញុំមិនមានកម្លាំងអូសនង្គ័លនោះបានទៀតទេ។ ខ្ញុំមិននឹកស្មានថាខ្ញុំអាចរួចផុតជីវិតទេ ព្រោះការប្រឆាំងនឹងអង្គការ គឺមិនអាចគេចផុតពីសេចក្តីស្លាប់ឡើយ។ ខ្ញុំឈ្មោះ នេត វើត អាយុ៧៦ឆ្នាំ រស់នៅភូមិប៉ោយក្អឿង ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ តំបន់៥។ បន្ទាប់ពីខ្មែរក្រហមឡើងគ្រប់គ្រងប្រទេសនៅឆ្នាំ១៩៧៥ គ្រួសាររបស់ខ្ញុំត្រូវបានខ្មែរក្រហមជម្លៀសឲ្យទៅរស់នៅភូមស្រេះខាងកើត ដោយខ្មែរក្រហមបានប្រកាសថា សូមបងប្អូនដែលរស់នៅក្នុងភូមិប៉ោយក្អឿងទាំងអស់ចាកចេញពីភូមិរបស់ខ្លួនមួយរយៈសិន ព្រោះដើម្បីគេចពីការទម្លាក់គ្រាប់បែកពីសំណាក់កងទ័ពអាមេរិក។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើរទៅរស់នៅភូមិស្រេះខាងកើត។ ខ្មែរក្រហមចាប់ផ្តើមប្រមែប្រមូលទ្រព្យសម្បត្តិរបស់ប្រជាជនដាក់ជារបស់រួមទាំងអស់។ គោរបស់ខ្ញុំក៏ត្រូវបានប្រមូលដាក់ជាសម្បត្តិរបស់អង្គការដែរ។ នៅពេលនោះខ្មែរក្រហមបានបញ្ជូនឲ្យខ្ញុំទឹមនង្គ័លភ្ជួរស្រែ ជំនួសឲ្យសត្វគោ។ ខ្ញុំអូសនង្គ័លភ្ជួរស្រែជារៀងរាល់ថ្ងៃ។ ខ្ញុំដើររហូតដល់ទន់ជង្គង់។ កងភ្ជួររបស់ខ្ញុំមានសមាជិកបីនាក់ សុទ្ធសឹងតែជាមនុស្សស្រីវ័យជំទង់។ ខ្ញុំនិងសមមិត្តនារីម្នាក់អូសនង្គ័លខាងមុខ ចំណែកឯមិត្តនារីម្នាក់ទៀតជាអ្នកសង្កត់នង្គ័លនៅខាងក្រោយ។ ខ្ញុំធ្វើការនេះយ៉ាងលំបាក ប៉ុន្តែខ្ញុំទទួលបានរបបមានត្រឹមតែដំឡូងមី និងបបរសម្រាប់បរិភោគតែប៉ុណ្ណោះ។ ថ្ងៃមួយខ្ញុំបានប្រាប់ទៅប្រធានកងថា ខ្ញុំមិនអាចធ្វើការងារនេះតទៅទៀតបានទេ ព្រោះដីស្រែនេះសូម្បីតែសត្វគោក៏មិនអាចអូសនង្គ័លទៅមុខរួចដែរ។ ដីស្រែមានសភាពរឹងព្រោះវាជារដូវប្រាំង។ ខ្ញុំនឹកគិតថា ខ្ញុំច្បាស់ជាស្លាប់ព្រោះខ្ញុំហ៊ានតវ៉ា។ ប្រធានកងបាននិយាយមកកាន់ខ្ញុំវិញថា «មិនអីទេ ប្រសិនបើមានគោចាំយកមកភ្ជួរជំនួសចុះ»។ ខ្ញុំអន់ចិត្តនឹងសម្តីរបស់ប្រធានកង ហើយសម្តីនេះនៅជិតដាមជាប់នៅក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច។

នៅថ្ងៃមួយពេលខ្ញុំវិលត្រឡប់មកភូមិវិញ ខ្ញុំបានឃើញគោរបស់បងប្រុសខ្ញុំនៅមុខផ្ទះ ប៉ុន្តែមិនឃើញម្ចាស់ឡើយ។ ពេលនោះបងប្រុសខ្ញុំនៅកងភ្ជួរស្រែ។ ខ្ញុំភ័យស្លន់ស្លោរហូតដល់ដួលសន្លប់ ប៉ុន្តែបានកងម៉ែៗនៅក្នុងភូមិជួយធ្វើចលនាបេះដូង និងច្របាច់ដៃជើងរហូតដល់ខ្ញុំដឹងខ្លួន។ ខ្ញុំនិយាយទៅកាន់ម៉ែៗនៅក្នុងភូមិថា បងប្រុសរបស់ខ្ញុំប្រហែលត្រូវបានខ្មែរក្រហមយកទៅសម្លាប់ហើយ។ ខ្ញុំបានព្យាយាមតាមសួររកបងប្រុសរបស់ខ្ញុំនៅតាមភូមិផ្សេងៗ ប៉ុន្តែនៅតែរកមិនឃើញគាត់។ អ្នកភូមិម្នាក់ដែលដឹងដំណឹងពីបងប្រុសរបស់ខ្ញុំបាននិយាយប្រាប់ខ្ញុំថា បងរបស់ខ្ញុំត្រូវបានខ្មែរក្រហមយកទៅសម្លាប់ហើយ។ ខ្មែរក្រហមបានចោទប្រកាន់គាត់ថា «ក្បត់អង្គការ» ដោយសារបងប្រុសរបស់ខ្ញុំបាននិយាយថា «ប្រសិនបើកូនប្រុសរបស់គាត់ស្លាប់ គាត់ក៏មិនចង់រស់ទៀតដែរ»។ កូនប្រុសរបស់គាត់បានស្លាប់ដោយសារជំងឺ។ គ្រាន់តែពោលពាក្យដូច្នេះធ្វើឲ្យគាត់មិនអាចមានជីវិតរស់នៅបាន។ មុននឹងខ្មែរក្រហមសម្លាប់បងប្រុសរបស់ខ្ញុំ មានប្រជាជនដែលរស់នៅភូមិជាមួយគ្នាបាននិយាយទៅកាន់គាត់ថា «សមមិត្តបងឯងគួរតែរត់ទៅតំបន់៣ ដើម្បីគេចខ្លួនមួយរយៈសិនទៅ។ តំបន់បី គឺជាតំបន់មួយក្នុងចំណោមតំបន់ទាំង៧ នៃភូមិភាគពាយ័ព្យ។ បងប្រុសខ្ញុំបានឆ្លើយតបវិញថា «ខ្ញុំមិនអាចរត់ចោលប្រពន្ធកូនខ្ញុំបានទេ» លុះដល់ព្រឹកឡើងបងប្រុសរបស់ខ្ញុំក៏ត្រូវបានគណៈឃុំឈ្មោះ តាក្រក និង តាផន បានមកយកគាត់ចេញទៅបាត់។ នៅពេលដែលខ្ញុំរំឭករឿងរ៉ាវរបស់បងប្រុសខ្ញុំ ទឹកភ្នែកខ្ញុំតែងតែស្រក់ចុះមក។ ខ្ញុំឈឺចាប់នូវទង្វើរបស់គណៈឃុំខ្មែរក្រហមដែលបានប្រព្រឹត្តមកលើបងប្រុសរបស់ខ្ញុំដែលគ្មានកំហុស។ មានយប់ខ្លះខ្ញុំលួចអុជធូបបន់ស្រន់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឲ្យខ្ញុំឆាប់រួចផុតពីរបបខ្មែរក្រហម។ ប៉ុន្តែប្រសិនបើខ្មែរក្រហមតាមទាន់ខ្ញុំកំពុងអុជធូប ខ្ញុំច្បាស់ជាទទួលរងនូវទារុណកម្ម ឬយកខ្ញុំទៅសម្លាប់មិនខានឡើយ។

មានថ្ងៃមួយពេលខ្ញុំកំពុងច្រូតស្រូវស្រាប់តែបានឃើញគីង្គក់នៅសម្ងំនឹងគុម្ពស្រូវ ខ្ញុំមានអារម្មណ៍ត្រេកអរយ៉ាងខ្លាំង។ ខ្ញុំបានចាប់គីង្គក់នោះពន្លាត់ស្បែក។ បន្ទាប់មក ខ្ញុំបានយកគីង្គក់នោះលាក់ទុកនៅក្នុងថ្នក់សំពត់។ នៅពេលត្រឡប់មកដល់ផ្ទះ ខ្ញុំបានលួចយកគីង្គក់ទៅអាំងហូបជាមួយបបរដែលខាងចុងភៅចែកឲ្យ។ លុះដល់ព្រឹកឡើង ខ្ញុំវិលមុខយ៉ាងខ្លាំងដោយសារពុលសាច់គីង្គក់។ ប្រធានក្រុមបានមកហៅខ្ញុំដល់ផ្ទះដើម្បីឲ្យចេញទៅធ្វើការ។ ខ្ញុំធ្វើការទាំងឈឺដោយមិនហ៊ានសុំច្បាប់ឈប់សម្រាកឡើយ។ ក្រៅពីការងារច្រូតស្រូវ ខ្ញុំត្រូវបានខ្មែរក្រហមចាត់តាំងឲ្យស្ទូង និងដាំដំឡូងទៀត។ ខ្ញុំព្យាយាមធ្វើការងារទាំងនេះរហូតដល់របបខ្មែរក្រហមដួលរលំនៅឆ្នាំ១៩៧៩។ ខ្ញុំបានវិលត្រឡប់មករស់នៅផ្ទះក្នុងភូមិវិញ និងធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ។ ក្រោយមក ខ្ញុំនិងប្រជាជនក្នុងភូមិមួយចំនួន បាននាំគ្នាទៅទិញសំពត់គេចពន្ធពីទឹកដីថៃ ដើម្បីយកមកដូរយកអង្ករពីប្រជាជនដែលរស់នៅខេត្តសៀមរាប។ ខ្ញុំបានទៅដល់ជីរំថ្មី ជីរំចាស់ និងជីរំណាងច័ន្ទ។ ខ្ញុំបានធ្វើដំណើរដោយថ្មើរជើង ដោយប្រើរយៈពេលមួយយប់មួយថ្ងៃ ទើបទៅដល់ទីនោះ។ ខ្ញុំបានវេចអង្ករ ឆ្នាំងចាន និងម្ហូបអាហារសម្រាប់ហូបតាមផ្លូវ។ នៅពេលនោះខ្ញុំមានប្រាក់តិចតួចប៉ុណ្ណោះ។ ខ្ញុំអាចទិញសំពត់គេចពន្ធពីថៃបានត្រឹមតែ១២០សំពត់សម្រាប់មួយជើង។ ខ្ញុំបានរកស៊ីរបរនេះអស់រយៈពេលប្រហែលមួយឆ្នាំ។ ក្រោយមក ខ្ញុំក៏បោះបង់របរនេះចោលហើយបានមកធ្វើស្រែចម្ការរហូតមក។ សព្វថ្ងៃនេះ ខ្ញុំមិនអាចធ្វើការធ្ងន់បានទេ គឺខ្ញុំបានទៅវត្តសុំសិល្ប៍។



វាលស្រែដែលទើបភ្ជួររាស់ហើយ នៅជាប់ជើងភ្នំស្រេះ ក្នុងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ។ (ហូ ថុនា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ពេលវេលាដ៏លំបាកសម្រាប់ខ្ញុំនៅក្នុងរបបខ្មែរក្រហម

អ៊ុន សុដាវី



ងិន ចន កំពុងផ្តល់បទសម្ភាសន៍ដល់ អ៊ុន សុដាវី បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា (លី កុកឆាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ងិន ចន គឺជាស្ត្រីវ័យជំទង់ម្នាក់ដែលមានអាយុត្រឹមតែ១៦ឆ្នាំនៅក្នុងសម័យខ្មែរក្រហម បាននិយាយថា «ប្រសិនយើងរំឭកទៅដល់ជីវិតរស់នៅប្រចាំថ្ងៃនៅក្នុងរបបខ្មែរក្រហមអាហារមួយពេលៗ គឺពិតជាមានតម្លៃណាស់ ប៉ុន្តែប្រសិនបើយើងគឺជាមនុស្សស្រីវិញ ការដោះស្រាយនឹងបញ្ហាអនាម័យពិតជាលំបាកជាងនេះ»។

សព្វថ្ងៃ ងិន ចន មានអាយុ៦១ឆ្នាំ រស់នៅក្នុងភូមិត្រពាំងថ្កូវ ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង។ ចាប់តាំងពីរបបខ្មែរក្រហមដួលរលំមក ចន រស់នៅជាមួយក្រុមគ្រួសារបងប្អូនជីដូនមួយ ព្រោះសមាជិកក្រុមគ្រួសាររបស់គាត់បានស្លាប់បាត់បង់ជីវិតទាំងអស់នៅក្នុងរបបខ្មែរក្រហម។ ចន ប្រកបរបរធ្វើស្រែចម្ការ និងជួយមើលថែក្មេងៗនៅក្នុងគ្រួសារ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ចន អំពីដំណើរឆ្លងកាត់រឿងរ៉ាវដ៏សែនលំបាកក្នុងជីវិតរបស់គាត់៖

ខ្ញុំកើតនៅភូមិត្រពាំងថ្កូវ ឃុំពងទឹក ស្រុករំដួល ខេត្តស្វាយរៀង។ ខ្ញុំមានបងប្រុសម្នាក់។ ខ្ញុំចាំបានថា នៅពេលដែលខ្ញុំមានអាយុប្រហែល៨ឆ្នាំ ម្តាយរបស់ខ្ញុំបានចុះឈ្មោះឲ្យខ្ញុំចូលរៀននៅសាលាបឋមសិក្សាមួយកន្លែងក្នុងវត្តព្រៃតាយ័ន្ត ដែលស្ថិតនៅក្បែរផ្ទះរបស់ខ្ញុំ។ ខ្ញុំរស់នៅ និងរៀនសូត្រនៅទីនោះរហូតដល់ថ្នាក់ទី១០។ ខ្ញុំចូលចិត្តរៀនមុខវិជ្ជាអក្សរសាស្ត្រខ្មែរ។ មុខវិជ្ជាផ្សេងៗខ្ញុំរៀនមិនសូវចេះទេ។ រហូតដល់ឆ្នាំ១៩៧០ ខ្ញុំ និងក្រុមគ្រួសារ បានចាកចេញពីស្រុកកំណើតទៅរស់នៅឯអ្នកលឿង ក្នុងខេត្តព្រៃវែង តាមឪពុកនិងបងប្រុសរបស់ខ្ញុំ ពីព្រោះអ្នកទាំងពីរ គឺជាទាហាន លន់ នល់។ ឪពុកនិងបងប្រុសខ្ញុំ តម្រូវឲ្យផ្លាស់ប្តូរមករស់នៅឯអ្នកលឿងដើម្បីត្រៀមប្រយុទ្ធទប់ទល់ជាមួយនឹងកងទ័ពខ្មែរក្រហម។ នៅឯអ្នកលឿង យើងបានជួលផ្ទះមួយរស់នៅ។ ខ្ញុំនៅផ្ទះជាមួយម្តាយ និងលក់ដូរអីវ៉ាន់បន្តិចបន្តួចៗ ក្រុមគ្រួសាររបស់ខ្ញុំ បានរស់នៅអ្នកលឿងទាំងអស់គ្នារហូតដល់ខ្មែរក្រហមវាយកាន់កាប់ទីក្រុងភ្នំពេញបានទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥។

បន្ទាប់ពីខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ មនុស្សម្នាជាច្រើនត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញឲ្យធ្វើដំណើរទៅរស់នៅតាមខេត្ត ឬស្រុកកំណើតរបស់ខ្លួន។ ឪពុកខ្ញុំត្រូវចេញទៅប្រយុទ្ធនៅក្នុងសមរភូមិ និងបានស្លាប់ពេលដែលប្រយុទ្ធនៅក្នុងសមរភូមិជាមួយយោធាខ្មែរក្រហម។ បន្ទាប់ពីឪពុកខ្ញុំស្លាប់ យើងនៅសល់សមាជិកគ្រួសារតែពនាក់ប៉ុណ្ណោះ គឺម្តាយខ្ញុំ បងប្រុសខ្ញុំ និងខ្ញុំ។ មិនយូរប៉ុន្មាន ខ្មែរក្រហមបានឲ្យយើងចាកចេញពីអ្នកលឿងទៅរស់នៅក្នុងខេត្តព្រៃវែងវិញ។ យើងធ្វើដំណើរទៅស្រុកព្រះស្តេច និងបានស្នាក់នៅក្នុងភូមិមួយ ប៉ុន្តែខ្ញុំមិនចាំឈ្មោះភូមិនោះទេ។ នៅក្នុងភូមិមួយរយៈខ្លីប៉ុណ្ណោះ បងប្រុសខ្ញុំ ត្រូវបានខ្មែរក្រហមនាំយកទៅសម្លាប់ទៀត ព្រោះខ្មែរក្រហមបានស៊ើបដឹងពីប្រវត្តិរបស់គាត់។ ម្តាយរបស់ខ្ញុំចាប់ផ្តើមព្រួយចិត្តព្រោះនឹករឭកដល់ប្តីនិងកូនដែលស្លាប់កាន់តែខ្លាំងទៅៗរហូតដល់ធ្លាក់ខ្លួនឈឺស្លាប់ទៀត។ ពេលនោះហើយ ដែលខ្ញុំចាប់ផ្តើមមានជីវិតលំបាកបំផុត។

ខ្ញុំបានរស់នៅក្នុងកងនារី។ ខ្មែរក្រហមបានឲ្យខ្ញុំទៅធ្វើការនៅក្នុងកងចល័ត រួមមាន លើកភ្លឺស្រែ ជីកអាងទឹក និងប្រូតស្រូវ។ ពេលនោះ ខ្ញុំគ្មានម្តាយឪពុកនិងសាច់ញាតិផ្តល់ភាពកក់ក្តៅឡើយ។ ខ្ញុំរស់នៅដោយពឹងពាក់លើខ្លួនឯងទាំងស្រុង។ រឿងដែលខ្ញុំពិបាកបំផុតនោះគឺបញ្ហាសុខភាព និងការដោះស្រាយអនាម័យប្រចាំថ្ងៃរបស់ខ្ញុំ។ នៅពេលដែលខ្ញុំមានរដូវប្រចាំខែ គឺខ្ញុំពិបាកណាស់។ ភាគច្រើន ខ្ញុំកុហកអង្គការថាខ្ញុំគ្រុន ឈឺក្បាល ឬវិលមុខ មិនអាចទៅធ្វើការងារខាងក្រៅបាន។ ខ្ញុំតែងតែនឹកគិតថា បើថ្ងៃណាមួយអង្គការដឹងថាខ្ញុំកុហក គេនឹងយកខ្ញុំទៅសម្លាប់ ប៉ុន្តែខ្ញុំក៏មិនអាចដើរចេញទៅធ្វើការងារនៅតាមវាលស្រែបានទេ។ ខ្ញុំតែងតែសម្ងំនៅផ្ទះ និងលេបថ្នាំគ្រាប់ខ្មៅនៅពេលដែលខ្ញុំឈឺចាប់។ ខ្ញុំគ្មានមិត្តភក្តិទេ។ ទោះបីជាយើងមានរឿងអ្វី ក៏យើងមិនអាចចែករំលែករឿងរ៉ាវឲ្យគ្នាទៅវិញទៅមកបានដែរ។ ប៉ុន្តែជួនពេលខ្លះ ខ្ញុំបានលួចខ្សឹបសួរអ្នកដែលខ្ញុំទុកចិត្ត និងមានវ័យចំណាស់ជាងខ្ញុំអំពីអាការរោគរបស់ស្ត្រី នៅពេលដែលខ្ញុំជួបការលំបាកខ្លាំង។

មុនរបបខ្មែរក្រហម ខ្ញុំមានសក់វែងត្រឹមចង្កេះ ពណ៌ខ្មៅស្រិលរលោងស្អាតខ្លាំងណាស់។ ប៉ុន្តែពេលជម្លៀសមកដល់ខេត្តព្រៃវែង ខ្មែរក្រហមបានហៅខ្ញុំឲ្យទៅកាត់សក់ត្រឹមកញ្ចឹងក។ ខ្ញុំស្តាយសក់ណាស់ ព្រោះជាវ័យដែលខ្ញុំពេញស្រឡាញ់សក់វែង។ ខ្ញុំចង់រក្សាសក់ដែលកាត់រួចនោះដែរ តែមិនអាចទេ។ ខ្ញុំទទួលស្គាល់ថា ការ

ទុកសក់វែងមិនមែនជារឿងល្អទេនៅពេលនោះ។ ខ្ញុំគ្មានសាប៊ូកក់សក់ទេ។ ខ្ញុំតែងតែយកស្លឹកគរមកច្របាច់យកទឹកនិងញីជាមួយសក់របស់ខ្ញុំ។ ដោយសារតែខ្វះអនាម័យ ខ្ញុំក៏កើតមានសត្វចៃជាច្រើននៅលើក្បាល។ គ្មាននរណាមានសាប៊ូដុសឬថ្នាំដុសធ្មេញសម្រាប់ប្រើប្រាស់ទេ គឺយើងផ្ទុតតែទឹកតែប៉ុណ្ណោះ ហើយជួនពេលខ្លះ យើងគ្មានទឹកផ្ទុតគ្រប់គ្រាន់ផង។ ចំណែកឯសម្លៀកបំពាក់ គឺយើងមានតែខោអាវខ្មៅដែលអង្គការចែកឲ្យចំនួន២សម្រាប់ក្នុងម្នាក់តែប៉ុណ្ណោះ។ ដោយសារតែគ្មានអនាម័យនិងអាហារហូបចុកគ្រប់គ្រាន់ ទើបធ្វើឲ្យស្ត្រីនៅក្នុងកងរបស់ខ្ញុំមានជំងឺថប់ និងដួលសន្លប់ជាច្រើននាក់ពេលកំពុងធ្វើការងារ។ ក្រៅពីបញ្ហាកង្វះអនាម័យ ខ្ញុំក៏ដេកខ្លាចរាល់ថ្ងៃដែរ គឺខ្លាចអង្គការយកខ្ញុំទៅសម្លាប់ ព្រោះខ្ញុំគឺជាប្រជាជនថ្មី និងមានសាច់ញាតិជាអតីតទាហានលន់ នល់។ ខ្ញុំខ្លាចក្រែងថ្ងៃណាមួយអង្គការស៊ើបដឹងពីប្រវត្តិគ្រួសាររបស់ខ្ញុំ អង្គការនឹងយកខ្ញុំទៅសម្លាប់ចោលដូចបងប្រុសរបស់ខ្ញុំដែរ។ ខ្ញុំមិនដែលសង្ឃឹមថាខ្ញុំគ្មានជីវិតរស់នៅដូចសព្វថ្ងៃនេះទេ។ ទាំងម្តាយឪពុក និងបងប្រុស ខ្ញុំ បានស្លាប់ទាំងអស់។



ងិន ចន (លី កុកឆាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំធ្លាប់បានដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហមនៅក្នុងឆ្នាំ២០០៩។ ការដាក់ពាក្យបណ្តឹងនៅពេលនោះ ព្រោះខ្ញុំឈឺចាប់នឹងការបាត់បង់សមាជិកគ្រួសាររបស់ខ្ញុំ។ ខ្ញុំមិនចង់បានសំណងសម្រាប់ខ្ញុំឡើយ។ អ្វីដែលខ្ញុំចង់បាននោះ គឺបញ្ហាសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ អ្នកទាំងនោះមានវ័យកាន់តែជរា ហើយក៏មានជំងឺច្រើនណាស់ដែរ។ ខ្ញុំសូមស្នើសុំឲ្យមានការជួយថែរក្សាសុខភាពដល់ជនរងគ្រោះជាពិសេសស្ត្រីដែលធ្លាប់ទទួលរងការធ្វើបាបផង។

ខ្ញុំពិតជាមានការព្រួយបារម្ភចំពោះបញ្ហាសុខភាពយ៉ាងខ្លាំង។ សព្វថ្ងៃនេះ ខ្ញុំកំពុងតែប្រឈមមុខនឹងជំងឺលើសឈាម ថែមទាំងជំងឺផ្សេងៗទៀតដែលបានធ្វើឲ្យខ្ញុំឈឺក្បាល ស្ពឹក ចុកចង្កេះ និងវិលមុខ។ ខ្ញុំព្យាបាលជំងឺរបស់ខ្ញុំតាមវិធីសាស្ត្របុរាណ។ ខ្ញុំផឹកថ្នាំបុរាណខ្មែរដែលផ្សំពីឫសឈើ។ ពេលខ្លះ ថ្នាំបុរាណនោះបានជួយឲ្យខ្ញុំបានធូរស្បើយខ្លះដែរ ប៉ុន្តែពេលខ្លះក៏ធ្វើឲ្យខ្ញុំមិនស្រួលខ្លួនដែរ។ សព្វថ្ងៃនេះ ខ្ញុំនៅតែឈឺក្បាល ស្ពឹក និងឈឺចង្កេះ។





# របបខ្មែរក្រហមមិនដែលរសាត់ចេញពីក្នុងចិត្តខ្ញុំឡើយ

អ៊ុន សុជាទី



លោកវេជ្ជបណ្ឌិត ដេម៉ូសធីន វ៉េយស៍ ទីប្រឹក្សាគម្រោង ប្រមូល និងចងក្រងការចងចាំបទពិសោធន៍ក្នុងរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងសួនាំពីអាការរោគរបស់ប្រជាជននៅតាមភូមិក្នុងខេត្តស្វាយរៀង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

អស់រយៈពេល៤១ឆ្នាំកន្លងមកហើយដែលរបបខ្មែរក្រហមបានដួលរលំ ប៉ុន្តែរបបនេះនៅតែស្ថិតនៅក្នុងចិត្តរបស់អ្នករស់រានមានជីវិត។ ការជិតដាមទាំងនេះអាចបណ្តាលមកពីរបបខ្មែរក្រហមបានផ្តល់មេរៀនជីវិតដ៏លំបាក និងឈឺចាប់ដែលស្ទើរតែមិនអាចទទួលយកបាន ឬរបបនេះបានបន្សល់ទុកនូវផលប៉ះពាល់ជាច្រើនដល់ការរស់នៅសម្រាប់ប្រជាជនកម្ពុជារហូតមកបច្ចុប្បន្ន។

ប្រែង ទូច ភេទស្រី អាយុ៧៥ឆ្នាំ រស់នៅភូមិត្រពាំងក្លោះ ឃុំជ្រៃធំ ស្រុករមាសហែកខេត្តស្វាយរៀងបានរៀបរាប់ប្រាប់ថា ខ្ញុំគឺជាកូនពៅនៅក្នុងចំណោមបងប្អូន១០នាក់។ នៅក្នុងរបបខ្មែរក្រហម បងប្អូនខ្ញុំស្លាប់អស់៧នាក់ ហើយសាច់ញាតិសរុប៥០នាក់ក៏បានស្លាប់ និងបាត់ខ្លួនដែរ។ ខ្ញុំមានកូនកំព្រា៥នាក់នៅក្នុងរបបខ្មែរក្រហម ព្រោះប្តីរបស់ត្រូវបានខ្មែរក្រហមយកទៅសម្លាប់។

បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ ខ្ញុំបានសម្រេចចិត្តរៀបការម្តងទៀត ព្រោះខ្ញុំគ្មានលទ្ធភាពចិញ្ចឹមកូនៗ និងម្តាយចាស់ជរារបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថា កូនៗរបស់ខ្ញុំអាចរស់នៅដោយមានអាហារហូបគ្រប់គ្រាន់ និងអាចមានលទ្ធភាពចូលរៀននៅសាលា។ ក្រោយមកខ្ញុំបានបង្កើតកូនបាន៥នាក់ថែមទៀត។ របបខ្មែរក្រហមបានបន្សល់ទុកនូវឧបសគ្គជាច្រើនក្នុងការរស់នៅសម្រាប់គ្រួសាររបស់ខ្ញុំ។ ប៉ុន្តែទោះបីជាយ៉ាងណា កូនៗរបស់ខ្ញុំ

បានរៀនដល់ថ្នាក់អនុវិទ្យាល័យ និងខ្លះទៀតរៀនបានដល់វិទ្យាល័យ។ សព្វថ្ងៃនេះ កូនៗរបស់ខ្ញុំធ្វើការងារជាជាងសំណង់ កម្មកររោងចក្រ និងលក់ដូរបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិត។

ពេញមួយជីវិតរបស់ខ្ញុំកើតមកបានឆ្លងកាត់សង្គ្រាមជាច្រើនជំនាន់។ នៅអំឡុងឆ្នាំ១៩៧០ មានការទម្លាក់គ្រាប់បែកជាច្រើនមកលើភូមិរបស់ខ្ញុំ ហើយក៏មានកងទ័ពធីវគី (វៀតណាមខាងត្បូង) ចូលមកភូមិរបស់ខ្ញុំដែលធ្វើឲ្យខ្ញុំមានការភ័យខ្លាចយ៉ាងខ្លាំង។ នៅពេលនោះគ្រួសាររបស់ខ្ញុំបានជីកលេណដ្ឋាននៅក្រោមផ្ទះដើម្បីការពារគ្រាប់ផ្លោង និងការទម្លាក់គ្រាប់បែកពីលើយន្តហោះ។ រហូតដល់ឆ្នាំ១៩៧៥ ខ្ញុំលែងឃើញមានកងទ័ពធីវគីទៀតហើយ គឺមានតែកងទ័ព និងកម្មាភិបាលរបស់ខ្មែរក្រហមតែប៉ុណ្ណោះ។ នៅឆ្នាំ១៩៧៨ ខ្មែរក្រហមបានសម្លាប់មនុស្សនៅក្នុងភូមិរបស់ខ្ញុំជាច្រើនរួមទាំងប្តីខ្ញុំ ព្រោះប្តីរបស់ខ្ញុំគឺជាអតីតទាហាន លន់ នល់។ យោធាខ្មែរក្រហមបានចោទប្រជាជននៅក្នុងភូមិថា «ក្បាលយួនខ្លួនខ្មែរ» និងជាអ្នកយកការណ៍ឲ្យកងទ័ពវៀតណាម។ ក្រោយមក ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជនចេញពីក្នុងភូមិទាំងអស់ ហើយខ្ញុំ និងក្រុមគ្រួសារក៏ត្រូវបានជម្លៀសទៅកាន់ខេត្តពោធិ៍សាត់ដែរ។ គ្រួសាររបស់ខ្ញុំរស់នៅយ៉ាងលំបាកវេទនានៅទីនោះ។ ថ្ងៃមួយពេលត្រឡប់មកពីធ្វើការងារនៅតាមការដ្ឋានវិញ ខ្ញុំឃើញកូនរបស់ខ្ញុំដេកស្លាប់នៅក្នុងរោងស្នាក់បណ្តោះអាសន្នតែម្នាក់ឯង។ កូនខ្ញុំរបស់ខ្ញុំកើតពិសនៅពេលនោះ។ មុខរបស់កូនខ្ញុំឡើងប្រែពណ៌ខ្មៅ។ មិនមែនមានតែកូនរបស់ខ្ញុំទេដែលស្លាប់នៅពេលនោះ គឺមានកូនរបស់ប្រជាជនដែលជម្លៀសទៅទីនោះជាច្រើននាក់ទៀត។ យើងរស់នៅដោយគ្មានអនាម័យ។ យើងផឹកទឹកដែលដងមកពីត្រពាំងបឹងបួរ និងហូបអាហាររួមដូរផ្អូម ដើម្បីបំពេញកម្លាំងធ្វើការងារជូនដល់អង្គការ។ ពេលនោះ មានប្រជាជនជម្លៀសជាច្រើនបានកើតជំងឺក្រញ៉ាល ពិស រាករូស និងជំងឺផ្សេងៗទៀតដែលបណ្តាលឲ្យស្លាប់អស់ជាច្រើននាក់។ ចំណែកខ្ញុំធ្វើកិច្ចការជាច្រើន ដូចជា លីបាវស្រូវ ភ្ជួរស្រែ ស្ទូងសំណាប់ និងលើកទំនប់។ ខ្មែរក្រហមមិនគិតថាយើងជាមនុស្សស្រីឬប្រុសទេ គឺត្រូវធ្វើការងារស្មើគ្នា។



ក្រុមការងារគម្រោងប្រមូល និងចងក្រងការចងចាំបទពិសោធន៍ក្នុងរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងលោកវេជ្ជបណ្ឌិត ដេម៉ូសធីន រ៉េយស៍ ជួបប្រជុំជាមួយអាជ្ញាធរឃុំនៅក្នុងខេត្តស្វាយរៀង ដើម្បីទទួលបានព័ត៌មាន មុននឹងចុះព្យាបាលជំងឺប្រជាជនដែលបានឆ្លងកាត់របបខ្មែរក្រហមនៅតាមភូមិ។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ដោយសារតែខ្ញុំបានឆ្លងកាត់រឿងរ៉ាវឈឺចាប់ និងបាត់បង់មនុស្សជាទីស្រឡាញ់អស់ជាច្រើននាក់នៅក្នុងរបបខ្មែរក្រហម ទើបខ្ញុំបានសម្រេចចិត្តដាក់ពាក្យបណ្តឹងទៅកាន់តុលាការខ្មែរក្រហមដើម្បីរកយុត្តិធម៌។ ខ្ញុំក៏បានតាមដានមើលការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលបានផ្សព្វផ្សាយតាមទូរទស្សន៍ដែរ។ ខ្ញុំតែងតែប្រាប់កូនរបស់ខ្ញុំ និងចៅៗថា «កូនៗនិងចៅសំណាងហើយដែលបានកើតមកនិងធំលូតលាស់នៅក្នុងរបបនេះដែលទទួលបានសិទ្ធិសេរីភាព មានការអប់រំ និងមានអាហារហូបបានគ្រប់គ្រាន់។ នៅក្នុងរបបខ្មែរក្រហមយាយមិនមានអាហារហូបគ្រប់ មិនមានពេលសម្រាកឲ្យបានគ្រប់គ្រាន់ និងសូម្បីតែឱកាសថែរក្សាជីវិតរបស់យាយក៏មានតិចតួចដែរ»។ ប៉ុន្តែមានក្មេងៗខ្លះមិនសូវជឿនូវអ្វីដែលខ្ញុំបានរៀបរាប់ឡើយ។ ខ្ញុំដឹងថារឿងរ៉ាវដែលបានកើតឡើងនៅក្នុងរបបខ្មែរក្រហមអាចធ្វើឲ្យក្មេងៗពិបាកទទួលយក ដោយសារតែក្មេងៗទាំងនោះកើតមកក្នុងសង្គមដែលមានសន្តិភាព និងមានឪពុកម្តាយថែទាំ។ ខ្ញុំមិនខឹងនឹងក្មេងៗដែលមិនជឿនៅរឿងរ៉ាវរបស់ខ្ញុំទេ ប៉ុន្តែខ្ញុំនៅតែបន្តនិយាយរឿងរ៉ាវរបស់ខ្ញុំ ព្រោះខ្ញុំចង់ឲ្យក្មេងៗទាំងនោះមានការប្រុងប្រយ័ត្នខ្ពស់ចំពោះការដឹកនាំនាពេលអនាគត។

សព្វថ្ងៃនេះ ខ្ញុំមានសុខភាពល្អប្រសើរជាងកាលពីរយៈពេលមួយឆ្នាំមុនច្រើនណាស់។ ជំងឺរបស់ខ្ញុំ បណ្តាលមកពីខ្ញុំធ្វើការងារធ្ងន់ៗ។ ខ្ញុំគិតថាជំងឺរបស់ខ្ញុំក៏អាចបណ្តាលមកពីខ្ញុំធ្លាប់ធ្វើការងារនៅក្នុងរបបខ្មែរក្រហមដែរ។ ដោយខ្ញុំមានវ័យកាន់តែចំណាស់ និងមានជំងឺប្រចាំកាយ ដូច្នេះខ្ញុំមិនអាចធ្វើស្រែចម្ការដូចពីមុនបានទៀតឡើយ។ ខ្ញុំនៅផ្ទះមើលថែចៅៗ។ ខ្ញុំធ្លាប់ឈឺចង្កេះ ប៉ុន្តែឥឡូវមិនសូវឈឺដូចពីមុនទេ ព្រោះខ្ញុំឈប់ធ្វើការងារធ្ងន់ៗ។ ខ្ញុំបានទៅពិនិត្យមើលចង្កេះរបស់ខ្ញុំនៅឯមន្ទីរពេទ្យមួយនៅក្នុងទីក្រុងភ្នំពេញ ហើយលទ្ធផលនៃការឈឺចង្កេះរបស់ខ្ញុំ គឺដោយសារតែឆ្អឹងខ្ញុំប្រេះស្រាំ និងចាប់ផ្តើមពុក។ ខ្ញុំបានផឹកថ្នាំ និងព្យាបាលដោយចលនាតាមការណែនាំរបស់គ្រូពេទ្យ។ ខ្ញុំភ័យបារម្ភចំពោះសុខភាពរបស់ខ្ញុំនៅពេលអនាគត។ សុខភាពរបស់ខ្ញុំពីមួយឆ្នាំទៅមួយឆ្នាំ គឺទ្រុឌទ្រោមៗ។ ខ្ញុំបារម្ភថាខ្ញុំដើរមិនរួច និងគ្មានលទ្ធភាពព្យាបាល។



លោកវេជ្ជបណ្ឌិត ដេម៉ូសធីន រ៉េយស៍ ទីប្រឹក្សាគម្រោង ប្រមូល និងចងក្រងការចងចាំបទពិសោធន៍ក្នុងរបបខ្មែរក្រហមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា កំពុងវាស់សម្ពាធឈាម និងពិនិត្យអាការរោគរបស់ប្រជាជននៅតាមភូមិក្នុងខេត្តស្វាយរៀង។ (ផេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំពិតជារីករាយប្រសិនបើមានការពិនិត្យសុខភាពដល់ខ្ញុំ។ ខ្ញុំនៅចាំបានថា នៅអំឡុងឆ្នាំ២០១៩ កន្លងមកនេះ មានវេជ្ជបណ្ឌិតជនជាតិហ្វីលីពីន និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះមកពិនិត្យសុខភាពរបស់ខ្ញុំ និងអ្នកដែលបានដាក់ពាក្យបណ្តឹងទៅកាន់សាលាក្តីខ្មែរក្រហមផ្សេងទៀត។ ខ្ញុំអរគុណ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានយកចិត្តទុកដាក់ និងបានទូរសព្ទសួរសុខទុក្ខខ្ញុំ។

# «ផេះផង់ធូលី»
# រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ
# សេក មឿន ៖ ពលទាហាន

**ប្រពន្ធរបស់គាត់ ឆេង ឃួន បាន និយាយរៀបរាប់ប្រាប់ថា៖**

ប្តីរបស់ខ្ញុំបានធ្វើការនៅរដ្ឋបាលអាកាសចរណ៍ស៊ីវិល នៅព្រលានយន្តហោះពោធិចិនតុងនៅពេលដែលយើងបានជួបគ្នា។ គាត់ជាអ្នកទទួលខុសត្រូវលើផ្នែកសន្តិសុខនៅព្រលានយន្តហោះនាពេលនោះជាពេលដែលប្រជាជនបានព្យាយាមដុតកម្ទេចព្រលានយន្តហោះនោះ។

មឿន បានរៀនសូត្រច្រើនជាងខ្ញុំ។ គាត់អាចនិយាយភាសាអង់គ្លេស បារាំង និងភាសាចិនយ៉ាងស្ទាត់ ព្រោះគាត់ជាកូនកាត់ចិន និងវៀតណាម។ បន្ទាប់ពីយើងរៀបការរួច យើងបានសង់ផ្ទះមួយនៅជិតការិយាល័យរបស់ មឿន។ មឿន មានប្រាក់ចំណូលតែ៤០០រៀលគត់ក្នុងមួយខែពីការងាររបស់គាត់នៅព្រលានយន្តហោះ ដូច្នេះគាត់បានបង្ខំចិត្តលួចប្រេងឥន្ធនៈយកទៅលក់ ធ្វើឲ្យយើងមានប្រាក់គ្រប់គ្រាន់សម្រាប់ផ្គត់ផ្គង់គ្រួសារ។ ថ្ងៃមួយនៅក្នុងឆ្នាំ១៩៧០ គាត់បានសម្រេចចិត្តមិនចង់ធ្វើការនៅខាងអាកាសចរណ៍ស៊ីវិលតទៅទៀតទេ គឺគាត់បានស្ម័គ្រចិត្តចូលធ្វើជាទាហានទៅច្បាំងនឹងខ្មែរក្រហម។ រាល់លើកគាត់ចេញទៅសមរភូមិ គាត់បានយកកូនៗរបស់ខ្ញុំ និងខ្ញុំទៅជាមួយគាត់។



សេក មឿន នៅខាងស្តាំ និងមិត្តភក្តិ នៅព្រលានយន្តហោះពោធិ៍ចិនតុង នៅឆ្នាំ១៩៦៦។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





កូនប្រុសច្បងរបស់ខ្ញុំមិនអាចអានបុសរសេរដល់សព្វថ្ងៃ ព្រោះវាតែងតែទៅជាមួយឪពុករបស់វា និងមិនបានចូលសាលារៀន។ នៅពេលខ្លះខ្ញុំធ្វើជាអ្នកយាមជំនួសប្តីរបស់ខ្ញុំ ដូច្នេះគាត់មានពេលសម្រាកខ្លះ។

នៅឆ្នាំ១៩៧៣ គាត់បានលាលែងពីទាហានហើយទៅធ្វើការជាអ្នកបើកបរជំនួសវិញ។ គាត់ក៏ចេះជួសជុលរថយន្តដែរ។ ប៉ុន្តែមួយរយៈខ្លីក្រោយមក គាត់បានត្រឡប់ទៅធ្វើជាទាហានម្តងទៀត។ នៅពេលដែលគាត់បានផ្ទេរទៅការិយាល័យយោធា២៤ ខ្ញុំបានទៅជាមួយគាត់ ទោះបីជាខ្ញុំរៀបតែនឹងសម្រាលកូនទីបួនរបស់ខ្ញុំក៏ដោយ។ នៅថ្ងៃដែលគាត់នឹងត្រូវបញ្ជូនទៅរៀនក្បួនយុទ្ធសាស្ត្រយោធានៅប្រទេសវៀតណាម ខ្ញុំបានរលូតកូន ដូច្នេះគាត់បានយកខ្ញុំទៅមន្ទីរពេទ្យ និងនៅជាមួយខ្ញុំទាល់តែខ្ញុំបានជាសះស្បើយ។

នៅឆ្នាំ១៩៧៥ យោធាខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំទាំងអស់ចេញពីបន្ទាយទាហាននៅភ្នំពេញ។ ខ្ញុំបានវេចខ្ចប់ឯកសណ្ឋានទាហានរបស់ប្តីខ្ញុំ ប៉ុន្តែបន្ទាប់មកបានគ្រវាត់វាចោលនៅតាមផ្លូវ ព្រោះអីខ្ញុំខ្លាចខ្មែរក្រហមរកឃើញឯកសណ្ឋាននោះ។ យើងបានធ្វើដំណើរឆ្ពោះទៅខេត្តតាកែវជាទីកន្លែងដែលម្តាយរបស់ខ្ញុំ និងសាច់ញាតិជាច្រើននាក់របស់ខ្ញុំជាប្រជាជនមូលដ្ឋាន។

យ៉ាងណាក៏ដោយ នៅពេលដែលយើងទៅដល់ អង្គការមិនបានអនុញ្ញាតឲ្យយើងនិយាយជាមួយអ្នករាល់គ្នាទេ ព្រោះយើងជាប្រជាជនថ្មី ហើយអ្នកភូមិក៏មិនបានស្វាគមន៍យើងដែរ។ បន្ទាប់មក យើងត្រូវបានបញ្ជូនទៅកាន់ភូមិមួយទៀតដែលនៅឆ្ងាយពីស្រុកកំណើតរបស់ខ្ញុំ ជាទីកន្លែងដែលអង្គការឲ្យយើងបំផ្លាញសាលារៀន និងវត្តជាច្រើន ហើយជីករណ្តៅសម្រាប់ដាក់សាកសពជនជាតិចិន បំផ្លាញម៉ុងរបស់ជនជាតិចិន។ ប្តីរបស់ខ្ញុំត្រូវបានបញ្ជាឲ្យឡើងដើមត្នោតច្រើនដើម ដើម្បីយកទឹកត្នោត និងវេញខ្សែព្រួរ។ ទោះបីការងារទាំងនេះថ្មីសម្រាប់គាត់ ក៏គាត់បានខិតខំប្រឹងធ្វើការយ៉ាងខ្លាំងដើម្បីជៀសវាងការចោទប្រកាន់ថាគាត់ជាអ្នកមូលធន។ រាល់យប់មានរទេះគោប្រហែល១៥គ្រឿង បានចូលមកក្នុងភូមិ និងបានដឹកប្រជាជនចេញទៅ។ អង្គការបាននិយាយថា អ្នកទាំងនោះត្រូវបានបញ្ជូនទៅរៀនសូត្រសាឡើងវិញ ប៉ុន្តែអ្នកទាំងនោះត្រូវបានសម្លាប់។ ខ្ញុំដឹងអំពីរឿងនេះ ព្រោះរបស់ប្រើប្រាស់ និងខោអាវរបស់អ្នកទាំងនោះបានយកមកភូមិវិញ។ ភាគច្រើននៃប្រជាជនដែលដឹកចេញទៅ ជាពលបាលទោ បុនាយទាហានជាន់ខ្ពស់។ ខ្ញុំបានសួរថា ហេតុអ្វីបានជាមិនយកខ្ញុំទៅ អង្គការបាននិយាយថា អង្គការទុកខ្ញុំមួយរយៈសិន និងបន្ទាប់មកទៀត ខ្ញុំនឹងត្រូវរៀនសូត្រសាឡើងវិញ។

នៅចុងឆ្នាំ១៩៧៥ យើងត្រូវបានបញ្ជូនទៅខេត្តបាត់ដំបង ជាទីកន្លែងដែលយើងបានរស់នៅជាមួយប្រជាជន ១៧ មេសា ដូចគ្នា។ យើងបានសង់ជម្រកមួយធ្វើពីឫស្សី ហើយជីវិតរបស់យើងក៏មិនលំបាកពិបាកដូចមុនដែរ។ យើងមានពេលវេលាសម្រាកខ្លះ និងអាចស្តាប់ចម្រៀងប្រពៃណីនៅអំឡុងពេលចូលឆ្នាំខ្មែរ។ ប្តីរបស់ខ្ញុំបានបន្តធ្វើការជាអ្នកឡើងត្នោត ហើយខ្ញុំត្រូវបានបញ្ជូនទៅធ្វើការនៅក្នុងរោងកិនស្រូវ។

ថ្ងៃមួយនោះ អង្គការបានឆែកឃើញអង្ករមួយក្តាប់ដៃ ដែលលាក់ទុកនៅក្នុងហោប៉ៅអាវរបស់ខ្ញុំ។ ខ្ញុំមិនបានដឹងសោះ ថាអង្ករនៅក្នុងហោប៉ៅរបស់ខ្ញុំ។ កូនស្រីរបស់ខ្ញុំបានដាក់អង្ករនោះនៅក្នុងហោប៉ៅរបស់ខ្ញុំនៅពេលនាងកំពុងលេង។ អង្គការបានយកខ្ញុំទៅឃុំនៅក្នុងរោងកិនស្រូវចាស់មួយពេញមួយថ្ងៃ ប៉ុន្តែពិតជាសំណាងមែន អង្គការបានដោះលែងខ្ញុំវិញ។

កងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជា នៅឆ្នាំ១៩៧៩ ហើយគ្រួសាររបស់ខ្ញុំបានរត់ចេញពីសហករណ៍។ យើងបានផ្លាស់ទីលំនៅទៅខេត្តសៀមរាបមួយរយៈពេលខ្លី។ ខ្ញុំបានពរពោះកូនទីប្រាំរបស់ខ្ញុំ ហើយប្តីរបស់ខ្ញុំបានសម្រេចចិត្តហែលឆ្លងបឹង ដូច្នេះគាត់អាចទៅដោះដូរស្បៀងបាន ប៉ុន្តែវាគ្រោះថ្នាក់ខ្លាំងណាស់ចំពោះគាត់។ គាត់បានប្រើកំណាត់ឈើដើម្បីរែកស្បៀងនោះ។ គាត់តែងតែធ្វើបែបនេះសម្រាប់គ្រួសារ។ បន្ទាប់មកយើងបានត្រឡប់ទៅស្រុកកំណើតរបស់ មឿន វិញ។ យើងមិនមានអង្ករច្រើនសម្រាប់ដាំបាយហូបទេ ដូចនេះយើងបានយកមាសរបស់យើងដូរយកក្រម៉ាបានជាច្រើន។ បន្ទាប់មកយើងបានយកក្រម៉ាទៅដូរយកស្បៀង។

**ប៉ាង ពីច័ន្ទ និង ទេនី ឧកហ្គៀល**

«ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ស៊ឹ ស្រស់ ៖ ពេទ្យទាហាន

ខ្ញុំបានបួសជាសង្ឃនៅពេលដែលខ្ញុំអាយុ១២ឆ្នាំ។ ប៉ុន្តែមួយឆ្នាំក្រោយមក ខ្ញុំបានសឹក ព្រោះខ្ញុំមានការយល់ដឹងបន្តិចបន្តួចពីព្រះពុទ្ធសាសនា។

នៅពេលរដ្ឋប្រហារទម្លាក់ស្តេចសីហនុ ខ្ញុំជាប្រធានភូមិ។ ខ្ញុំបានគ្រប់គ្រងផ្ទះជាង៥០ខ្នង ទោះយ៉ាងណាខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រមូលពន្ធផ្ទាល់ទៀតឡើយ។ ខ្ញុំក៏បានត្រួតកងស្វ័យត្រាណជាង១២នាក់ និងដឹកនាំយាមល្បាតជុំវិញភូមិ។ នៅឆ្នាំ១៩៧៣ មានការរីករាលដាលយ៉ាងខ្លាំងនៅក្នុងភូមិរបស់យើង។ លើកទីមួយ ផ្ទះដែលខ្ញុំបានសង់នៅឆ្នាំ១៩៦៨ ត្រូវបានបំផ្លាញដោយសារគ្រាប់បែក ដូចនេះខ្ញុំបានសង់ជម្រកមួយនៅខាងមុខវត្តសម្រាប់រស់នៅ។ បន្ទាប់មកយោធាខ្មែរក្រហម បានចូលមកហើយបានបំផ្លាញភូមិខ្ទេចខ្ទី។ សមរភូមិប្រយុទ្ធបានកើតមានជាបន្តបន្ទាប់ អ្នកភូមិបានចាប់ផ្តើមផ្លាស់ទីលំនៅ។

ខ្ញុំបានដោះដូរស្រូវរបស់ខ្ញុំដែលមានគុណភាពល្អ ទៅដូរយកស្រូវមានគុណភាពមិនសូវល្អបានច្រើនដើម្បីចិញ្ចឹមកូន៨នាក់របស់ខ្ញុំ ហើយបានធ្វើការងារផ្សេងទៀតដើម្បីចិញ្ចឹមជីវិត។ ខ្ញុំជាកសិករ ជាចុងភៅសម្រាប់ពិធីមង្គលការ ខ្ញុំក៏បានចូលបំរើកងទ័ពលន់ នល់ មាននាទីជាពេទ្យទាហាន។ យោធាខ្មែរក្រហមបានជម្លៀសបងប្អូនប្រុស-ស្រីរបស់ខ្ញុំទាំងអស់ ទៅខេត្តបាត់ដំបង នៅឆ្នាំ១៩៧៥ ប៉ុន្តែគ្រួសាររបស់ខ្ញុំបានទៅស្រុកណ្តាលស្ទឹង។ ខ្ញុំមិនបានយកឯកសណ្ឋានយោធាទៅជាមួយខ្ញុំទេ ខ្ញុំបានកប់ឯកសណ្ឋានជាមួយកាំភ្លើងរបស់ខ្ញុំនៅក្នុងដីនៅជិតវត្ត។



ស៊ឹ ស្រស់ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



ក្មួយរបស់ស៊ឹ ស្រស់ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្មែរក្រហមបានសួរអំពីប្រវត្តិរូបរបស់ខ្ញុំជារៀងរាល់ខែ។ លើកដំបូង ខ្ញុំប្រាប់គេថាខ្ញុំជាកសិករ អ្នកលីបាវស្រូវ និងអ្នករែកទឹក។ ប៉ុន្តែនៅឆ្នាំ១៩៧៧ ខ្ញុំបានប្តូរចម្លើយ ហើយប្រាប់គេថាខ្ញុំជាទាហានម្នាក់។ ប្រពន្ធរបស់ខ្ញុំ និងកូនៗមិនបានរស់នៅជាមួយខ្ញុំទេ គឺរស់នៅឆ្ងាយពីគ្នានៅក្នុងកងចល័ត។ ខ្ញុំបានធ្វើការនៅផ្នែកអារឈើ នៅថ្ងៃមួយនោះឈើមូលធំមួយដើមបានធ្លាក់ត្រូវចង្កេះខ្ញុំ។ នៅក្នុងមន្ទីរពេទ្យ គ្រូពេទ្យបានចាក់ថ្នាំឲ្យខ្ញុំជាច្រើនដង។ ខ្ញុំបានស្នាក់នៅទីនោះជិត២៨ថ្ងៃ។
អំឡុងពេលនៃការស្នាក់នៅរបស់ខ្ញុំមានអ្នកជំងឺជាច្រើននាក់បានបាត់ខ្លួន។ ខ្ញុំបានសួរគម្រូកិបាលពេទ្យម្នាក់អំពីរឿងនេះ គាត់បានប្រាប់ខ្ញុំថា អ្នកជំងឺទាំងនោះបានត្រឡប់ទៅធ្វើការវិញហើយ។ ប៉ុន្តែ ក្រោយមកប្រធានកងរបស់ខ្ញុំបានខ្សឹបប្រាប់ខ្ញុំថា ខ្ញុំត្រូវតែចាកចេញពីមន្ទីរពេទ្យឆាប់ៗ បើអាចទៅបាន បើមិនអញ្ចឹងទេ ខ្ញុំនឹងត្រូវបាត់ខ្លួនដូចអ្នកជំងឺផ្សេងៗទៀតដែរ។ ខ្ញុំគិតថាអ្នកជំងឺទាំងអស់នោះត្រូវបានបញ្ជូនទៅសម្លាប់។

នេះជារូបថតក្មួយរបស់ខ្ញុំ រូបនេះថតនៅក្នុងរបបលន់ នល់។ វាធ្លាប់ធ្វើជាទាហាន វា និងប្រពន្ធរបស់វា និងសាច់ញាតិរបស់វាជាច្រើននាក់ត្រូវបានខ្មែរក្រហមសម្លាប់។ ខ្ញុំអាណិតក្មួយខ្ញុំណាស់ ព្រោះអីម្តាយរបស់វាបានស្លាប់នៅពេលដែលវាមានអាយុបាន១ឆ្នាំ ហើយឪពុករបស់វាមានការលំបាកយ៉ាងខ្លាំងនៅពេលនោះ ដោយរកមនុស្សម្នាក់មកបំបៅវា។ បងប្អូនប្រុស-ស្រីរបស់ខ្ញុំពីរនាក់បានស្លាប់នៅអំឡុងរបបខ្មែរក្រហម ប៉ុន្តែកូនរបស់ខ្ញុំទាំងអស់បានរស់រានមានជីវិតពីរបបនោះ។

**ប៉ាង ពីច័ន្ទ និង ទេនី ខកហ្គៀល**





«ផេះផង់ធូលី»

## រឿងរ៉ាវចេញពីប្រជាជនថ្មីក្រោមរបបកម្ពុជាប្រជាធិបតេយ្យ

# ឈួន សុភ័ក្រ ៖ តម្រួតយោធា

ម្តាយរបស់ខ្ញុំបានស្លាប់នៅពេលដែលខ្ញុំនៅក្មេងនៅឡើយ ហើយឪពុករបស់ខ្ញុំមិនមានប្រាក់គ្រប់គ្រាន់ដើម្បីផ្គត់ផ្គង់ការរៀនសូត្ររបស់ខ្ញុំទេ។ ដូច្នេះខ្ញុំបានផ្លាស់ទីលំនៅពីខេត្តព្រៃវែងទៅភ្នំពេញជាទីដែលខ្ញុំបានរស់នៅជាមួយបងថ្លៃខ្ញុំឈ្មោះ ចាន់ គឹមហោរ។ គាត់ជាពលបាលទោនៅក្នុងកងទ័ពបានសុំខ្ញុំឲ្យប្រឡងចូលធ្វើជាទាហាន។ បន្ទាប់ពីខ្ញុំ បានប្រឡងជាប់មក ខ្ញុំបានរៀនវគ្គបណ្តុះបណ្តាលយោធាចំនួន៧ខែ និងវគ្គបណ្តុះបណ្តាលបច្ចេកទេសកាំភ្លើងធំ។ ខ្ញុំបានជ្រើសរើសវគ្គចូលរៀននៅអង្គភាពអាវុធធុនធ្ងន់នៃកងកម្លាំងអាកាស។

បន្ទាប់ពីយើងបានបញ្ចប់វគ្គបណ្តុះបណ្តាលមក សមាជិក៨នាក់របស់ក្រុមយើងជាអង្គរក្សបានតាមការពារសម្តេចសីហនុ នៅពេលព្រះអង្គយាងទៅទតខេត្តផ្សេងៗ។ អង្គរក្សនីមួយៗនៅក្នុងក្រុមបានកាន់កាំភ្លើងដែលមានប្រវែង ៣៧ មីលីម៉ែត្រ។

នៅឆ្នាំ១៩៦៧ បន្ទាប់ពីខ្ញុំចាប់បានខ្មែរក្រហមម្នាក់នៅខេត្តបាត់ដំបង សម្តេចបានផ្តល់មេដាយឲ្យខ្ញុំមួយគ្រឿង និងបានតម្លើងខ្ញុំឲ្យទៅធ្វើការនៅក្នុងកងកម្លាំងអាកាសទីបី ជាទីដែលខ្ញុំបានវាយប្រយុទ្ធនៅលើសមរភូមិជាច្រើន។ យើងត្រូវបានឡោមព័ទ្ធដោយយោធាខ្មែរក្រហមពីរដង និងជាប់ការ



ឈួន សុភ័ក្រ នៅក្នុងអំឡុងរបបលន់ នល់ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ហ៊ុំព័ទ្ធចំនួនមួយអាទិត្យ និងច្រើនជាងមួយអាទិត្យ។

ខ្ញុំបានរៀបការជាមួយ អ៊ិន សែមួន នៅឆ្នាំ១៩៧២។ យើងបានជួបគ្នានៅចំការអណ្តូង នៅពេលដែលខ្ញុំដឹកនាំកងវរសេនាតូចមួយទៅវាយប្រយុទ្ធនៅសមរភូមិចេនឡា។ បន្ទាប់មកយើងបានផ្លាស់ទៅក្រុងភ្នំពេញ ជាទីដែលប្រពន្ធខ្ញុំធ្វើការជាជាងកាត់ដេរ។ ខ្ញុំជាយុទ្ធជនដែលជៀសមិនរួច ត្រូវបញ្ជូនទៅសមរភូមិប្រយុទ្ធ ដូចនេះខ្ញុំត្រូវបានផ្ទេរទៅការិយាល័យតម្រួតយោធានៅក្រុងភ្នំពេញ។

នៅក្នុងខែកុម្ភៈឆ្នាំ១៩៧៥ ខ្ញុំបានសម្រេចចិត្តរស់នៅបែកពីប្រពន្ធរបស់ខ្ញុំ និងកូនៗ មួយរយៈ ពីព្រោះ

មានអស្ថិរភាពនយោបាយនៅក្នុងប្រទេស។ ប្រពន្ធរបស់ខ្ញុំចង់ទៅរស់នៅជាមួយឪពុកម្តាយរបស់នាងនៅខេត្តកំពង់ចាម ហើយខ្ញុំចង់ភៀសខ្លួនទៅប្រទេសអាមេរិក តាមប្រទេសថៃ។ ខ្ញុំមិនមានប្រាក់គ្រប់គ្រាន់ទិញសំបុត្រយន្តហោះសម្រាប់នាង និងកូនៗរបស់យើងទេ ខ្ញុំមានប្រាក់គ្រប់ល្មមទិញសំបុត្រមួយសម្រាប់ខ្លួនខ្ញុំប៉ុណ្ណោះ។

ខ្ញុំបានចាកចេញពីក្រុងភ្នំពេញ ហើយហោះទៅខេត្តបាត់ដំបង ជាទីដែលខ្ញុំអាចរកបណ្តាញមួយដែលអាចនាំខ្ញុំចេញទៅប្រទេសថៃ។ ខ្ញុំបានប្រាប់ប្រពន្ធរបស់ខ្ញុំ និងកូនៗថា ខ្ញុំនឹងត្រឡប់វិលវិញនៅថ្ងៃមួយ ដែលប្រទេសយើងមានសន្តិភាពពេញលេញ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលខ្ញុំទៅដល់បាត់ដំបងខ្ញុំបានសម្រេចចិត្តនៅក្នុងប្រទេសកម្ពុជា។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសខ្ញុំទៅភូមិមួយនៅក្បែរព្រំដែនថៃ។ ខ្មែរក្រហមបានប្រាប់ប្រជាជនឲ្យចុះឈ្មោះរបស់ពួកគេនិងមុខងារ ដូច្នេះគេអាចត្រឡប់ទៅធ្វើការងារចាស់របស់គេវិញ។ ប្រជាជនខ្លះបាននិយាយថា គេជាភ្នាក់ងារគយ ឬនាយទាហាន។ ទោះជាយ៉ាងណា ខ្ញុំបានប្តូរឈ្មោះរបស់ខ្ញុំទៅជាសុខ ចាន់ ហើយបានប្រាប់ថា ខ្ញុំជាកម្មកររោងចក្រ។ ថ្ងៃបន្ទាប់មក ភ្នាក់ងារគយនិងទាហានត្រូវបានយកចេញទៅដាក់ក្នុងរថយន្តជាច្រើនគ្រឿង ហើយមិនត្រឡប់មកវិញឡើយ។

ថ្វីបើខ្ញុំចង់សុំលិខិតអនុញ្ញាតទៅសួរសុខទុក្ខប្រពន្ធកូនៗរបស់ខ្ញុំ ច្បាប់របស់អង្គការវាតឹងរឹងខ្លាំងណាស់ ដូច្នេះខ្ញុំមិនហ៊ានឡើយ។ ប្រសិនបើខ្ញុំត្រឡប់ទៅស្រុកកំណើត ខ្ញុំនឹងត្រូវបានសម្លាប់ ព្រោះខ្ញុំជាទាហាន។

ខ្ញុំបានធ្វើការងារដូចគោនៅតាមវាលស្រែ។ ក្រុមការងារនីមួយៗមានមនុស្ស៩នាក់ យើង៨នាក់បានអូសនង្គ័លដូចគោ ហើយម្នាក់ទៀតបានទប់នង្គ័ល។ មុនដំបូង យើងបានហូបគ្រប់គ្រាន់ ប៉ុន្តែបន្ទាប់មករបបអាហារបានបន្ថយ។ ខ្មែរក្រហមបានបញ្ជាមនុស្ស៥០នាក់ ឲ្យអូសរទេះច្រើនដឹកបាវស្រូវ១៣០បាវ ពីភូមិមួយចម្ងាយ២០គីឡូម៉ែត្រយកទៅគោកតាសាត។

អង្គការបានផ្ទេរខ្ញុំញឹកញាប់ឲ្យទៅធ្វើការនៅភូមិផ្សេងៗ បន្ទាប់ពីពេលប្រូតកាត់រួច។ ខ្ញុំបានជញ្ជូនស្រូវនិងអង្ករមយកទៅទុកដាក់នៅក្នុងជង្រុក។ បង បានធ្វើការនៅក្នុងរោងកិនស្រូវជាមួយគ្នា។ គាត់ត្រូវបានចោទប្រកាន់ជាជនជាតិវៀតណាម ហើយបានបញ្ជូនទៅសម្លាប់។ ពីរថ្ងៃបន្ទាប់មក អង្គការបានយកប្រពន្ធនិងកូនៗរបស់បងទៅសម្លាប់ទៀត។ បង អាចនិយាយភាសាវៀតណាម ប៉ុន្តែគាត់ជាជនជាតិខ្មែរ។

ថ្ងៃមួយ កម្មាភិបាលដែលធ្វើការនៅក្នុងសហករណ៍បានយកទាពីរឲ្យខ្ញុំចិញ្ចឹម។ គាត់បានសន្យាថានៅពេលដែលទាធំផ្តល់ពង គាត់នឹងចែកចំណែកពងទាជាមួយខ្ញុំ។ ទោះយ៉ាងណានៅពេលដែលទានោះធំ ប្រធានថ្មីត្រូវបានផ្ទេរទៅកាន់ជង្រុកស្រូវ។ កម្មាភិបាលចង់បានទារបស់គាត់ទៅវិញ ប៉ុន្តែខ្ញុំមិនអាចឲ្យទានោះទៅគាត់ ព្រោះអ្វីៗទាំងអស់ត្រូវបានគ្រប់គ្រងដោយប្រធានថ្មី។ ដូច្នេះកម្មាភិបាលនោះ បានចោទខ្ញុំថា បានលួចទារបស់គាត់។ នៅរសៀលថ្ងៃដដែលនោះ កម្មាភិបាល បានយកខ្ញុំទៅមន្ទីរសេដ្ឋកិច្ច ជាទីដែលចោទប្រកាន់ខ្ញុំថាជាជនចក្រពត្តិ។ ខ្ញុំមិនអាចប្រឆាំងនឹងកម្មាភិបាលឡើយ ខ្ញុំបានត្រឹមតែបន់ស្រន់ប៉ុណ្ណោះ។ កម្មាភិបាល បានវាយខ្ញុំទាល់តែខ្ញុំសន្លប់ពេញមួយថ្ងៃ។ ខ្នងប្រាណរបស់ខ្ញុំប្រឡាក់ដោយឈាម។ បន្ទាប់មកអង្គការបានបញ្ជូនខ្ញុំ ត្រឡប់ទៅកងរបស់ខ្ញុំវិញ។ មិនមានអ្នកណាម្នាក់ហ៊ាននិយាយរកខ្ញុំទៀតឡើយ ព្រោះខ្ញុំបានប្រព្រឹត្តឲ្យមានកំហុស។

នៅពេលដែលកងទ័ពវៀតណាមបានចូលមកប្រទេសកម្ពុជានៅឆ្នាំ១៩៧៩ ខ្ញុំបានប្រមូលប្រជាជននៅក្នុងភូមិ ដើម្បីងើបឡើងប្រឆាំងនឹងខ្មែរក្រហមដោយប្រើដំបង និងកាំបិត។ បន្ទាប់មកខ្ញុំបានត្រឡប់ទៅកំពង់ចាមស្វែងរកប្រពន្ធ និងកូនៗរបស់ខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ អ្នកភូមិនៅទីនោះបានប្រាប់ខ្ញុំថា ប្រពន្ធរបស់ខ្ញុំ ឪពុករបស់នាង និងបងប្អូនប្រុសស្រី និងកូនៗរបស់យើង ត្រូវបានខ្មែរក្រហមសម្លាប់បាត់ហើយ។ ខ្ញុំបានរកសាកសពរបស់ពួកគេ ប៉ុន្តែ អ្វីដែលខ្ញុំបានរកឃើញនោះ គឺជាមន្ទីរសន្តិសុខមួយ។

**ប៊ុន ពិច័ន្ទ និង ទេនី ខករម្ភ្លៀល**





# ព្រឹត្តិការណ៍ ថ្ងៃ១៥មេសា

## ឧក្រិដ្ឋកម្មមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

## កៅ សំរិទ្ធ (តពីលេខមុន)

នៅឯខាងជើងស្ពានទី២ ឯណោះវិញ មានពួកយោធាអាវខ្មៅមួយក្រុមឈរយាមផ្លូវទៅកាន់សាលាសង្កាត់គោកធ្លកលើដែលកាត់តាមភូមិសង្កែ។ ពួកក្រុមនោះចាប់ខ្លួនមនុស្សម្នាដែលធ្វើដំណើរឆ្លងកាត់ដោយមិនរើសមុខ។ លោកមាព្រំ រី យល់សភាពការណ៍ពេលនោះថា ប្រាកដជាមានការសម្លាប់មនុស្សជាមិនខាន ទើបបានជាគាត់ស្លុតចិត្តយ៉ាងខ្លាំងនៅពេលដែលគាត់បានឃើញពួកអាវខ្មៅឃាត់ខ្លួនលោកឪពុកខ្ញុំ លោកអាចារ្យ យាន និងលោកមាវ៉ន ដែលជិះកង់តាមផ្លូវនោះ។ ពួកគាត់ត្រូវក្រុមយោធាចាប់ចងនិងនាំខ្លួនទៅឲ្យអង្គុយជាមួយអ្នកជាប់ចំណងផ្សេងទៀតនៅវាលស្រែក្បែរស្ពាន។

យុវជនហឿន អាយុ១៧ឆ្នាំ ដៃជាប់ចំណងនៅមិនឆ្ងាយប៉ុន្មានពីឡានតាសុក បានឃើញយោធាអាវខ្មៅបីបួននាក់ចាក់ស្រា.សចេញពីកានដឹកនៅក្នុងឡាន ហើយម្នាក់ក្នុងចំណោមអ្នកទាំងនោះទាញកាំបិតមួយចេញមកស្រាយក្រណាត់រុំចេញរួចគ្រវីដើរសំដៅទៅអ្នកជាប់ចំណង។ យោធាម្នាក់នោះឈ្មោះ យី មានអាយុ២២ឆ្នាំជាអ្នកភូមិគោកធ្លក ដែលនៅមិនឆ្ងាយប៉ុន្មានពីភូមិត្រពាំងវែង។ លោកមាខាន់ ដែលដៃគាត់ស្ទាក់ខ្យល់ដោយសារ


កៅ សំរិទ្ធ

ចំណងដ៏តឹងប៉ែស មានការឈឺចាប់ហួសប្រមាណ ក៏ស្រែកជេរពួកយោធាអាវខ្មៅថា «ពួកអាត្រូវគ្រាប់! ពួកអ្ហែងចងដៃអញឈឺយ៉ាងនេះ ឆាប់យកអញទៅសម្លាប់ទៅ! យកទៅអារ.កបុរីចោល ក៏រីទៅ អញមិនខ្លាចស្លាប់ទេ ធ្វើបដិវត្តន៍ដូចតែគ្នាទេតើ!» ពេលនោះសមមិត្តយីកាន់កាំបិតមួយ សមមិត្តធាក៏មានកាន់កាំបិតគ្នោតមួយដែរ និងគ្នីគ្នាប្រមាណ១០នាក់ទៀតស្ទុះទៅទាញលោកមាខាន់ លោកអាចារ្យ នល់ និង៨នាក់ផ្សេងទៀតឲ្យក្រោកឈរ រឹតចំណងឲ្យកាន់តែតឹងជាងមុន គឺរឹតទាល់តែកែងដៃជាប់គ្នា ហើយចងភ្ជាប់គ្នាមួយខ្សែ៥នាក់ តឹងសឹងតែខ្ទង់ទល់នឹងខ្នង។ ពួកពេជ្ឈឃាតចាប់អូសជនរងគ្រោះទាំង ២ ខ្សែដែលដើរសឹងមិនកើតដោយសារតែចំណង យកទៅអារ.កសម្លាប់នៅគុម្ពោតព្រៃខាងលិចចម្ងាយប្រមាណ១០០ម៉ែត្រពីកន្លែងប្រជុំ។ លោកមាព្រំ រី មិនត្រូវបានពួកយោធាចង្អុលមុខឲ្យទៅឈរតម្រង់ជួរ ដើម្បីចងស្លាបសេកដូចអ្នកផ្សេងឡើយ។ ឃើញដូច្នោះ តាសុក ក៏ចង្អុល និងស្រែកថា «ចុះម៉េចក៏មិនចងអាម្នាក់នេះផងទៅ?» សមមិត្ត ស៊ុម ដែលនៅក្បែរនោះក៏តបថា «ម្នាក់នេះជាអ្នកមូលដ្ឋានចាស់ មានប្រវត្តិល្អទេ»។ តាសុក ក៏តបថា «អើ មើលអ្នកណាមានប្រវត្តិល្អឲ្យទៅផ្ទះវិញទៅ»។ លោកព្រំ រី ដែលកាលនោះមានអាយុ៣០ឆ្នាំគត់ ធ្លាប់ឆ្លងកាត់ការប្រយុទ្ធក្នុងសមរភូមិច្រើនដង បានសច្ចាក្នុងចិត្តថានឹងតដៃឲ្យបានមុនគេចាប់ចងបំណាច់តែនឹងស្លាប់ដូចតែគ្នា។ រូបគាត់ សមមិត្ត ស៊ឹម លោកអាចារ្យនល់ លោកមាខាន់ ធ្លាប់បួសរៀនជាមួយគ្នានៅវត្តគោកធ្លក ។ ក្នុងចំណោមជនរងគ្រោះទាំង១០នាក់ដំបូងដែលពួកអាវខ្មៅទើបនឹងប្រល័យ គឺមានលោកមាខាន់ និងលោកអាចារ្យនល់ផងដែរ។ ប្រហែលជាដោយសារតែរឿងហ្នឹងទើបសមមិត្ត ស៊ឹម ដាក់គូទអង្គុយមិនឆ្ងាយប៉ុន្មានពីលោកព្រំ រី និងពោលថា «បើធ្វើបែបហ្នឹងស្លាប់ប្រជាជនអស់ហើយ»។

ក្រោយពីប្រល័យជីវិតក្រុមដំបូងហើយ ពួកក្រុមពេជ្ឈឃាតបានត្រឡប់មកជនរងគ្រោះបន្ទាប់ទៀតដែលជាក្រុមទី២។ មានបុរសម្នាក់នៅពេលឃាតកឲ្យក្រោកឈរដើម្បីរឹតខ្សែចំណងគាត់ក៏ស្រែកឡើងថា «ជយោបដិវត្តន៍កម្ពុជា!»។ តាសុក ក៏ស្រែកតបថា «បដិវត្តន៍ចោរម្រាយម្អែងអី បើអញមិនទាន់មកដល់ផងនាំគ្នាបះបោររកកាប់អញ?» ពេលនោះយោធាម្នាក់បានរើសយកប្រែករទេះដែលបាក់ជា២កំណាត់ ដែលគេទុកចោលនៅវាលស្រែសំពងគាត់ដួល ហើយម្នាក់ទៀតយកកាំបិតទៅអារ.កគាត់ បាញ់ឈាមឆ្វាច ប្រកាច់ស្លាប់នៅចំពោះមុខជនរងគ្រោះផ្សេងទៀត។ បុរសម្នាក់មានមុខមាត់ស្អាតបាតដូចកូនកាត់ចិនដែលជាប់ចំណងអង្គុយរង់ចាំវេនប្រល័យ មានការតក់ស្លុតយ៉ាងខ្លាំងគាត់ស្រែកទ្រហោយំបែរបន់គុណម៉ែគុណឪឲ្យជួយ។ លោកមាព្រំ រី ឃើញលោកឪពុកខ្ញុំស្ថិតក្នុងចំណោមជនរងគ្រោះក្រុមបន្ទាប់ដែលមានចំនួន១០នាក់ ក្នុងនោះមានទាំងលោកអាចារ្យយាន ពេទ្យផាត់ និងលោកមា វន ផងដែរ។

ក្នុងអំឡុងពេលដែលពួកពេជ្ឈឃាតកំពុងប្រល័យ ពួកយាមផ្លូវបានឃាត់អ្នកបររទេះម្នាក់ឈ្មោះ តិ ដែលគេតែងហៅគាត់ថាចិនតិ កំពុងបររទេះគោម្នាក់ឯងក្នុងគោលបំណងទៅលេងបងប្អូនគាត់នៅឯកំពង់ក្តី ដែលជាភូមិកំណើតរបស់គាត់។ ជាអកុសល គាត់ទៅដល់ចំពេលពួកអាវខ្មៅកំពុងចាប់មនុស្សគ្មានរើសមុខ។ ពួកវាឲ្យគាត់ចុះពីរទេះ តែគាត់ជជែកតវ៉ាថា «រឿងអីដែលពួកឯងចាប់អញ? អញគ្មានបានទៅធ្វើបាតុកម្មឯណាទេ»។ សំដីតវ៉ាបែបនេះបានធ្វើឲ្យពួកវាខឹង ហើយទាញចន្ទល់រទេះវាយគាត់ដួលសន្លប់។ មួយសន្ទុះក្រោយមកគាត់ក៏ដឹងខ្លួនខ្លះៗ ហើយនិយាយដោយមមើមមាយស្តាប់មិនបាន ចំពេលដែលពួកពេជ្ឈឃាតត្រឡប់មកយកជនរងគ្រោះផ្សេងទៀតទៅប្រហារ ក៏យកកាំបិតអារ.កគាត់ស្លាប់នៅនឹងកន្លែងនោះតែម្តងទៅ។

យុវជន ហឿន (ដែលមុននោះឃើញពួកពេជ្ឈឃាតដឹកស្រាលើឡាន) កំពុងជាប់ចំណងអង្គុយរង់ចាំវេនមរណៈដោយគ្មានក្តីសង្ឃឹមបន្តិចណាឡើយ តែខណៈដែលឃើញតាសុក ដើរមកក្បែរប្រមែប្រមូលសេចក្តីក្លាហាននិយាយអង្វរថា «អុំអើយខ្ញុំអត់ដឹងអីទេ ខ្ញុំទើបនឹងមកពីរហាលព្រលល្ងាចមិញនេះឯង»។ តាសុក សម្លឹងមុខរួចក៏បញ្ជាយោធាម្នាក់ថា «លែងវាទៅ វានៅក្មេងឈាមរាវទេ»។ ជាមហាសំណាងបំផុតមិនមែនតែសម្រាប់ហឿនម្នាក់ទេ តែយុវជន៣នាក់ទៀត (ភាត់ នួន និង ង៉ិក) ដែលអង្គុយក្បែរគ្នាក៏ត្រូវបានដោះលែងដែរ។ ហឿន អរពេកមិនដឹងខ្លួនថាឈឺអីទេ ទាល់តែទៅដល់ផ្ទះទើបឈឺដៃដែលស្វាក់ខ្យល់ដោយសារចំណង រមួលខ្លួនប្រកាច់ប្រកិន ហើមចេញទឹករងៃដូចដៃសាកសព។

លោកមាព្រំ រី គឺជាប្រជាជនតែម្នាក់គត់ដែលអង្គុយមើលហេតុការណ៍នាពេលនោះសឹងតែពីដើមដល់ចប់។ គាត់ឃើញមានស្រា.សមួយកានដាក់លើឡានរបស់ពួកកងការពារ និងឃើញពួកពេជ្ឈឃាតចេញចូលដឹកស្រវឹងជោកជាំ។ ក្រោយពីការប្រហារជនរងគ្រោះទាំង៣ក្រុម ហើយពួកវារៀបចំបន្តដំណើរទៅមុខទៀត។ លោកមារី សួរស៊ីមថា «បងទៅណាទៀត?» ស៊ីមឆ្លើយថា «ទៅភូមិគោកធ្លក។ លោកប្អូនកុំភ្លេចទៅប្រាប់បងប្អូនយើងឲ្យទុកដាក់អ្នកទាំងនោះ (សពជនរងគ្រោះ) ផង»។ មួយសន្ទុះមក តាសុកដើរមកប្រាប់បន្ថែមទៀតថា «មិត្តឯងទៅកប់ខ្មោចផង ហើយដើរប្រមូលផ្គាក់ពូថៅយកទៅទុកក្នុងរោងយាមនៅចុងភូមិ»។ នៅពេលដែលពួកនោះចេញទៅផុត លោកមា ដើរប្រាប់អ្នកភូមិឲ្យប្រមូលផ្គាក់ពូថៅទៅទុកនៅរោងយាម ហើយគាត់ទៅយកចបនៅឯផ្ទះដើម្បីកប់សព។

ពេលទៅដល់លានពិឃាត លោកមា ស្ទុតចិត្តស្ទើរទន់ជង្គង់ដួលដោយសារឃើញសព ៣៧នាក់ រណ្ដូករណែលគរជើងលើគ្នាក្បែរគុម្ពោតព្រៃដែលសពនិមួយៗមានក្បាលស្ទើរតែដាច់ចេញពីដងខ្លួន ផ្ទៃមុខជោគជាំដោយឈាម។ គាត់បីសពលោកអាចារ្យនល់ លោកមាខាន់ និងលោកមាឃីទៅដាក់នៅម្លប់ឈើ ចំណែកសាកសពដទៃទៀត គាត់កាត់ចំណងមុននឹងកប់ក្នុងរណ្តៅរួម។ ដើម្បីជាការងាយស្រួលប្រាប់បងប្អូនឲ្យស្វែងរកនាពេលក្រោយ គាត់ដាក់សពអ្នកដែលគាត់ស្គាល់ក្នុងទិសដៅផ្ទុយពីសពដទៃ។ ដោយឡែកសពលោកឪពុកខ្ញុំ គាត់ដាក់ឈើមួយកំណាត់ពីលើទុកជាការចំណាំមុននឹងលុបដី។

នៅពេលធ្វើដំណើរកាត់តាមភូមិសង្កែ ពួកក្រុមឃាតកបានសម្លាប់បុរសៗមួយចំនួន ដែលវាជួបនៅតាមផ្លូវ។ ជនរងគ្រោះម្នាក់ក្នុងចំណោមអ្នកទាំងនោះឈ្មោះ នៅ ត្រូវជាអ៊ំបង្កើតរបស់ពេជ្ឈឃាត យី។ មានអ្នកដឹងពីរឿងនោះថា ពីដំបូង យី ស្ទាក់ស្ទើរមិនចង់សម្លាប់គាត់ទេ គឺគ្រាន់តែធាក់ឲ្យដួល ហើយឲ្យធ្វើពុតជាស្លាប់ ប៉ុន្តែអ៊ំនៅបានស្រែកខ្លាំងៗថា «យើសអាកូនចង់សម្លាប់ឪឯងផង?» ពេលនោះយីដែលប្រហែលជាខ្លាចបែកការណ៍ទៅដល់តាសុក ថាត្រូវរ៉ូវគ្នាជាមួយខ្មាំងក៏អារ.កសម្លាប់គាត់តែម្តងទៅ។

មានយុវជនអ្នកធ្វើដំណើរ និងបុរសៗអ្នកភូមិដែលពួកវាហៅឲ្យចេញពីផ្ទះចំនួន២៥នាក់ទៀតក៏ត្រូវបានពួកវាចាប់ចងដែរ។ ប្រហែលជាប្រញាប់បន្តដំណើរទៅភូមិគោកធ្លកទៀតទើបពួកវាមិនទាន់សម្លាប់ ហើយចាត់តាំងយោធាមួយចំនួនឲ្យបណ្តើរទៅកំពង់ក្តី។ ក្នុងចំណោមអ្នកទាំងនោះមានយុវជនម្នាក់ឈ្មោះឈង់ ដែលរស់នៅជាមួយបងស្រីនៅភូមិត្រពាំងវែងមិនឆ្ងាយប៉ុន្មានពីស្ពានទី២។ នាថ្ងៃកើតហេតុនោះ គាត់ក្រោកពីព្រលឹមទៅយករទេះពីភូមិម្តាក់មកទុកនៅផ្ទះវិញ តែជាអភ័ព្វ ដែលគាត់បររទេះមកផ្ទះវិញក៏ជួបនឹងពួកក្រុមឃាតកនៅភូមិសង្កែឃាត់ខ្លួន និងចាប់ចង។ នៅពេលដែលគេបណ្តើរគាត់ទៅដល់មុខផ្ទះ ឈង់ ក៏ស្រែកទ្រហោយំដាក់បងស្រីថា «បងអើយ! ប្អូនមិនសង្ឃឹមថានឹងបានរស់ទេ»។ បងស្រីរបស់ឈង់ភាំងស្មារតី គ្មានពាក្យអ្វីតបមកប្អូនវិញឡើយក្រៅពីការសោកសង្រេង។ ក្រុមឃាតកបានចេញពីភូមិសង្កែទៅដល់ភូមិគោកធ្លក បានឃើញក្រុមបាតុករឈរព្រោងព្រាតក៏ធ្វើការបាញ់រះ។ ពេជ្ឈឃាតធា បានដើរពីផ្ទះមួយទៅផ្ទះមួយសម្ភុតប្រជាជនសួររកផ្គាក់ពូថៅ ដែលយកទៅប្រើធ្វើបាតុកម្ម។ ពេជ្ឈឃាតយី ដែលមានផ្ទះនៅគោកធ្លកបានឆ្មៀតចូលទៅប្រាប់យាយទីជាម្តាយថា «ម៉ែអើយអ៊ំនៅស្លាប់ហើយ ខ្ញុំទៅជួយគាត់មិនទាន់»។ នោះជាការនិយាយបំភ្លៃការពិតដើម្បីលុបលាងទង្វើដ៏ឃោរឃៅព្រៃផ្សៃរបស់វា។

នៅឯវត្តគោកធ្លកឯនោះ បាតុករមួយក្រុមប្រមាណ ៣០-៤០នាក់កំពុងជុំគ្នា នៅពេលឮស្នូរកាំភ្លើង ពួកគាត់ក៏រត់គេចតាមវាលស្រែទៅទិសខាងជើង និងខាងលិចបែកគ្នាអស់។ បុរសម្នាក់ឈ្មោះម៉ានត្រូវគ្រាប់កាំភ្លើងអឹម៧៩ស្លាប់នៅភូមិថ្នល់ចាស់ប្រមាណ ៥០០ម៉ែត្រខាងជើងវត្ត។

ពួកអាវខ្មៅរាយគ្នាជា ២ខ្សែព័ទ្ធភូមិតាភ្វាដែលនៅខាងលិចវត្តគោកធ្លក បាញ់គំរាមពេញភូមិ។ ប្រុសៗត្រូវបានពួកវាបង្ខំឲ្យទៅប្រជុំនៅឯវត្ត ប៉ុន្តែបុរសៗខ្លះដែលភាគច្រើនជាអ្នកមូលដ្ឋានចាស់សម្រេចចិត្តទៅប្រជុំដោយសារតែការចង់ដឹងចង់ឮ។ បងទីវ វិចារតន៍ ដែលកំពុងនៅលេងនៅផ្ទះបងទីវសារិននៅក្បែរវត្ត ភ័យនឹងស្នូរកាំភ្លើងក៏រត់ពួនក្នុងច្បារអំពៅ ប៉ុន្តែនៅពេលឃើញសមមិត្តបើន ប្រធានយោធាស្រុកថ្មីដែលជាមនុស្សស្គាល់គ្នាកាលនៅការដ្ឋានទំនប់ម្តាក់ ក៏សម្រេចចិត្តទៅប្រជុំដែរ។

យុវជនអាយុ២៣ឆ្នាំម្នាក់ឈ្មោះ សៀវ សុផុន ដែលរស់នៅឯភូមិថ្នល់តាសិតក្បែរថ្នល់ជាតិចម្ងាយ៩គីឡូម៉ែត្រពីទីនោះបានឮ សូរអឹម៧៩ជាច្រើនគ្រាប់។ គាត់ និងអ្នកភូមិអន្ទះសាចង់ដឹងនូវហេតុការណ៍ដែល កំពុងកើតឡើងនោះយ៉ាងខ្លាំង។

មិនដូចកាលនៅត្រពាំងវែងដែលមានការប្រជុំសិនមុននឹងចង តែលើកនេះគឺចាប់ចងតែម្តងដោយមិនរើសមុខ ដោយប្រើវល្លិ និងខ្សែគោពីរោងសិប្បកម្មនៅក្នុងវត្ត ហើយក៏មានខ្សែនីឡុង និងក្រណាត់ស្បង់លោកផងដែរ។ ពួកវាលូកហោប៉ៅយកថ្នាំជក់និងដែកកេះពីជនរងគ្រោះអស់គ្មានសល់។ មនុស្សប្រមាណ១០០នាក់ ដែលជាប់ចំណង ត្រូវបានពួកវាឲ្យអង្គុយសណ្តូកជើងជាជួរក្នុងទីធ្លាវត្ត មួយចំនួនទៀតដែលវាចាប់ពីទិសខាងកើតត្រូវវាចងទុកនៅរបងវត្តក្បែរខ្លោងទ្វារចូលវត្ត។ ខាងត្បូងទីនោះបន្តិច គឺជាទីដែលតាសុកចតឡាន។

ពូសាគី ជាអ្នកមូលដ្ឋានចាស់មកពីភូមិតាភ្វា ដែលក្លាហាន និងសំដីបានផងដែរនោះបានតវ៉ានឹងពួកទាហានអាវខ្មៅថា «កាលពីមិនទាន់បានរដ្ឋអំណាចពួកមិត្តឯងហៅពួកខ្ញុំថាពុកៗពេញមាត់។ ឥឡូវបដិវត្តន៍បានជោគជ័យម៉េចក៏បែរទៅជាចងពុកឯងទៅវិញ?» គ្មានពួកអាវខ្មៅម្នាក់ណាតបតទៅគាត់វិញទេ។

ខណៈពេលដែលកំពុងមានការចាប់ចងនោះ គេឃើញសមមិត្តអ៊ុនដើរចូលទៅក្នុងបរិវេណវត្ត ហើយជួបនិយាយជាមួយសមមិត្តស៊ីម ដែលជាមនុស្សស្គាល់គ្នា។ មិនដឹងជាពួកគាត់និយាយគ្នាថាម៉េចខ្លះទើបបានជាមានបញ្ជាឲ្យចងស្វាបសេកគាត់ ហើយបណ្តើរចេញទៅចងភ្ជាប់នឹងដើមស្វាយព្រៃមួយដើម ដែលនៅមិនឆ្ងាយប៉ុន្មានពីឡានតាសុក។ គឺដើមស្វាយនោះហើយដែលកាលពីមួយខែមុនមានស្លាកស្នាមចម្លែកធ្វើឲ្យអ្នក

(តនៅលេខក្រោយ)

# បញ្ជីឈ្មោះអ្នកដែលបានស្លាប់
## នៅក្នុងរបបខ្មែរក្រហម ចារទុកក្នុងសៀវភៅរំឭកវិញ្ញាណក្ខន្ធនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

*ផាន់ថាន់ ពៅដារ៉ា និង ឡុង ដានី*

(តពីលេខមុន)

**ធី សែម** *មានអាយុ៣៣ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅសៀមរាប ខេត្តសៀមរាប ជាកូនរបស់អ៊ំ ទី សំផុន និងអ៊ំស្រី ហួរ នី មានប្រពន្ធឈ្មោះ ម៉ែន វ៉ាវី មានកូនប្រុស ២នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅអូរត្របែក ថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ០២ បន្ទប់តូច ១១។ (គ្មានក្នុងបញ្ជី)។*

**ធឹម កុយ** *មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ អ៊ុក វ៉ែន និងមីង យិន ហួន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ (គ្មានក្នុងបញ្ជី)។*

**ធឹម យ៉ាន** *ហៅ ស៊ាន មានអាយុ២០ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្ទោង ខេត្តកំពង់ធំ ជាកូនរបស់ពូ ទឹម ស៊ុក និងមីងរ័ត្ន ឡុង ត្រូវបានខ្មែរក្រហមចាប់ខ្លួនឋាមពល ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទឹម យាន នៅថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩ ថ្ងៃ។*

**ធឹម ស៊ី** *មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៨ (ស្រុកកោះធំ) ខេត្តកណ្ដាល ជាកូនរបស់ពូ ឆេង និងមីង ទឹម អួយ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទឹម ស៊ី នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧។*

**ធឹម សារិន** *អតីតទាហានជើងទឹក ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទឹម សារិន ពីភូមិតា ឡី ទៅដល់គុកទួលស្លែងនៅថ្ងៃទី៣០ ឬ ៣១ ខែសីហា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី៦ ខែធ្នូ ឆ្នាំ១៩៧៦។*

**ធី ធុយហុង** *មានអាយុ៣៧ឆ្នាំក្នុងឆ្នាំ១៩៧៧ ជាកូនរបស់អ៊ំ ទី សៀង និងអ៊ំស្រី ខៀវ ស៊ិន មានប្រពន្ធឈ្មោះ សូ សាមឿន មានកូនប្រុស ២នាក់និងស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរស-៨ ឡានទឹក ថ្ងៃទី៣១ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទី ទុយហុង ឬ ទី ទុយហេង នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២៤ ថ្ងៃ។*

**ធុយ ផាន់** *មានអាយុ៣០ឆ្នាំ ក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកងមាស ខេត្តកំពង់ចាម ជាកូនរបស់ពូ ទុយ ហ៊ាង និងមីង គីម ហ៊ិន មានប្រពន្ធឈ្មោះ ឯក លាត ហៅ មូល មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទុយ វ៉ាន់ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៧៦ ថ្ងៃ។*

**ធុយ សាន** *ហៅ ទុយ ត្រាច មានស្រុកកំណើតនៅសណ្ដាន់ ខេត្តកំពង់ធំ ជាកូនរបស់ពូ អាង ឈាន និងមីង សេក អែម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរពេទ្យភ្នំពេញ ព-៣១ ថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៣ បន្ទប់តូច ១០។ ខ្មែរក្រហមសម្លាប់ ទុយ សាន នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ១៩៧៧។*

**ធុំ ខេន** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល១៧០ ក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទុំ ខេន ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៤ ថ្ងៃ។*

**ធុំ ឈុំ** *ហៅ ឆន មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅកណ្ដាលស្ទឹង ខេត្តកណ្ដាល ជាកូនរបស់អ៊ំ ទី ប៉ក់ និងអ៊ំស្រី ព្រុំ ម៉ាន់ មានប្រពន្ធឈ្មោះ សុង ស៊ាងគង់ មានកូនប្រុស ១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅភ្នំស្រុក ថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក បន្ទប់ធំ ១ បន្ទប់តូច ២។ (មនុស្សតែមួយនឹង ទី ឆុំ ខាងលើ)។*

**ធុំ ជឹម** *មានអាយុ៤២ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅសណ្ដាន់ខេត្តក្រចេះ ជាកូនរបស់អ៊ំ ជា និងអ៊ំស្រី រឿន មានប្រពន្ធឈ្មោះ ជឹម គុយ មានកូនស្រី ២នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួនពាណិជ្ជកម្មរដ្ឋ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ០៣ បន្ទប់តូច ៩។ បើយោងតាមឯកសារនៅបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលយកទៅធ្វើបញ្ជីឡើងវិញដោយការិយាល័យសហព្រះរាជអាជ្ញានៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រកឃើញថា ទុំ ជឹម ត្រូវបានខ្មែរក្រហមចាប់បញ្ជូនទៅដល់គុកទួលស្លែងនៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ (ផ្ទុយនឹងថ្ងៃខែចាប់ខ្លួន)។*

**ធុំ ឈឿន** *ហៅ ឆន ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុង១៩៧៦ នៅឃ្លាំងរដ្ឋ។ ខ្មែរក្រហមចាប់បញ្ជូន ទុំ ឈឿន ទៅដល់គុកទួលស្លែងនៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៩២ ថ្ងៃ។*

**ធុំ ថាច** *មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅតាខ្មៅ ខេត្តកណ្ដាល ជាកូនរបស់ពូ ម៉ុក ទុំ និងមីង ជុំ សុខុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស្រុក១៥៤ ថ្ងៃទី១៩ ខែមករា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៨ បន្ទប់ធំ ១៣។ ខ្មែរក្រហមចាប់បញ្ជូន ទុំ ថាច ទៅដល់គុកទួលស្លែងនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១០៦ ថ្ងៃ។*

**ធុំ ប៉ុម** *មានអាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅបារាយណ៍ ខេត្តកំពង់ធំ ជាកូនរបស់ពូ ស្រី ទុំ និងមីង វ៉ាយ យឹប មានប្រពន្ធឈ្មោះ រី ហៅ វ៉ុម មានកូនប្រុស ១នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៣១០ ថ្ងៃទី៥ ខែធ្នូ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ០២ បន្ទប់តូច ២។ ខ្មែរក្រហមចាប់បញ្ជូន ទុំ ប៉ុម ទៅដល់គុកទួលស្លែងនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។*

**ធូច ត្រី** *ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១យ ក្នុងឆ្នាំ១៩៧៦។ (គ្មានក្នុងបញ្ជី)។*

**ធូច ខន** *ហៅ ស៊ីផា មានអាយុ៤០ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅស្រុក១៨ (ស្រុកស្អាង) ខេត្តកណ្ដាល ជាកូនរបស់អ៊ំ ទូច និងអ៊ំស្រី អន មានប្រពន្ធឈ្មោះ ប៉ិ ជូរ មានកូនប្រុស ៤នាក់និងស្រី ៣នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ១៥ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៥ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ០ បន្ទប់ធំ ០២ បន្ទប់តូច ៨។ ខ្មែរក្រហមសម្លាប់ ទូច ងន នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៦។*

**ទូច ថុង** មានអាយុ៤១ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅគីរីវង្ស ខេត្តតាកែវ ជាកូនរបស់អ៊ំ ទូច ឃិន និងអ៊ំស្រី ហ៊ុន ប្រិច មានប្រពន្ធឈ្មោះ អ៊ុង ចាន់ថុល មានកូនស្រី ៤នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅមន្ទីរ ក-១៥ ថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ឆ បន្ទប់ធំ ៤ បន្ទប់តូច ១៧។ ខ្មែរក្រហមសម្លាប់ ទូច ថុង នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៣ ថ្ងៃ។ ប្រពន្ធឈ្មោះ អ៊ុង ចាន់ថុល ត្រូវបានខ្មែរក្រហមចាប់ និងសម្លាប់នៅថ្ងៃជាមួយនឹងប្តីគាត់ដែរ។

**ទូច ទី** អាយុ៣០ឆ្នាំក្នុងឆ្នាំ១៩៧៥ ស្រុកកំណើតនៅភ្នំស្រួច ខេត្តកំពង់ស្ពឺ ជាកូនរបស់ពូ កុយ ទូច និងមីង ណុប ម៉ែន មានប្រពន្ធឈ្មោះ សឿង ភុន ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅរទេះភ្លើងកំពង់សោម ថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទូច ទី នៅថ្ងៃទី៦ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៦២ ថ្ងៃ។

**ទូច ទឹម** ហៅ ផល មានអាយុ៤៣ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅជើងព្រៃ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ កែវ ទូច និងអ៊ំស្រី ស ជាម មានប្រពន្ធឈ្មោះ ពិច សី មានកូនប្រុស ២នាក់និងស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមសម្លាប់ ទូច ទឹម នៅថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៥៥ ថ្ងៃ។

**ទូច ប្រិល** ហៅ សាយ ត្រូវបានខ្មែរក្រហមចាប់ខ្លួនក្នុងឆ្នាំ១៩៧៦។ ខ្មែរក្រហមចាប់បញ្ជូន ទូច ប្រិល ហៅ សាយ ទៅដល់គុកទួលស្លែងនៅថ្ងៃទី២៣ ឬ ២៤ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៧៦។

**ទូច ភឿន** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅស-២១ឃ ថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ទូច ភឿន នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៨៦ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ២១ ថ្ងៃ។

**ទូច យ៉យ** ហៅ វណ្ណា មានអាយុ២៥ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅពញាក្រែក ខេត្តកំពង់ចាម ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅពញាក្រែក ថ្ងៃទី២០ ខែតុលា ឆ្នាំ១៩៧៦។ ខ្មែរក្រហមសម្លាប់ ទូច យ៉យ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ១៥០ ថ្ងៃ។

**ទូច សាយ** ត្រូវបានខ្មែរក្រហមឃាត់ខ្លួននៅរទេះភ្លើង ថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

**ទូច សារ៉េង** មានអាយុ២២ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅទូកមាស ខេត្តកំពត ជាកូនរបស់ពូ ទូច ភេន និងមីង អ៊ុប ប៊ូ ត្រូវបានខ្មែរក្រហមចាប់ខ្លួនថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៧៦ នៅស្ថានីយ៍ផ្ទះ ឡាង ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ១ បន្ទប់តូច ៨។ ខ្មែរក្រហមចាប់បញ្ជូន ទូច សារ៉ែង ទៅដល់គុកទួលស្លែងនៅថ្ងៃទី២១ ឬ ២២ ខែតុលា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧។

**ទូច សុត** ត្រូវបានខ្មែរក្រហមចាប់ខ្លួនតំបន់២៥ក្នុងឆ្នាំ១៩៧៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

**ទូច ហ៊ុន** មានអាវយុ៣៦ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្ទឹងត្រង់ ខេត្តកំពង់ចាម ជាកូនរបស់អ៊ំ គន ស្លាម និងអ៊ំស្រី អុល មានប្រពន្ធឈ្មោះ វ៉ន មានកូនប្រុស ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ខ បន្ទប់ធំ ១ បន្ទប់តូច ៩។ ខ្មែរក្រហមសម្លាប់ ទូច ហ៊ុន នៅថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ បន្ទាប់ពីជាប់ឃុំឃាំងអស់រយៈពេល ៩៩ ថ្ងៃ។





**ទួត ចប** មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៦ មានស្រុកកំណើតនៅស្រុក ១៤ (ស្រុកលើកដែក) ខេត្តកណ្តាល ជាកូនរបស់ពូ ឈិត ទួត និងមីង ខឹម ស៊ៀង ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅព្រែកហូ ខែកុម្ភៈ ឆ្នាំ១៩៧៦ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៣ បន្ទប់ធំ ៧។ ខ្មែរក្រហមចាប់បញ្ជូន ទួត ចប ទៅដល់គុកទួលស្លែងនៅថ្ងៃទី៥ ឬ ១៦ ខែមីនា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៦។

**ទួត ជា** ហៅ អុល មានអាយុ២៧ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅកំពង់ស្វាយ ខេត្តកំពង់ធំ ជាកូនរបស់ពូម៉ី ហ៊ើង និងមីង ណាវ មឿន មានប្រពន្ធឈ្មោះ អ៊ឹម ម៉េត មានកូនស្រី ១នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅកងពល៤៥០ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ១៩៧៧។ ខ្មែរក្រហមចាប់បញ្ជូន ទួត ជា ទៅដល់គុកទួលស្លែងនៅថ្ងៃទី២២ ឬ ២៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ និងសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧។

**ទួត ញឹម** មានអាយុ៤៨ឆ្នាំក្នុងឆ្នាំ១៩៧៥ មានស្រុកកំណើតនៅមង្គលបូរី ខេត្តបាត់ដំបង ជាកូនរបស់អ៊ំ ទូត ខ្មៅ និងអ៊ំស្រី ចាន់ សួន មានប្រពន្ធឈ្មោះ ម៉ង់ សារិន មានកូនប្រុស ២នាក់និងស្រី ៧នាក់ ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥ នៅវត្តបារាយណ៍ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ក០៦ បន្ទប់ធំ ៦។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការមកដល់គុកទួលស្លែង និងការសម្លាប់នៅឡើយ។

**ទួន រស់** មានអាយុ១៩ឆ្នាំក្នុងឆ្នាំ១៩៧៧ មានស្រុកកំណើតនៅស្រុក១៥៤ តំបន់ ១៥ ជាកូនរបស់ពូ ទួន សយ និងមីង កែវ សុក ត្រូវបានខ្មែរក្រហមចាប់ខ្លួននៅស-២១ឃ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ ហើយបញ្ជូនទៅឃុំឃាំងនៅគុកទួលស្លែងក្នុងផ្ទះ ង បន្ទប់ធំ ៣ បន្ទប់តូច ៨។ នៅពុំទាន់មានឯកសារបញ្ជាក់ពីកាលបរិច្ឆេទនៃការសម្លាប់នៅឡើយ។

(តទៅលេខក្រោយ)

**ការបោះពុម្ពផ្សាយរឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ**

ទស្សនាវដ្ដីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា សង្ឃឹមថាប្រជាជនកម្ពុជាគ្រប់រូប និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលបាន និងកំពុងសរសេរអត្ថបទ ឬសៀវភៅ អំពីរឿងរ៉ាវពិតផ្ទាល់ខ្លួនទាក់ទងនឹងរបបខ្មែរក្រហម ហើយមានបំណងផ្សព្វផ្សាយ សូមផ្ញើមកទស្សនាវដ្ដីស្វែងរកការពិតតាមអាសយដ្ឋាន ៖ ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥ ឬ (៨៥៥) ៩៩៦ ៧៥០

អ៊ីម៉ែល៖ truthbunthorn.s@dccam.org - គេហទំព័រ៖ www.dccam.org

រូបក្របមុខ៖
ព្រះសង្ឃនៅមុខព្រះវិហារ វត្តថ្មី ហៅ វត្តជម្ពូរព្រឹក្សា នៅក្នុងស្រុកស្វាយទាប (បច្ចុប្បន្ន ក្រុងស្វាយរៀង) ខេត្តស្វាយរៀង។
(ដេវីដ ហ៊ិក/ បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)
រូបក្របក្រោយ ៖
ប្រជាជនកម្ពុជាវិលត្រឡប់មកស្រុកកំណើត បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅឆ្នាំ១៩៧៩។
(ឌិញ ហ៊ុង និង ហូ វ៉ាន់តាយ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org
A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 246, June 2020 ◆ Funded by USAID
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.